ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជបណ្ឌិត្យសភាកម្ពុជា

# ព្រឹត្តិបត្រ
# ក្រុមប្រឹក្សាជាតិភាសាខ្មែរ

## BULLETIN DU CONSEIL NATIONAL DE LA LANGUE KHMERE

## BULLETIN OF THE NATIONAL COUNCIL OF KHMER LANGUAGE

លេខ ៨ ឆមាសទី១ ឆ្នាំ២០១៧

Vol. 8, Semester 1, 2017

អាសយដ្ឋាន៖ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់កាកាប ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ
ទូរសព្ទដៃ៖ (៨៥៥) ១២ ៩១១ ៣៥៧, (៨៥៥) ១២ ៩០៦ ៥៨៥ អ៊ីមែល៖ info@nckl.gov.kh គេហទំព័រ៖ www.nckl.gov.kh

Scanned with CamScanner

# មាតិកា

ចំណងជើង ទំព័រ


• គណៈគ្រប់គ្រងនិងក្រុមការងារ.....i

• បុព្វកថា.....iii

• អារម្ភកថា.....v

I- កម្រងច្បាប់ទាក់ទងនឹងក្រុមប្រឹក្សាជាតិភាសាខ្មែរ (ក.ជ.ភ.ខ.).....១

• ព្រះរាជក្រឹត្យលេខ នស/រកត/១១១៤/១៣៦៧ ត្រាស់បង្គាប់តែងតាំងនិងផ្ដល់ឋានៈអគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិភាសាខ្មែរ.....៣

• ព្រះរាជក្រឹត្យលេខ នស/រកត/០៨១៥/៩២៧ ត្រាស់បង្គាប់តែងតាំងឧត្តមទីប្រឹក្សានៃក្រុមប្រឹក្សាជាតិភាសាខ្មែរ បន្ថែមលើមុខងារបច្ចុប្បន្ន.....៤

• ព្រះរាជក្រឹត្យលេខ នស/រកត/០១១៦/០៧០ ត្រាស់បង្គាប់តែងតាំងសមាសភាពនៃក្រុមប្រឹក្សាជាតិភាសាខ្មែរ.....៦

• ព្រះរាជក្រឹត្យលេខ នស/រកត/០៦១៦/៦៦៦ ត្រាស់បង្គាប់តែងតាំងអនុប្រធានប្រចាំការ និងសមាជិកនៃក្រុមប្រឹក្សាជាតិភាសាខ្មែរ បន្ថែមលើតំណែងបច្ចុប្បន្ន.....៧

• ព្រះរាជក្រឹត្យលេខ នស/រកត/០៨១៧/៦៤២ ត្រាស់បង្គាប់តែងតាំងនិងផ្ដល់ឋានៈប្រធានក្រុមប្រឹក្សាជាតិភាសាខ្មែរ.....៩

• សេចក្ដីសម្រេចលេខ ៣៩ សសរ ស្ដីពី ការផ្ទេរសមាជិក ការបញ្ឈប់ពីសមាជិក និង ការតែងតាំងសមាជិកបន្ថែមក្នុងគណៈកម្មការបច្ចេកទេសមួយចំនួននៃក្រុមប្រឹក្សាជាតិភាសាខ្មែរ.....១១

• សេចក្ដីសម្រេចលេខ ១២ សសរ ស្ដីពី ការតែងតាំងសមាសភាពនៃគណៈកម្មការបច្ចេកទេសនិងការតែងតាំងមន្ត្រីជំនួយការក្នុងអគ្គលេខាធិការនៃក្រុមប្រឹក្សាជាតិភាសាខ្មែរ.....១៣

• សេចក្ដីសម្រេចលេខ ៣៩ សសរ ស្ដីពី ការតែងតាំងសមាជិកបន្ថែមនិងការបញ្ចប់តំណែងក្នុងគណៈកម្មការបច្ចេកទេសមួយចំនួននិងក្នុងអគ្គលេខាធិការនៃក្រុមប្រឹក្សាជាតិភាសាខ្មែរ.....១៦

II- សមិទ្ធផលនៃក្រុមប្រឹក្សាជាតិភាសាខ្មែរ.....១៩

II.១- សិក្ខាសាលាស្ដីពី «ពិពិធភាពនៃភាសាខ្មែរ».....២១

II.២- បច្ចេកសព្ទ អក្ខរាវិរុទ្ធនិងអំណាន អនុម័តដោយ ក.ជ.ភ.ខ.....២៨

II.២.១- បច្ចេកសព្ទស្នើដោយគណៈកម្មការវប្បធម៌.....២៨

II.២.២- បច្ចេកសព្ទស្នើដោយគណៈកម្មការប្រវត្តិវិទ្យា.....៤៤

II.២.៣- បច្ចេកសព្ទស្នើដោយគណៈកម្មការភូមិវិទ្យា.....៨៥

II.២.៤- បច្ចេកសព្ទស្នើដោយគណៈកម្មការវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា.....១០៣

III- លិខិតទាក់ទងនឹងការជូនព្រឹត្តិបត្រលេខ៧របស់ក្រុមប្រឹក្សាជាតិភាសាខ្មែរ.....១១៧

• លិខិតថ្លែងអំណរគុណរបស់សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាមកក្រុមប្រឹក្សាជាតិភាសាខ្មែរ.....១១៩


Scanned with CamScanner

- លិខិតថ្លែងអំណរគុណរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាមកក្រុមប្រឹក្សាជាតិភាសាខ្មែរ.................... ១២០
- លិខិតលេខ ០៨៩ សជណ ប.ស្ក របស់ក្រសួងបរិស្ថានមកក្រុមប្រឹក្សាជាតិភាសាខ្មែរ.................... ១២១
- លិខិតលេខ ០៦១ ២០១៥/LC របស់ក្រុមហ៊ុន មេនញូឡាយហ្វ៍ (ខេមបូឌា) ភីអិលស៊ី មក ក្រុមប្រឹក្សាជាតិភាសាខ្មែរ.................... ១២២


Scanned with CamScanner

# គណៈគ្រប់គ្រងនិងក្រុមរៀបចំព្រឹត្តិបត្រ

- ឯកឧត្តមបណ្ឌិត នៅ ស៊ុន
- បណ្ឌិត សន ពៅ
- លោក លាង សុភាព
- លោកស្រី ហង់ លក្ខិណា
- លោកបណ្ឌិត ប៉ោ គឿន
- លោក សេ អឿន
- លោក ជួន សោរិទ្ធី
- លោក គឹម សុវត្ថិ

# អារម្ភកថា

ព្រឹត្តិបត្រលេខ៨នេះ ចុះផ្សាយពីលទ្ធផលនៃការអនុម័តពាក្យស្នើដោយគណៈកម្មការបច្ចេកទេសមួយចំនួន លទ្ធផលនៃសិក្ខាសាលាស្ដីពី «ពិពិធភាពនៃភាសាខ្មែរ» និង លិខិតថ្លែងអំណរគុណនិងការលើកសរសើររបស់ស្ថាប័ននានាចំពោះក្រុមប្រឹក្សាជាតិភាសាខ្មែរផងដែរ។

ក្រុមប្រឹក្សាជាតិភាសាខ្មែរ(ក.ជ.ភ.ខ.) សូមថ្លែងអំណរគុណទុកជាមុនចំពោះសាធារណជន ដែលជួយផ្ដល់យោបល់ទិតៀនស្ថាបនាទាក់ទងនឹងពាក្យស្នើពីគណៈកម្មការបច្ចេកទេសនានា ដែលក.ជ.ភ.ខ.បានអនុម័តដើម្បីឱ្យយើងមានលទ្ធភាពពិនិត្យឡើងវិញ និងសម្រេចចុងក្រោយ។

ក្នុងនាមនៃក.ជ.ភ.ខ.ទាំងមូលខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនសម្ដេចបណ្ឌិតសភាចារ្យ អគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលតែងតែឧបត្ថម្ភនិងផ្ដល់ការគាំទ្រដ៏ខ្ពង់ខ្ពស់ដល់ក្រុមប្រឹក្សាជាតិភាសាខ្មែរទាំងផ្នែកស្មារតី ទាំងផ្នែកសម្ភារៈ។

រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែតុលា ឆ្នាំ២០១៧

**ប្រធានក្រុមប្រឹក្សាជាតិភាសាខ្មែរ**

បណ្ឌិត **នៅ ស៊ុន**



Scanned with CamScanner

# I- កម្រងច្បាប់ទាក់ទងនឹង
# ក្រុមប្រឹក្សាជាតិភាសាខ្មែរ ( ក.ជ.ភ.ខ. )

# ព្រះរាជក្រឹត្យ

នស/រកត/០៤១៥/៩២៧

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៦១១/៦០០ ចុះថ្ងៃទី ២០ ខែមិថុនា ឆ្នាំ ២០១១ ស្តីពីការបង្កើតក្រុមប្រឹក្សាជាតិភាសាខ្មែរ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨១១/៧៧៦ ចុះថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១១ ស្តីពីការតែងតាំងសមាសភាពក្រុមប្រឹក្សាជាតិភាសាខ្មែរ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** ត្រូវបានតែងតាំងឧត្តមទីប្រឹក្សានៃក្រុមប្រឹក្សាជាតិភាសាខ្មែរ នៃទីស្តីការគណៈរដ្ឋមន្ត្រី បន្ថែមលើមុខតំណែងបច្ចុប្បន្ន :

១- សម្តេចព្រះអគ្គមហាសង្ឃរាជាធិបតី **តេព វង្ស** សម្តេចព្រះមហាសង្ឃរាជនៃព្រះរាជាណាចក្រកម្ពុជា

២-ព្រះឃោសធម្ម **ញៀម សុគ័ន្ធ្រ** ព្រះរាជាគណៈថ្នាក់ទោ, ព្រះបាឡាត់គណខេត្តកណ្តាល, ព្រះអនុគណក្រុងតាខ្មៅ, នាយកពុទ្ធិកវិទ្យាល័យ ប៊ុន រ៉ានី ហ៊ុន សែន ក្រពើហា ប្រធានផ្នែកពុទ្ធិកបឋមសិក្សា និងធម្មវិន័យនៃអគ្គាធិការដ្ឋានរបស់ក្រសួងធម្មការ និងសាសនា និងជាព្រះចៅអធិការវត្តប្រជុំនទី ហៅក្រពើហា។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

មាត្រា២ : ត្រូវបានតែងតាំងសមាជិកនៃក្រុមប្រឹក្សាជាតិភាសាខ្មែរ នៃទីស្តីការគណៈរដ្ឋមន្ត្រី បន្ថែមលើមុខតំណែងបច្ចុប្បន្ន :

| | |
|---|---|
| ១- លោកបណ្ឌិត **នេង វណ្ណារិទ្ធ** | អនុប្រធានវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម នៃរាជបណ្ឌិត្យសភាកម្ពុជា |
| ២- លោកបណ្ឌិត **ឈុំ តិតលន់** | អតីតព្រឹទ្ធបុរសមហាវិទ្យាល័យវិទ្យាសាស្ត្រ និងវេជ្ជសាស្ត្រសត្វ នៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម |
| ៣- លោកបណ្ឌិត **ចាន់ ម៉ុន្នី** | លេខាអចិន្ត្រៃយ៍នៃវិទ្យាស្ថានជីវសាស្ត្រ វេជ្ជសាស្ត្រ និងកសិកម្ម នៃរាជបណ្ឌិត្យសភាកម្ពុជា |
| ៤- លោក **អែម ឧត្តម** | ព្រឹទ្ធបុរសរងពុទ្ធិកមហាវិទ្យាល័យបាលី-សំស្ក្រឹតនិងភាសាបរទេស នៃពុទ្ធិកសាកលវិទ្យាល័យ ព្រះសីហនុរាជ ។ |

មាត្រា៣ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ២៩ ខែសីហា ឆ្នាំ ២០១៥*

**ក្នុងព្រះបរមនាម និងតាមព្រះរាជបញ្ជាដ៏ខ្ពង់ខ្ពស់បន្ទាប់**

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា និងព្រះរាជលញ្ឆករ**

**សម្តេចវិបុលសេនាភក្តី សាយ ឈុំ**

នស/រកត.០៨១៥.៩៣៧

លេខ: ៩៤០ ស.ណ

**សំណៅចែលមានតម្លៃជាការចែកផ្សាយ**

រាជធានីភ្នំពេញ ,ថ្ងៃទី ០១ ខែកញ្ញា ឆ្នាំ២០១៥

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

ក្រុមប្រឹក្សាជាតិភាសាខ្មែរ
ចូល
មកដល់ថ្ងៃ ...02/02/16
ម៉ោង 10h30'
លេខ 022/16

# ព្រះរាជក្រឹត្យ

នស/រកត/០១១៦/០៧០

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានត្ថមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៦១១/៦០០ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១១ ស្តីពីការបង្កើតក្រុមប្រឹក្សាជាតិភាសាខ្មែរ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨១១/៧៧៦ ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១១ ស្តីពីការតែងតាំងសមាសភាពក្រុមប្រឹក្សាជាតិភាសាខ្មែរ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១** : តែងតាំងសមាសភាពនៃក្រុមប្រឹក្សាជាតិភាសាខ្មែរ ៖

១- ឯកឧត្តមបណ្ឌិតសភាចារ្យ **ឡុំ ម៉ាល់** ប្រធានក្រុមប្រឹក្សាជាតិភាសាខ្មែរ ជាទីប្រឹក្សាជាន់ខ្ពស់

២- ឯកឧត្តមបណ្ឌិត **ច័ន្ទ សំណព្វ** អនុប្រធានក្រុមប្រឹក្សាជាតិភាសាខ្មែរ ជាប្រធាន

៣- ឯកឧត្តម **សូ មុយឃៀង** អនុប្រធានក្រុមប្រឹក្សាជាតិភាសាខ្មែរ ជាអនុប្រធានអចិន្ត្រៃយ៍ ។

**មាត្រា២** : សមាសភាពដទៃនៃក្រុមប្រឹក្សាជាតិភាសាខ្មែរ ដែលត្រូវបានតែងតាំងឬកែសម្រួលមុនថ្ងៃទី២០ ខែមករា ឆ្នាំ២០១៦ ត្រូវរក្សាទុកដដែល។

**មាត្រា៣** : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

៣៩៧.១៦០១.០៧៦

ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១៦

លេខៈ ៧៧ ស.ណ

សំណៅដែលមានតម្លៃជាការចែកផ្សាយ

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ មករា ឆ្នាំ២០១៦

អគ្គលេខាធិការរាជរដ្ឋាភិបាល

សយ សុខា

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៦/៦៦៦

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពោធិតាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៦១១/៦០០ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១១ ស្តីពីការបង្កើតក្រុមប្រឹក្សាជាតិភាសាខ្មែរ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨១១/៧៧៦ ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១១ ស្តីពីការតែងតាំងសមាសភាពក្រុមប្រឹក្សាជាតិភាសាខ្មែរ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** តែងតាំងអនុប្រធានប្រចាំការ និងសមាជិកនៃក្រុមប្រឹក្សាជាតិភាសាខ្មែរ បន្ថែមលើមុខតំណែងបច្ចុប្បន្ន ៖

| | | |
|---|---|---|
| ១- ឯកឧត្តម **ច័ន្ទ មេត្តាពល** | សមាជិកគណៈកម្មការភាសាវិទ្យាខ្មែរនៃទីស្តីការគណៈរដ្ឋមន្ត្រី | ជាអនុប្រធានប្រចាំការ មានឋានៈស្មើរដ្ឋលេខាធិការ |
| ២- ឯកឧត្តមបណ្ឌិត **ជា ពៅ** | ទីប្រឹក្សាអមទីស្តីការគណៈរដ្ឋមន្ត្រី | ជាសមាជិក |
| ៣- ឯកឧត្តមបណ្ឌិត **សឹង ពេត** | ទីប្រឹក្សាឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី | ជាសមាជិក |

៤- ឯកឧត្តមបណ្ឌិត **ឡឹក បូផា** ទីប្រឹក្សារាជបណ្ឌិត្យសភាកម្ពុជា ជាសមាជិក
៥- ឯកឧត្តម **ហាក់ សឺងលី** ទីប្រឹក្សាក្រសួងអប់រំ យុវជន និងកីឡា ជាសមាជិក
៦- ឯកឧត្តម **ហ៊ីង គីមថន** ទីប្រឹក្សារាជបណ្ឌិត្យសភាកម្ពុជា ជាសមាជិក
៧- ឯកឧត្តម **ស៊ឹម សៀងប៉ាង** ជំនួយការរាជបណ្ឌិត្យសភាកម្ពុជា ជាសមាជិក
៨- ឯកឧត្តមឧត្តមសេនីយ៍ឯក **ម៉ម សំ** អត្តលេខ ០០២៥១២ ជាសមាជិក
៩- ឯកឧត្តមឧត្តមសេនីយ៍ទោ **អឿ សាម៉ន** អត្តលេខ ០០៩៤៧៥ ជាសមាជិក
១០- លោក **ឡាក់ ឡេង** ជាសមាជិក
១១- លោក **ហ៊ែវ គីមី** ជាសមាជិក
១២- លោកស្រី **ហង់ ថាវី** ជាសមាជិក
១៣- លោក **ហេង នីវ៉ាដូ** ជាសមាជិក

**មាត្រា២ :** តែងតាំងទីប្រឹក្សាជាន់ខ្ពស់ និងទីប្រឹក្សានៃក្រុមប្រឹក្សាជាតិភាសាខ្មែរ បន្ថែមលើមុខតំណែងបច្ចុប្បន្ន ៖

១- ឯកឧត្តមបណ្ឌិតសភាចារ្យ **ស៊ន សំណាង** ទីប្រឹក្សារាជរដ្ឋាភិបាល ជាទីប្រឹក្សាជាន់ខ្ពស់
២- លោកជំទាវ **ហ៊ែវ សុជាតិយ** ជាទីប្រឹក្សាជាន់ខ្ពស់
៣- ព្រះមង្គលបញ្ញា **សៅរ៍ តារាវី** ព្រះរាជាគណៈ ថ្នាក់កិត្តិយស ជាទីប្រឹក្សា
៤- ព្រះបវរមុនី **ឈិត សុផៃ** ព្រះរាជាគណៈថ្នាក់កិត្តិយស ជាទីប្រឹក្សា

**មាត្រា៣ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

នស/រកត.១៦០៦.៦៧៣

លេខៈ ៦៤៥ ស.ណ

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១៦*

សំណៅដែលមានតម្លៃជាការចែកផ្សាយ
រាជធានីភ្នំពេញ .ថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ២០១៦
អគ្គលេខាធិការរាជរដ្ឋាភិបាល

សយ សុខា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី

លេខ....៣៩...សសរ

# សេចក្តីសម្រេច
## ស្តីពី
## ការផ្ទេរសមាជិក ការបញ្ឈប់ពីសមាជិក និង ការតែងតាំងសមាជិកបន្ថែម ក្នុងគណៈកម្មការបច្ចេកទេសមួយចំនួននៃក្រុមប្រឹក្សាជាតិភាសាខ្មែរ

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦១១/៦០០ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១១ ស្តីពីការបង្កើតក្រុមប្រឹក្សាជាតិភាសាខ្មែរ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨១១/៧៧៦ ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១១ ស្តីពីការតែងតាំងសមាសភាពក្រុមប្រឹក្សាជាតិភាសាខ្មែរ
- បានឃើញអនុក្រឹត្យលេខ ១៣៨ អនក្រ.បក ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិភាសាខ្មែរ
- បានឃើញសេចក្តីសម្រេចលេខ ៦៥ សសរ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១១ ស្តីពីការបង្កើតគណៈកម្មការបច្ចេកទេសនៃក្រុមប្រឹក្សាជាតិភាសាខ្មែរ
- បានឃើញសេចក្តីសម្រេចលេខ ៥៦ សសរ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១២ ស្តីពីការតែងតាំងសមាជិកបន្ថែម ការតែងតាំងជំនួស ការផ្ទេរ និង ការលាឈប់ ក្នុងគណៈកម្មការបច្ចេកទេសនៃក្រុមប្រឹក្សាជាតិភាសាខ្មែរ
- បានឃើញសេចក្តីសម្រេចលេខ ០២ សសរ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៤ ស្តីពីការផ្ទេរសមាជិក ការលាឈប់ពីសមាជិកភាព និង ការតែងតាំងសមាជិក នៃគណៈកម្មការបច្ចេកទេសនៃក្រុមប្រឹក្សាជាតិភាសាខ្មែរ
- យោងតាមសំណើរបស់ប្រធានក្រុមប្រឹក្សាជាតិភាសាខ្មែរ

## សម្រេច

**ប្រការ១.-**

ត្រូវបានផ្ទេរលោក **គីម ឌុន្នី** ពីសមាជិកនៃគណៈកម្មការវិទ្យាសាស្ត្រសេដ្ឋកិច្ចទៅគណៈកម្មការវប្បធម៌។

**ប្រការ២.-**

ត្រូវបានបញ្ឈប់ពីសមាជិកនៃគណៈកម្មការបច្ចេកទេសកសិកម្ម ដូចមានរាយនាមខាងក្រោម៖

១- ឯកឧត្តមបណ្ឌិត **សាមុ អ្នហ្សាណា**
២- លោកបណ្ឌិត **ម៉ែន សារុំម**
៣- លោកបណ្ឌិត **សួន សុធឿន**

**ប្រការ៣.-**

ត្រូវបានតែងតាំងសមាជិកបន្ថែមក្នុងគណៈកម្មការបច្ចេកទេសមួយចំនួន ដូចមានរាយនាមខាងក្រោម៖

១- ឯកឧត្តម **ចោ គឿន** អគ្គលេខាធិការរងនៃក្រុមប្រឹក្សាជាតិភាសាខ្មែរ ជាសមាជិកនៃគណៈកម្មការ**អក្ខរាវិរុទ្ធនិងអំណាន**

២- លោក **ហោង ទីរិទ្ធិ** មន្ត្រីវិទ្យាស្ថានជីវសាស្ត្រ វេជ្ជសាស្ត្រ និង កសិកម្មនៃរាជបណ្ឌិត្យសភាកម្ពុជា ជាសមាជិកនៃគណៈកម្មការ**កសិកម្ម**

៣- លោក **មិន សុផានិត** អនុប្រធាននាយកដ្ឋានបណ្តុះបណ្តាលនៃអគ្គនាយកដ្ឋានរដ្ឋបាលក្រសួងមហាផ្ទៃ ជាសមាជិកនៃគណៈកម្មការ**កសិកម្ម**

៤- លោក **ឌុក ឆេង** មន្ត្រីការិយាល័យការងារសង្គមនៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម ជាសមាជិកនៃគណៈកម្មការ**កសិកម្ម**

៥- លោក **សុខ ចំណាន** មន្ត្រីវិទ្យាស្ថានទំនាក់ទំនងអន្តរជាតិនៃរាជបណ្ឌិត្យសភាកម្ពុជា ជាសមាជិកនៃគណៈកម្មការ**ប្រវត្តិវិទ្យា**

៦- លោក **កែវ លីណែត** មន្ត្រីវិទ្យាស្ថានភាសាជាតិនៃរាជបណ្ឌិត្យសភាកម្ពុជា ជាសមាជិកនៃគណៈកម្មការ**ភាសាវិទ្យា**

៧- លោក **ហឿង សុធារស់** មន្ត្រីវិទ្យាស្ថានវប្បធម៌និងវិចិត្រសិល្បៈនៃរាជបណ្ឌិត្យសភាកម្ពុជា ជាសមាជិកនៃគណៈកម្មការ**វប្បធម៌**

៨- លោក **លី ទីន** អនុប្រធាននាយកដ្ឋានវិញ្ញាបនបត្រកម្មនៃក្រសួងឧស្សាហកម្ម និង សិប្បកម្ម ជាសមាជិកនៃគណៈកម្មការ**វិទ្យាសាស្ត្រនិងបច្ចេកវិទ្យា**

៩- លោកបណ្ឌិត **កា ម៉ាធុល** មន្ត្រីវិទ្យាស្ថានទំនាក់ទំនងអន្តរជាតិនៃរាជបណ្ឌិត្យសភាកម្ពុជា ជាសមាជិកនៃគណៈកម្មការ**វិទ្យាសាស្ត្រនយោបាយ**

១០- លោក **សេ អឿន** ប្រធានផ្នែកបោះពុម្ព ផ្សព្វផ្សាយ និង បណ្តុះបណ្តាលនៃអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិភាសាខ្មែរ ជាជំនួយខាងភាសានៃគណៈកម្មការ**វិទ្យាសាស្ត្រនយោបាយ**

១១- លោកបណ្ឌិត **គី សេរីវឌ្ឍន៍** មន្ត្រីវិទ្យាស្ថានទំនាក់ទំនងអន្តរជាតិនៃរាជបណ្ឌិត្យសភាកម្ពុជា ជាសមាជិកនៃគណៈកម្មការ**វិទ្យាសាស្ត្រសេដ្ឋកិច្ច**

១២- លោក **វ៉ាន់ ម៉ុន** មន្ត្រីវិទ្យាស្ថានភាសាជាតិនៃរាជបណ្ឌិត្យសភាកម្ពុជា ជាសមាជិកនៃគណៈកម្មការ**អក្ខរាវិរុទ្ធនិងអំណាន**។

**ប្រការ៤.-**

អគ្គលេខាធិការរាជរដ្ឋាភិបាល ប្រធានក្រុមប្រឹក្សាជាតិភាសាខ្មែរ ប្រធាននាយកដ្ឋានរដ្ឋបាល ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានផ្គត់ផ្គង់និងហិរញ្ញកិច្ច និង សាមីខ្លួន ដូចមានចែងក្នុងប្រការ១ ប្រការ២ និង ប្រការ៣ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែ ០៩ ឆ្នាំ២០១៥

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**សុខ អាន**

**កន្លែងទទួល :**
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រសួងមហាផ្ទៃ
- ក្រសួងឧស្សាហកម្ម និង សិប្បកម្ម
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- រាជបណ្ឌិត្យសភាកម្ពុជា
- សាកលវិទ្យាល័យភូមិន្ទកសិកម្ម
- ដូចប្រការ៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្តីការគណៈរដ្ឋមន្ត្រី**
**លេខ**...១៥...ស.ស.រ

# សេចក្តីសម្រេច
# ស្តីពី
# ការតែងតាំងសមាសភាពនៃគណៈកម្មការបច្ចេកទេស និងការតែងតាំងមន្ត្រីជំនួយការក្នុងអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិភាសាខ្មែរ

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និង បំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦១១/៦០០ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១១ ស្តីពីការបង្កើតក្រុមប្រឹក្សាជាតិភាសាខ្មែរ
- បានឃើញអនុក្រឹត្យលេខ១៣៨ អនក្រ.បក ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិភាសាខ្មែរ

- បានឃើញសេចក្តីសម្រេចលេខ៦៥ សសរ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១១ ស្តីពីការបង្កើតគណៈកម្មការបច្ចេកទេសនៃក្រុមប្រឹក្សាជាតិភាសាខ្មែរ
- បានឃើញសេចក្តីសម្រេចលេខ៧៦ សសរ ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១១ ស្តីពីការរៀបចំក្រុមមន្ត្រីជំនួយការក្នុងអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិភាសាខ្មែរ
- យោងតាមសំណើរបស់ប្រធានក្រុមប្រឹក្សាជាតិភាសាខ្មែរ

## សម្រេច

**ប្រការ១.-**

ត្រូវបានតែងតាំងសមាសភាពគណៈកម្មការបច្ចេកទេសនៃក្រុមប្រឹក្សាជាតិភាសាខ្មែរ ដូចខាងក្រោម៖

១- ឯកឧត្តមបណ្ឌិត **ហ៊ាន សាហ៊ីប** ប្រធានគណៈកម្មការវិទ្យាសាស្ត្រសេដ្ឋកិច្ច ជាទីប្រឹក្សាគណៈកម្មការវិទ្យាសាស្ត្រសេដ្ឋកិច្ច

២- លោកស្រីបណ្ឌិត **ថ្រាំ ទេវី** អនុប្រធានគណៈកម្មការវិទ្យាសាស្ត្រសេដ្ឋកិច្ច ជាប្រធានគណៈកម្មការវិទ្យាសាស្ត្រសេដ្ឋកិច្ច

៣- ឯកឧត្តមបណ្ឌិត **ស៊ុន សុត** អនុប្រធានគណៈកម្មការកសិកម្ម ជាប្រធានគណៈកម្មការកសិកម្ម ជំនួសឯកឧត្តមបណ្ឌិតសភាចារ្យ ជា ណេង ដែលបានទទួលមរណភាព

៤- លោកបណ្ឌិត **ម៉ុខ ស៊ាខឌីម** សមាជិកគណៈកម្មការកសិកម្ម ជាអនុប្រធានគណៈកម្មការកសិកម្ម

៥- លោកស្រីបណ្ឌិត **ហ៊ាន សុទ្ធនា** មន្ត្រីស្រាវជ្រាវនៃវិទ្យាស្ថានជីវសាស្ត្រ វេជ្ជសាស្ត្រ និងកសិកម្មនៃរាជបណ្ឌិត្យសភាកម្ពុជា ជាសមាជិកគណៈកម្មការកសិកម្ម

៦- លោកស្រី **ហាច់ លក្ខិណា** អនុប្រធានផ្នែករដ្ឋបាល បុគ្គលិក និងហិរញ្ញវត្ថុនៃអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិភាសាខ្មែរ ជាសមាជិកគណៈកម្មការភូមិវិទ្យា

៧- លោក **ម៉ាន់ សុខញា** មន្ត្រីវិទ្យាស្ថានជីវសាស្ត្រ វេជ្ជសាស្ត្រ និងកសិកម្ម នៃរាជបណ្ឌិត្យសភាកម្ពុជា ជាសមាជិកគណៈកម្មការសុខាភិបាល

៨- លោកស្រី **តិប ស៊ីណា** មន្ត្រីវិទ្យាស្ថានភាសាជាតិនៃរាជបណ្ឌិត្យសភាកម្ពុជា ជាសមាជិកគណៈកម្មការភូមិវិទ្យា

៩- កញ្ញា **ហេ ផល្លាសម្បត្តិ** សមាជិកគណៈកម្មការភាសាវិទ្យាខ្មែរនៃទីស្តីការគណៈរដ្ឋមន្ត្រី ជាសមាជិកគណៈកម្មការអក្ខរាវិរុទ្ធនិងអំណាន

១០- លោក **លាវ ផារុណា** មន្ត្រីស្រាវជ្រាវវិទ្យាស្ថានទំនាក់ទំនងអន្តរជាតិនៃរាជបណ្ឌិត្យសភាកម្ពុជា ជាសមាជិកគណៈកម្មការវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា

១១- លោក **យូ គន្ធា** មន្ត្រីស្រាវជ្រាវវិទ្យាស្ថានទំនាក់ទំនងអន្តរជាតិនៃរាជបណ្ឌិត្យសភាកម្ពុជា ជាសមាជិកគណៈកម្មការវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា

១២- លោក **ឈឹម ផាន់ណា** មន្ត្រីស្រាវជ្រាវវិទ្យាស្ថានទំនាក់ទំនងអន្តរជាតិនៃរាជបណ្ឌិត្យសភាកម្ពុជា ជាសមាជិកគណៈកម្មការបង្កើតពាក្យនិងកម្ពីពាក្យ។

**ប្រការ២.-**

ត្រូវបានតែងតាំងមន្ត្រីជំនួយការក្នុងអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិភាសាខ្មែរ ដូចខាងក្រោម៖

១-លោកបណ្ឌិត **លឹម សេងឌី** មន្ត្រីវិទ្យាស្ថានវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា នៃរាជបណ្ឌិត្យសភាកម្ពុជា ជាមន្ត្រីជំនួយការនៃផ្នែកបោះពុម្ព ផ្សព្វផ្សាយ និងបណ្តុះបណ្តាល

២- លោក **ឈាង ហៃយ៉ាម៉ា** ជាមន្ត្រីជំនួយការនៃផ្នែកបោះពុម្ព ផ្សព្វផ្សាយ និងបណ្តុះបណ្តាល

៣- កញ្ញា **ទិត ស៊ីណាត** ជាមន្ត្រីជំនួយការនៃផ្នែករដ្ឋបាល បុគ្គលិក និងហិរញ្ញវត្ថុ។

**ប្រការ៣.-**

អគ្គលេខាធិការរាជរដ្ឋាភិបាល ប្រធានក្រុមប្រឹក្សាជាតិភាសាខ្មែរ ប្រធាននាយកដ្ឋានរដ្ឋបាល ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានផ្គត់ផ្គង់និងហិរញ្ញកិច្ច និងសាមីខ្លួនដូចមានចែងក្នុងប្រការ១និងប្រការ២ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ ០៦ ឆ្នាំ២០១៦

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**សុខ អាន**

**កន្លែងទទួល :**

- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- រាជបណ្ឌិត្យសភាកម្ពុជា
- ដូចប្រការ៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី
លេខ ៣៩ សសរ

# សេចក្តីសម្រេច
# ស្តីពី
# ការតែងតាំងសមាជិកបន្ថែម និងការបញ្ចប់តំណែង ក្នុងគណៈកម្មការបច្ចេកទេសមួយចំនួន និងក្នុងអគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាជាតិភាសាខ្មែរ

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និង បំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦១១/៦០០ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១១ ស្តីពីការបង្កើតក្រុមប្រឹក្សាជាតិភាសាខ្មែរ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨១១/៧៧៦ ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១១ ស្តីពីការតែងតាំងសមាសភាពក្រុមប្រឹក្សាជាតិភាសាខ្មែរ
- បានឃើញអនុក្រឹត្យលេខ១៣៨ អនក្រ.បក ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិភាសាខ្មែរ
- បានឃើញសេចក្តីសម្រេចលេខ៦៥ សសរ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១១ ស្តីពីការបង្កើតគណៈកម្មការបច្ចេកទេសនៃក្រុមប្រឹក្សាជាតិភាសាខ្មែរ
- បានឃើញសេចក្តីសម្រេចលេខ៧៦ សសរ ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១១ ស្តីពីការរៀបចំក្រុមមន្ត្រីជំនួយការក្នុងអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិភាសាខ្មែរ
- យោងតាមសំណើរបស់ប្រធានក្រុមប្រឹក្សាជាតិភាសាខ្មែរ

## សម្រេច

**ប្រការ១.-**

ត្រូវបានតែងតាំងសមាជិកបន្ថែម :

១- លោកបណ្ឌិត **ហេង ហុកឡេន** មន្ត្រីផ្នែកបណ្តុះបណ្តាល និងស្រាវជ្រាវ នៃរាជបណ្ឌិត្យសភាកម្ពុជា ជាមន្ត្រីជំនួយការផ្នែកតាមដាននិងត្រួតពិនិត្យនៃអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិភាសាខ្មែរ។

២- លោក **ផង់ តិរុណា** មន្ត្រីវិទ្យាស្ថានភាសាជាតិនៃរាជបណ្ឌិត្យសភាកម្ពុជា ជាសមាជិកនៃគណៈកម្មការបង្កើតពាក្យនិងកម្ពីពាក្យ។

៣- លោក **ជួន សៅរិទ្ធី** អនុប្រធានផ្នែករដ្ឋបាល បុគ្គលិក និងហិរញ្ញវត្ថុ នៃអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិភាសាខ្មែរ ជាសមាជិកនៃគណៈកម្មការបង្កើតពាក្យនិងកម្ពីពាក្យ។

៤- លោក **អាត ឡៀង** មន្ត្រីស្រាវជ្រាវបណ្ដោះអាសន្ននៃវិទ្យាស្ថានមនុស្សសាស្ត្រ និងវិទ្យាសាស្ត្រសង្គម នៃរាជបណ្ឌិត្យសភាកម្ពុជា ជាសមាជិកគណៈ-កម្មការប្រវត្តិវិទ្យា។

៥- លោកស្រី **សំរិទ្ធ ទេពី** មន្ត្រីផ្នែករដ្ឋបាលនិងហិរញ្ញវត្ថុនៃរាជបណ្ឌិត្យសភាកម្ពុជា ជាមន្ត្រីជំនួយការផ្នែកតាមដាននិងត្រួតពិនិត្យ នៃអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិភាសាខ្មែរ។

**ប្រការ២.-**

ត្រូវបានបញ្ចប់តំណែងលោក **លៀម រ័ត្ន** ពីមន្ត្រីជំនួយការផ្នែករដ្ឋបាល បុគ្គលិក និងហិរញ្ញវត្ថុ នៃអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិភាសាខ្មែរ។

**ប្រការ៣.-**

អគ្គលេខាធិការរាជរដ្ឋាភិបាល ប្រធានរាជបណ្ឌិត្យសភាកម្ពុជា ប្រធានក្រុមប្រឹក្សាជាតិភាសាខ្មែរ ប្រធាននាយកដ្ឋានរដ្ឋបាល ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានផ្គត់ផ្គង់និងហិរញ្ញកិច្ច និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ និងប្រការ២ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី១៧ ខែ ០៣ ឆ្នាំ២០១៦

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**សុខ អាន**

**កន្លែងទទួល :**

- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# II- សមិទ្ធផល
# នៃក្រុមប្រឹក្សាជាតិភាសាខ្មែរ

## II.1- សិក្ខាសាលាស្ដីពី «ពិពិធភាពនៃភាសាខ្មែរ»



ចាប់ពីថ្ងៃទី១៥ ខែកញ្ញាដល់ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៦ នៅសាលប្រជុំរបស់រាជបណ្ឌិត្យសភាកម្ពុជា ក្រុមប្រឹក្សាជាតិភាសាខ្មែរ (ក.ជ.ភ.ខ.) បានរៀបចំសិក្ខាសាលាមួយ ស្ដីពី «**ពិពិធភាពនៃភាសាខ្មែរ**» ដែលមានអ្នកចូលរួមចំនួន៣០០នាក់ វាគ្មិនចំនួន៩រូបដែលមានវាគ្មិនបរទេសជាស្ត្រី១រូបនិងអ្នកសម្របសម្រួលចំនួន៤រូប។ អង្គសិក្ខាសាលាបានបើកឱ្យដំណើរដោយឯកឧត្តមបណ្ឌិត **ពិត ចំណាន** រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា តំណាងដ៏ខ្ពង់ខ្ពស់ឯកឧត្តមបណ្ឌិត **ហង់ ជួនណារ៉ុន** រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា។

បន្ទាប់ពីការអានរបាយការណ៍របស់ឯកឧត្តមបណ្ឌិត **សន ពៅ** អគ្គលេខាធិការនៃក.ជ.ភ.ខ. និង សុន្ទរកថាស្វាគមន៍របស់ឯកឧត្តមបណ្ឌិត **ច័ន្ទ សំណព្វ** ប្រធានក.ជ.ភ.ខ. រួចមក ឯកឧត្តម **ពិត ចំណាន** រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា តំណាងដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម **ហង់ ជួនណារ៉ុន** រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា បានថ្លែងសុន្ទរកថាបើកសិក្ខាសាលា ស្ដីពី «**ពិពិធភាពនៃភាសាខ្មែរ**» ជូនអង្គពិធីទាំងមូល។ នាឱកាសនោះ ឯកឧត្តមមានប្រសាសន៍ថា ខ្ញុំមានមោទនភាពយ៉ាងក្រៃលែង ដោយក.ជ.ភ.ខ.រៀបចំសិក្ខាសាលានេះឡើងក្នុងគោលបំណងរួមចំណែកក្នុងការអភិរក្សនិងអភិវឌ្ឍភាសាខ្មែរដែលមានទាំងការនិយាយ ការអាន ការសរសេរ ការបង្កើតពាក្យ ជាដើម ដើម្បីបន្តនូវនិរន្តរភាពនិងរក្សាបាននូវអត្តសញ្ញាណជាតិខ្មែរ ជាពិសេសការស្វែងរកស្តង់ដារួមមួយក្នុងការអនុវត្តសម្រាប់ភាសាខ្មែរទូទាំងប្រទេសកម្ពុជា។

សិក្ខាសាលានាពេលនេះ ក.ជ.ភ.ខ.ពិតជាទទួលបាននូវបទពិសោធន៍និងគំនិតថ្មីៗថែមទៀត ដើម្បីអនុវត្តតួនាទីដ៏សំខាន់របស់ខ្លួន និង ជួយដាស់ស្មារតី ជំរុញការយកចិត្តទុកដាក់បន្ថែមទៀតដល់ការប្រើប្រាស់ភាសាខ្មែរនៅលើបណ្ដាញសង្គម ប្រព័ន្ធព័ត៌មានអេឡិចត្រូនិក និងតាមប្រព័ន្ធផ្សព្វផ្សាយនានា មានសារព័ត៌មាន វិទ្យុ ទូរទស្សន៍ ជាដើម ព្រមទាំងការបង្រៀនភាសាខ្មែរផងដែរ។ ទន្ទឹមនឹងនេះ ក.ជ.ភ.ខ. ក៏ត្រូវកំណត់គោល

ការណ៍ដាក់លាក់លើការប្រើប្រាស់ភាសាខ្មែរ ជាពិសេស លើការកំណត់និយមន័យបច្ចេកសព្ទថ្មីៗទាំងឡាយ ក្បួនខ្នាតបង្កើតពាក្យ វិធីសរសេរ វិធីអាន ជាដើម ដើម្បីស្វែងរកឯកភាពមួយសម្រាប់ភាសាជាតិ។

ក្នុងឋានៈជារដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ខ្ញុំរីករាយនឹងធ្វើកិច្ចសហការនិងគាំទ្រជានិច្ចនូវគោលការណ៍ស្វែងរកឯកភាព អភិរក្ស និងអភិវឌ្ឍភាសាខ្មែររបស់ ក.ជ.ភ.ខ. ដោយក្រសួងអប់រំ យុវជន និងកីឡានឹងអនុវត្តតាមនូវគោលការណ៍នានារបស់ ក.ជ.ភ.ខ. ដែលបានអនុម័ត ដើម្បីបញ្ចូលក្នុងកម្មវិធីសិក្សានៅគ្រប់កម្រិតសិក្សា ជាពិសេស ការនិពន្ធ និងការបោះពុម្ពផ្សាយសៀវភៅសិក្សា ហើយក្រសួងអប់រំក៏ត្រូវការអ្នកជំនាញខាងអក្សរសាស្ត្រខ្មែរដែលមាននៅ ក.ជ.ភ.ខ. ចូលរួមជួយអភិវឌ្ឍកម្មវិធីសិក្សាភាសាខ្មែរនៅកម្រិតសិក្សាផងដែរ។

ខ្ញុំសង្ឃឹមថា វាគ្មិននិងអ្នកចូលរួមសិក្ខាសាលាថ្ងៃនេះ នឹងផ្តល់នូវរបកគំហើញថ្មីៗជាច្រើនដល់មហាជនខ្មែរ អ្នកស្រាវជ្រាវជាតិនិងអន្តរជាតិ ដើម្បីជាចំណេះដឹងបន្ថែមនិងជាទុនដ៏សំខាន់ សម្រាប់ការអភិរក្សនិងអភិវឌ្ឍភាសាខ្មែរនៅក្នុងព្រះរាជាណាចក្រកម្ពុជាយើង។

អង្គសិក្ខាសាលារយៈពេលពីរថ្ងៃនេះចែកចេញជា៤វគ្គ គឺថ្ងៃទីមួយពីរវគ្គ ពេលព្រឹកមួយវគ្គនិងពេលល្ងាចមួយវគ្គ មានវាគ្មិនចំនួន៥នាក់។ នៅថ្ងៃទីពីរមានពីរវគ្គ ពេលព្រឹកមួយវគ្គ និងពេលល្ងាចមួយវគ្គ មានវាគ្មិនចំនួន៤នាក់។

## ថ្ងៃទីមួយ វគ្គទីមួយៈ

**វាគ្មិនទីមួយ** ក្នុងប្រធានបទ «**ន័យនីយកម្ម**» ឯកឧត្តមបណ្ឌិត **ច័ន្ទ សំណព្វ** បានបង្ហាញថា ការសិក្សា ការរៀន ការសរសេរ ការសន្ទនា នៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃ គេត្រូវតែស្វែងយល់ដើម្បីឈ្វេងយល់ពីន័យនៃប្រធានបទដែលបានចោទឡើងចំពោះមុខ។ កិច្ចការសព្វមុខគេគិតពីន័យជាចម្បង សូម្បីវិទ្យាសាស្ត្រពិតដូចជា គណិតវិទ្យា ជាដើម ក៏ចាំបាច់យកន័យមកគិតជាមួយដែរ។ ឯកឧត្តមបណ្ឌិតបានលើកយកប្រភាគគ្មានន័យជាប្រភាគដែលមិនអាចធ្វើប្រមាណវិធីបាន។ រីឯជីវិតឥតន័យប្រៀបបានទៅនឹងស្លាប់ទាំងរស់។ អត្ថបទដែលមិនច្បាស់ន័យ កម្មវិធីសិក្សាដែលគ្មានន័យឬខុសន័យ មិនមែនគ្រាន់តែគ្មានប្រយោជន៍នោះទេ តែជាការបំផ្លាញបញ្ញាញាណរបស់អ្នកសិក្សាថែមទៀតផង។

នៅក្នុងបញ្ហាន័យដដែលនេះ វាគ្មិនបានលើកយក *ន័យនីយកម្ម ន័យ និយមន័យ អត្ថន័យ បំណកស្រាយន័យ និងសេចក្តីសន្និដ្ឋាន* មកបង្ហាញជូនអង្គសិក្ខាសាលា ដោយបានផ្តល់នូវចំណុចវិភាគដែលមានលក្ខណៈជាប្រព័ន្ធ ហើយធាតុចូលទាំងនេះជាកត្តាចម្បងនៃន័យនីយកម្ម ប្រកបដោយលក្ខណៈគរុសភានិងវិទ្យាសាស្ត្រ ដោយអាចយកទៅអនុវត្តជាក់ស្តែងបាន។

**វាគ្មិនទី២** លោកស្រី Wang Hailing បទបង្ហាញស្តីពី «**ស្ថានភាពទូទៅនៃការបង្រៀនភាសាខ្មែរនិងសិក្សាស្រាវជ្រាវអំពីខ្មែរនៅប្រទេសចិន**»។ ខ្លឹមសារនៃបទបង្ហាញនេះ លោកស្រីបានសង្កត់ធ្ងន់ទៅលើការបើកបង្រៀននៃភាសាខ្មែរដំបូងបង្អស់នៅប្រទេសចិនក្នុងឆ្នាំ១៩៦៥ នៅសាកលវិទ្យាល័យប៉េកាំងក្នុងរយៈពេល៣៥ឆ្នាំក្រោយគ្មានសាកលវិទ្យាល័យណាបើកបង្រៀនភាសាខ្មែរទេ លុះមកដល់ឆ្នាំ២០០០ ទើបសាកលវិទ្យាល័យជនជាតិខេត្តក្វាងស៊ីជាសាកលវិទ្យាល័យទីពីរក្នុងប្រទេសចិនបានបើកបង្រៀនភាសាខ្មែរ។ បច្ចុប្បន្ន ដេប៉ាតឺម៉ង់ភាសាខ្មែរមានគ្រូបង្រៀនចំនួន៥នាក់ រួមទាំងគ្រូ *វេហាស៍* (Wang Hailing) ដែលកំពុងមកបន្តការសិក្សា

ថ្នាក់បណ្ឌិតភាសាវិទ្យានៅរាជបណ្ឌិត្យសភាកម្ពុជាផង។ រីឯនិស្សិតភាសាខ្មែរសរុបចំនួន៨០នាក់ ប៉ុន្មានថ្ងៃមុនអ្នកគ្រូបានបញ្ជូននិស្សិតភាសាខ្មែរឆ្នាំទី៣ ចំនួន២២នាក់មកចុះឈ្មោះរៀននៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។

លោកស្រីលើកឡើងថា នៅប្រទេសចិន សាកលវិទ្យាល័យដែលបានបើកបង្រៀនភាសាខ្មែរ រួមមាន រាជធានីប៉េកាំងមាន១សាលា ខេត្តក្វាងស៊ីមាន៣សាលា ខេត្តយូណានមាន៤សាលា និងសាលាមួយចំនួនកំពុងត្រៀមខ្លួនដើម្បីបើកបង្រៀនភាសាខ្មែរផងដែរ។

**ថ្ងៃទីមួយ វគ្គទីពីរៈ**

**វាគ្មិនទី១** លោក **ចែម វត្ត** បទបង្ហាញស្ដីពី «**ប្រព័ន្ធស្រៈក្នុងភាសាខ្មែរ**»ជាការសិក្សាបែបសូរវិទ្យាអាគូស្ទិកដែលមានចំណុចសំខាន់ដូចជា លទ្ធផលប្រេកង់មធ្យមនៃសូរសព្ទស្រៈ លទ្ធផលនៃរង្វាស់រយៈពេលនៃការបន្លឺសូរស្រៈ។ គោលបំណងនៃការស្រាវជ្រាវនេះ គឺចង់បង្ហាញពីតួលេខប្រេកង់ និង រយៈពេលនៃការបន្លឺសូរស្រៈនីមួយៗ រួចធ្វើការសិក្សាប្រៀបធៀបតាមវិធាននៃទីបន្លឺនិងគូអប្បបរិមានៃប្រព័ន្ធស្រៈក្នុងភាសាខ្មែរ។ វាគ្មិនបានបង្ហាញថា ក្នុងភាសាខ្មែរនៅមិនទាន់ឯកភាពគ្នាលើចំនួនសូរស្រៈនៅឡើយទេ។ ដូច្នេះការកំណត់ចំនួនស្រៈក្នុងភាសាខ្មែរជាការងារចាំបាច់និងសំខាន់បំផុតក្នុងការស្រាវជ្រាវរបស់ស្មេរ ដោយស្មេរបានជ្រើសរើសយកការចាត់ថ្នាក់និងការរាប់ចំនួនស្រៈរបស់លោកបណ្ឌិត ហ្សង់ មីសែលហ្វីលីពី និង លោក ហៀប ច័ន្ទវិចិត្រ ធ្វើជាមូលដ្ឋានក្នុងការកំណត់ចំនួនស្រៈក្នុងភាសាខ្មែរទំនើប។ ស្មេរបានរៀបចំវិភាគនិងចាត់ថ្នាក់ប្រព័ន្ធស្រៈទោលវែងនិងខ្លីទៅតាមវិធានសូរវិទ្យាអាគូស្ទិកនិងប្រព័ន្ធស្រៈនៃសូរវិទ្យាអន្តរជាតិ។

ក្នុងការបង្ហាញលទ្ធផលរង្វាស់ប្រេកង់មធ្យមនៃសូរសព្ទស្រៈ វាគ្មិនបានបង្ហាញពីប្រេកង់មធ្យមនៃស្រៈទោលវែង ប្រេកង់មធ្យមនៃស្រៈទោលខ្លី ប្រេកង់មធ្យមនៃស្រៈផ្សំពីរវែង និងប្រេកង់មធ្យមនៃស្រៈផ្សំពីរខ្លី ដោយមានក្រាហ្វដែលពិព័ណ៌នាអំពីទីតាំងអណ្ដាត លក្ខណៈនៃប្រហោងមាត់ និងរយៈពេលបន្លឺនៃសូរស្រៈ ដែលស្មេរបានគណនាចេញពីប្រេកង់នៃអ្នកនិយាយទាំងអស់។

**វាគ្មិនទី២** លោក Bayat Salee បទបង្ហាញស្ដីពី «**ការប្រើប្រាស់និងការទ្រទ្រង់គ្រាមភាសាខ្មែរនៅក្នុងបទចម្រៀងប្រជាប្រិយក្នុងខេត្តសុរិន្ទ**»។

វាគ្មិនបានលើកឡើងពីការប្រើប្រាស់គ្រាមភាសាខ្មែរនៅក្នុងបទចម្រៀងប្រជាប្រិយរបស់អ្នកស្រុកសុរិន្ទ ទាំងការប្រើភាសានិងការរៀបចំពាក្យពេចន៍នៅក្នុងបទចម្រៀង។ ការសិក្សារកឃើញថា ចម្រៀងប្រជាប្រិយនៅខេត្តសុរិន្ទមានពីរប្រភេទគឺ ទី១ ចម្រៀងដែលប្រគំក្នុងការកម្សាន្តនិងក្នុងពិធីកម្មជំនឿ ដូចជាការបំពេកូន ចូលមេមត់ សែនដូនតា និងត្រុដិ និងទី២ ចម្រៀងដែលប្រើក្នុងការសម្ដែងដូចជា របាំកន្ទ្រឹមនិងចម្រៀងឯទៀត។ ការប្រើភាសាខ្មែរក្នុងបទចម្រៀងនិងល្បែងប្រជាប្រិយរបស់ខ្មែរសុរិន្ទ ជាទូទៅ គេប្រើពាក្យមិនសុភាព ការប្រើពាក្យផ្ទួន ការប្រើពាក្យដែលបង្ហាញពីការប្រៀបធៀប និងប្រើពាក្យខ្មែរសុរិន្ទផ្សំនឹងភាសាថៃផងដែរ។ ក្រៅពីនេះនៅមានពាក្យពេចន៍ខ្មែរសុរិន្ទដែលជាមរតកក្នុងចម្រៀងប្រជាប្រិយដែលមានសំនៀងពាក្យនិងន័យរបស់ពាក្យ។ ពាក្យទាំងនោះអាចមានលក្ខណៈប្លែកពីភាសាខ្មែរកណ្ដាលឬខ្មែរបច្ចុប្បន្ន។ បច្ចុប្បន្ន ភាសាខ្មែរសុរិន្ទចាប់ផ្ដើមបាត់បង់បន្តិចម្ដងៗ។ វាគ្មិនបានបង្ហាញនូវការព្រួយបារម្ភពីការបាត់បង់ភាសាខ្មែរសុរិន្ទផងដែរ ហើយការអភិរក្សពាក្យខ្មែរសុរិន្ទគឺជាប្រការសំខាន់មួយ។ ក្មេងជំនាន់ក្រោយមិននិយមប្រើភាសាខ្មែរបែរជាចូលចិត្តនិយាយគ្នាជាភាសាថៃ។ សព្វថ្ងៃការអភិរក្សភាសាខ្មែរសុរិន្ទមាននៅតែតាមរយៈបទចម្រៀងខ្មែរសុរិន្ទតែប៉ុណ្ណោះ។

**វាគ្មិនទី៣** ឯកឧត្តម **សូ មុយឃៀង** ប្រធានបទស្តីពី «**ខេមរយានកម្ម**» លោកបានបង្ហាញថាគណៈកម្មាធិការជាតិអចិន្ត្រៃយ៍នៃខេមរយានកម្មសិក្សាត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៦៧ ក្រោមការគ្រប់គ្រងរបស់ក្រសួងអប់រំជាតិ។ ខេមរយានកម្មសិក្សាបាននិពន្ធសៀវភៅសិក្សាគ្រប់មុខវិជ្ជាសម្រាប់មធ្យមសិក្សាពីថ្នាក់ទី៦ដល់ថ្នាក់ទីបញ្ចប់(ពីឆ្នាំ១៩៦៧ដល់ឆ្នាំ១៩៧៤)។ គេអាចចែកសម័យខេមរយានកម្មពីឆ្នាំ១៩៦៧ដល់ឆ្នាំ១៩៧៥ជាពីរដំណាក់កាលគឺ ដំណាក់កាលទី១ ពីឆ្នាំ១៩៦៧ដល់ឆ្នាំ១៩៧២ អនុម័តពាក្យគន្លឹះផ្អែកលើគោលការណ៍បកឱ្យមកជាខ្មែរ បកឱ្យងាយប្រើ បកឱ្យស៊ីនឹងទម្លាប់ បកឱ្យមានឯកភាព មិនបកពាក្យអន្តរជាតិ និង ដំណាក់កាលទី២ ពីឆ្នាំ១៩៧២ដល់ឆ្នាំ១៩៧៥ បង្កើតគណៈកម្មការបច្ចេកទេស(គណិតវិទ្យា រូបវិទ្យា គីមីវិទ្យា ធម្មជាតិវិទ្យា ប្រវត្តិវិទ្យា ភូមិវិទ្យា អក្សរសាស្រ្ត ទស្សនវិជ្ជា ពេងជាង កសិកម្ម ...) ដោយប្រជុំអនុម័តបីដងក្នុងមួយសប្តាហ៍ ហើយលទ្ធផលរបស់អង្គប្រជុំយកទៅថ្វាយសម្តេចព្រះសង្ឃរាជ ហួត តាត ទ្រង់ឡាយព្រះហស្តលេខាសម្រេចឱ្យផ្សាយប្រើជាផ្លូវការ។

**ថ្ងៃទីពីរ វគ្គទីមួយៈ**

**វាគ្មិនទី១** លោកបណ្ឌិត **វង្ស មេង** បង្ហាញពីប្រធានបទ «**ការសិក្សាបច្ចេកសព្ទពិធីអាពាហ៍ពិពាហ៍ក្នុងភាសាខ្មែរ**»។ វាគ្មិនលើកពីប្រជាពលរដ្ឋខ្មែរសម័យបុរាណបានឱ្យតម្លៃពិធីមង្គលការគឺជារឿងសំខាន់ពីព្រោះភាគច្រើនយល់ថា មនុស្សម្នាក់អាចរៀបការបានតែម្តង ក៏ប៉ុន្តែបច្ចុប្បន្ន ការយល់បែបនេះមានការប្រែប្រួល ដែលជាទូទៅ យើងសង្កេតឃើញថាពួកគាត់អាចរៀបការបានលើកទីពីរ លើកទីបី ឬច្រើនជាងនេះ។ នៅក្នុងការសិក្សានេះ វាគ្មិនមិនផ្អែកលើទម្រង់ឬរបៀបរបបនៃការរៀបចំឬដំណើរការនៃអាពាហ៍ពិពាហ៍នោះទេ ការសិក្សានៅទីនេះផ្អែកទៅលើអត្ថន័យនៃបច្ចេកសព្ទអាពាហ៍ពិពាហ៍ដោយមានទិន្នន័យចំនួន១០៤ពាក្យ។ ចំពោះទិន្នន័យទាំងនោះ លោកប្រមូលបានមកពីក្បួនអាពាហ៍ពិពាហ៍ដោយលោក ញ៉ុក នូវ បោះពុម្ពឆ្នាំ១៩៦៥ កម្រងឯកសារស្តីពីតួនាទីភារកិច្ចអាចារ្យក្នុងការរៀបចំពិធីមង្គលការ និងពិធីបុណ្យផ្សេងៗក្នុងព្រះពុទ្ធសាសនារបស់ក្រសួងធម្មការចងក្រងដោយ មិន ឃិន, ញាណ គឿន និង វ៉ាយ វិបុល បោះពុម្ពឆ្នាំ២០១០ និងសៀវភៅដំណើរជីវិតមនុស្សខ្មែរមើលតាមពិធីឆ្លងវ័យដោយ អាំង ជូលាន, ព្រាប ចាន់ម៉ារ៉ា និង ស៊ុន ចាន់ដឹប បោះពុម្ពឆ្នាំ២០០៧។

កិច្ចការស្រាវជ្រាវនេះ មានគោលបំណងសំខាន់៣គឺ ទី១ ពិភាក្សាលើទ្រឹស្តីពាក់ព័ន្ធ និងបច្ចេកសព្ទដែលបានរៀបចំ, ទី២ ពិចារណាទៅលើទំនាក់ទំនងរវាងន័យនិងនិយមន័យ, និងទី៣ សង្កត់ទៅលើទិដ្ឋភាពន័យផ្សារភ្ជាប់ទៅនឹងការងារអនុវត្តតាមគន្លងប្រពៃណីជាក់ស្តែងនៅក្នុងសង្គម។

**វាគ្មិនទី២** លោក **វ៉ាន់ ម៉ូន** បង្ហាញពីប្រធានបទ «**បញ្ហាមួយចំនួនខាងសម្ព័ន្ធក្នុងភាសាខ្មែរបច្ចុប្បន្ន**» វាគ្មិនបានលើកយកបញ្ហាមួយចំនួនដែលបណ្តាញព័ត៌មានឬស្នេរមួយចំនួនប្រើប្រាស់ពុំទាន់ត្រឹមត្រូវតាមសម្ព័ន្ធល្បះក្នុងភាសាខ្មែរ មានពីរចំណុចគឺៈ

**១- បញ្ហាទាក់ទងនឹងសម្ព័ន្ធ ប្រធាននិងកិរិយាសព្ទនៅក្នុងល្បះ**

ការប្រើប្រាស់ប្រធាននិងកិរិយាសព្ទនៅក្នុងសម្ព័ន្ធល្បះមិនត្រឹមត្រូវ គឺជាការធ្វេសប្រហែសនៅក្នុងសង្គមបច្ចុប្បន្នដែលបានបណ្តាលឱ្យមានកន្សោមធ្លាក់ជាប្រធានរបស់កិរិយាសព្ទ។ លោកបានដកស្រង់កំហុសក្នុងការប្រើប្រាស់មិនត្រឹមត្រូវមួយចំនួនមកបង្ហាញអង្គសិក្ខាសាលា។

**២- បញ្ហានៃការប្រើសម្ព័ន្ធ «កម្មវាចកៈ»**

វាគ្មិនបានលើកឡើងថា ក្នុងភាសាខ្មែរបច្ចុប្បន្នហាក់ទទួលស្គាល់ទម្រង់មួយដែលមានប្រើពាក្យ «*ត្រូវបាន*»។ គេសង្កេតឃើញមានការប្រើសម្ព័ន្ធល្បះ «កម្មវាចកៈ» ជាញឹកញាប់ក្នុងអត្ថបទសារព័ត៌មានបច្ចុប្បន្ន ដោយហេតុថា តាមរយៈកម្មវាចកៈ គេបង្ហាញការចាប់អារម្មណ៍ទៅលើប្រធានរបស់ល្បះដែលជា អ្នករងអំពើតាមតក្កភាពជាជាងកម្មក្នាក់ងារ ដែលជាអ្នកធ្វើអំពើតាមតក្កភាព។ គេអាចបង្កើត «កម្មវាចកៈ» ពី «កត្តុវាចកៈ» ដោយការយកកម្មបទរបស់ «កត្តុវាចកៈ»មកធ្វើជាប្រធានរបស់ «កម្មវាចកៈ»។ ឧទាហរណ៍ គេអាចបង្កើត«កម្មវាចកៈ» ពីល្បះ «កត្តុវាចកៈ» *លោក នូ ហាច និពន្ធរឿងផ្កាស្រពោន។* ដែលមានប្រធានជា «លោក នូ ហាច», កិរិយាសព្ទជា «និពន្ធ» និង កម្មបទជា «រឿងផ្កាស្រពោន» បានដោយគ្រាន់តែយកកម្មបទមកធ្វើជាប្រធាន ហើយបន្ថែមពាក្យ «ត្រូវបាន» មុនកិរិយាសព្ទបង្គោលជា *រឿងផ្កាស្រពោនត្រូវបាននិពន្ធដោយលោក នូ ហាច។*

កាលណាគេប្រើសម្ព័ន្ធល្បះ «កម្មវាចកៈ» គេត្រូវចងចាំថា កិរិយាសព្ទនៃ ល្បះនោះគឺជា *កិរិយាសព្ទសកម្ម* ពីព្រោះកិរិយាសកម្មនេះត្រូវការកម្មបទនៅក្នុង «កត្តុវាចកៈ» ហើយ កម្មបទនេះហើយដែលគេយកមកធ្វើជាប្រធាននៅក្នុង «កម្មវាចកៈ»។

**វាគ្មិនទី៣** លោក **ទូច គីមស្រ៊ាង** បទបង្ហាញស្ដីពី «**បម្រើបម្រាស់កិរិយាសព្ទ គុណសព្ទ និងនាមសព្ទបាលី សំស្ក្រឹតក្នុងភាសាខ្មែរ**»។ វាគ្មិនបានលើកឡើងថា ក្នុងការសិក្សាស្រាវជ្រាវ ការរៀន ការបង្រៀន ការសរសេរ ការនិពន្ធ គេតែងតែសង្កេតឃើញសំណេរអក្ខរាវិរុទ្ធខ្មែរយើងនៅមានចំណុចខ្លះៗថា ការប្រើប្រាស់កិរិយាសព្ទ គុណសព្ទ នាមសព្ទ បាលី សំស្ក្រឹតក្នុងភាសាខ្មែរយើងនៅខ្វះចន្លោះមិនទាន់បានត្រឹមត្រូវតាមបែបបទវេយ្យាករណ៍ទាំងស្រុងនោះទេ។ វាគ្មិនលើកយកពាក្យមួយមកបង្ហាញបញ្ជាក់ហេតុផលជាគោលពិចារណា។

**ថ្ងៃទីពីរ វគ្គទីពីរៈ**

លោក **ជុំ ស៊ុនណាង** មន្ត្រីវិទ្យាស្ថានភាសាជាតិបន្តការសិក្សាថ្នាក់បណ្ឌិតនៅសាកលវិទ្យាល័យមហាសារខាំប្រទេសថៃ បទបង្ហាញស្ដីពី «**បន្លែករវាងភាសាខ្មែរកណ្ដាលនិងភាសាខ្មែរលើ**»។ វាគ្មិនបានពិនិត្យទៅលើបន្លែករវាងភាសាខ្មែរកណ្ដាល(ប្រទេសកម្ពុជា)ទៅនឹងភាសាខ្មែរក្នុងខេត្តសុរិន្ទ(ប្រទេសថៃ) ដោយពិចារណាលើទិដ្ឋភាពខ្លះនៃសូរ រូប និងន័យរបស់ពាក្យក្នុងបរិបទឃ្លា ល្បះផ្អែកលើទិន្នន័យវាក្យសព្ទមូលដ្ឋានចំនួន៣៤០ពាក្យ ព្រមជាមួយឃ្លាល្បះដែលប្រមូលបានពីអ្នកប្រើប្រាស់ភាសាខ្មែរនៅខេត្តសុរិន្ទ។ លទ្ធផលនៃការសិក្សារបស់វាគ្មិនបានបង្ហាញថា ភាសាខ្មែរកណ្ដាលនិងភាសាខ្មែរសុរិន្ទមានលក្ខណៈដូចគ្នាច្រើន តែក៏មានលក្ខណៈប្លែកគ្នាមួយចំនួនផងដែរ។

វាគ្មិនបានបញ្ជាក់ថា ព្យញ្ជនៈមួយចំនួនក្នុងភាសាខ្មែរសុរិន្ទនិងភាសាខ្មែរកណ្ដាលមានបន្លែកមួយចំនួនទាំងនៅក្នុងទីតាំងដើមព្យាង្គនិងទីតាំងចុងព្យាង្គ ជាពិសេសភាសាខ្មែរសុរិន្ទនៅរក្សាធម្មតាភាពនៃព្យញ្ជនៈសិថិលបានច្រើនជាងភាសាខ្មែរកណ្ដាល។ ពាក្យមួយចំនួនមានចំនួនជាតុនៃព្យាង្គនិងចំនួនព្យាង្គមិនត្រូវគ្នា។ ន័យរបស់ពាក្យមួយចំនួនមិនត្រូវគ្នាក្នុងបរិបទនៃការប្រើប្រាស់ក្នុងឃ្លាល្បះ។ លើសពីនេះ វាគ្មិនក៏បានបង្ហាញឱ្យឃើញថា ភាសាខ្មែរក្នុងខេត្តសុរិន្ទបច្ចុប្បន្នបានទទួលឥទ្ធិពលច្រើនពីភាសាថៃនិងភាសាឡាវ ទាំងផ្នែកវាក្យសព្ទនិងផ្នែកសម្ព័ន្ធផងដែរ។

ឆ្លងតាមការពិភាក្សា សំណួរ ចម្លើយ រវាងសមាជិក សមាជិកាអង្គសិក្ខាសាលា និងវាគ្មិន ក្នុងរយៈពេលថ្ងៃនេះ អង្គសិក្ខាសាលាយើងបានទទួលនូវអនុសាសន៍មួយចំនួន ដូចតទៅៈ

១- ក.ជ.ភ.ខ.ត្រូវបង្កើតយន្តការត្រួតពិនិត្យអក្សរនៅលើផ្លាកសញ្ញាពាណិជ្ជកម្មនានាដែលដាក់តាំងនៅតាមផ្ទះ ហាង ក្រុមហ៊ុន ដងផ្លូវសាធារណៈ ជាដើម។

២- សូមឱ្យបង្កើតគណៈកម្មការត្រួតពិនិត្យរាល់ការបោះពុម្ពផ្សាយនូវឯកសារទាំងឡាយដែលបម្រុងបោះពុម្ពផ្សាយជាសាធារណៈ

៣- ក.ជ.ភ.ខ. គួរតែបើកវគ្គខ្លីៗបង្រៀនពីរបៀបប្រើប្រាស់ភាសាខ្មែរឱ្យបានត្រឹមត្រូវនៅតាមប្រព័ន្ធផ្សព្វផ្សាយមានវិទ្យុ ទូរទស្សន៍ ឬបណ្ដាញផ្សេងទៀត ជាពិសេស ពិធីករ ពិធីការិនីឱ្យយល់ពីភាសាខ្មែរ។

៤- សិក្ខាសាលាដែលទាក់ទងនឹងការប្រើប្រាស់ភាសាខ្មែរលើកក្រោយ ក.ជ.ភ.ខ. និង ក្រសួងអបរំ យុវជន និងកីឡា គួររួមសហការគ្នាអញ្ជើញលោកគ្រូ អ្នកគ្រូបង្រៀនភាសាខ្មែរនៅតាមបណ្ដាខេត្ត ក្រុង  និងរាជធានីចូលរួមឱ្យបានច្រើនឬបើកវគ្គបណ្ដុះបណ្ដាលបំប៉នភាសាខ្មែរដល់ពួកគាត់។

៥- ស្នើសុំឱ្យក.ជ.ភ.ខ.សហការរៀបចំវេទិកាអក្សរសាស្ត្រប្រចាំឆ្នាំជាមួយនឹងក្រសួងអប់រំ យុវជន និងកីឡា និងរាជបណ្ឌិត្យសភាកម្ពុជា។

៦- ក.ជ.ភ.ខ. គួរផ្សព្វផ្សាយនិងបញ្ជ្រាបនូវសមិទ្ធផលដែលបានសម្រេចរួចហើយដល់មហាជនឱ្យបានទូលំទូលាយបន្ថែមទៀត តាមប្រព័ន្ធផ្សព្វផ្សាយនានា។

៧- គួរមានកម្មវិធីកុំព្យូទ័រៈ
- សម្រាប់ត្រួតពិនិត្យអក្ខរាវិរុទ្ធខ្មែរក្នុងកម្មវិធី word
- បកប្រែពីភាសាអង់គ្លេសឬបារាំងមកជាភាសាខ្មែរ
- បង្កើតប្រព័ន្ធកត់ត្រាឈ្មោះអសាធារណនាមពីភាសាខ្មែរទៅជាឡាតាំង
- បញ្ចូលតួអក្សរខ្មែរដែលខ្វះទៅក្នុងប្រព័ន្ធ Unicode។
- បង្កើតវចនានុក្រម(Talking Dictionary) សម្រាប់ភាសាខ្មែរ ជាពិសេស ដើម្បីសម្រួលដល់ការសិក្សារបស់ជនពិការ។

៨- ស្នើឱ្យមានកម្មវិធីសិក្ខាសាលាបែបនេះឱ្យបានច្រើន ដើម្បីឱ្យមានការផ្លាស់ប្ដូរការស្រាវជ្រាវរវាងខ្មែរ-ចិន ក៏ដូចជាជនជាតិដទៃទៀត។

៩- ស្នើឱ្យមានសមាគមមួយរវាងគ្រូបង្រៀនបរទេសដែលបង្រៀនភាសាខ្មែរនិងគ្រូខ្មែរដែលបង្រៀនភាសាខ្មែរ។

១០- ស្នើសុំឱ្យបង្កើតពាក្យថ្មីដើម្បីបកប្រែពាក្យខ្ចីពីភាសាបរទេសដែលកំពុងតែចូលមកក្នុងភាសាខ្មែរឱ្យទាន់ពេលវេលា។

១១- ស្នើសុំឱ្យមានការពង្រីកការសិក្សារៀនសូត្រ ការស្រាវជ្រាវភាសាខ្មែរឱ្យមានការរីកចម្រើនដូចអារ្យភាសា។

១២- គួរមានកម្មវិធីភាសាវិទ្យានិងអក្សរសាស្ត្រច្រើនថែមទៀតតាមទូរទស្សន៍ដើម្បីផ្សព្វផ្សាយឱ្យបានទូលំទូលាយដល់សាធារណជនពីសកម្មភាពរបស់ក្រុមប្រឹក្សាជាតិភាសាខ្មែរនិងការបកស្រាយពាក្យខ្មែរណាដែលមានបញ្ហាចម្រូងចម្រាស។

អង្គសិក្ខាសាលាបានបិទនៅវេលាល្ងាចថ្ងៃទី២ គឺថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៦ ក្រោមអធិបតីភាពរបស់ឯកឧត្តមបណ្ឌិត **ច័ន្ទ សំណព្វ** ប្រធានក្រុមប្រឹក្សាជាតិភាសាខ្មែរ។

ឯកឧត្តមបណ្ឌិតបានថ្លែងនៅក្នុងឱកាសបិទអង្គសិក្ខាសាលានេះថា ក្នុងរយៈពេលពីរថ្ងៃនេះ អង្គសិក្ខា-សាលាបានទទួលនូវលទ្ធផលយ៉ាងល្អប្រសើរដោយវាគ្មិនជាតិនិងអន្តរជាតិ ព្រមទាំងអ្នកចូលរួមទាំងអស់បានចែករំលែកបទពិសោធនៃការសិក្សាស្រាវជ្រាវនិងបង្រៀនភាសាខ្មែររបស់ពួកគាត់យ៉ាងផុលផុស ដែលនាំមកនូវធាតុចូលថ្មីៗជាច្រើន មានជាអាទិ៍ ន័យនីយកម្ម ដែលរំលេចពីសញ្ញាណបញ្ញត្តិនៃបច្ចេកសព្ទ ប្រព័ន្ធគំនិត ជំហរ និងន័យនៃប្រធានបទស្រាវជ្រាវប្រកបដោយលក្ខណៈគុសភានិងវិទ្យាសាស្ត្រ ហើយដែលមានសារៈសំខាន់ក្នុងការអនុវត្តការងារស្រាវជ្រាវនិងការប្រាស្រ័យទាក់ទងគ្នាប្រចាំថ្ងៃ។

ទន្ទឹមនឹងនេះ ទិដ្ឋភាពនៃការអភិរក្សភាសាខ្មែរនៅក្នុងប្រទេសមានសន្ទុះគួរឲ្យកត់សំគាល់ និងកាន់តែមានមោទនភាពថែមទៀតចំពោះកិច្ចខិតខំប្រឹងនៃប្រទេសជាមិត្ត ជាពិសេស បងប្អូនខ្មែរសុរិន្ទក្នុងការរក្សាបាននូវអត្តសញ្ញាណភាសាខ្មែរនិងវប្បធម៌របស់ខ្លួន។ ព្រមពេលជាមួយគ្នានេះ ទាំងកម្ពុជា ទាំងប្រទេសជាមិត្ត មានជាអាទិ៍ ថៃនិងចិន បានរួមគ្នាពង្រីកដែនអភិរក្សនិងអភិវឌ្ឍភាសានិងអក្សរសាស្ត្រខ្មែរដោយបានបើកបង្រៀនភាសាខ្មែរដល់ជនបរទេសនៅតាមសាកលវិទ្យាល័យជាតិរបស់ខ្លួន។ ក្នុងក្របខណ្ឌនេះ ក្រុមប្រឹក្សាជាតិភាសាខ្មែរក្នុងកិច្ចសហការជាមួយវិទ្យាស្ថានជាតិភាសាខ្មែរនៃរាជបណ្ឌិត្យសភាកម្ពុជា គួរពិចារណាសម្រេចអនុម័តបមាណីយជាតិស្តីពីកម្មវិធីនិងវិធីសាស្ត្របង្រៀនភាសាខ្មែរជាអន្តរជាតិ ដើម្បីបង្កើតបានជាក្របខណ្ឌគោលមួយដែលអនុញ្ញាតឲ្យជនបរទេសដែលរៀនភាសាខ្មែរទទួលបាននូវសមមូលភាពនៃកម្រិតចំណេះដឹងខាងផ្នែកភាសានិងវប្បធម៌ខ្មែរ។

ឯកឧត្តមបណ្ឌិតបានសម្តែងការជឿជាក់ថា សិក្ខាសាលាស្តីពីពិធភាពនៃភាសាខ្មែរនេះពិតជាវេទិកាវិទ្យា-សាស្ត្រជាតិមួយដ៏មានសារៈសំខាន់ក្នុងការពិភាក្សា ចែករំលែកបទពិសោធនៃការសិក្សាស្រាវជ្រាវ និងផ្តល់នូវដំណោះស្រាយចំពោះបញ្ហាដែលចោទមានឡើងក្នុងផ្នែកភាសានិងអក្សរសាស្ត្រខ្មែរ។

ជាទីបញ្ចប់ ឯកឧត្តមបណ្ឌិតគណៈអធិបតីបានកោតសរសើរដោយស្មោះនិងវាយតម្លៃខ្ពស់ចំពោះលទ្ធផលដែលទទួលបានពីអង្គសិក្ខាសាលានេះ ហើយគាំទ្រឲ្យមានកិច្ចសហការជាមួយស្ថាប័នពាក់ព័ន្ធនានា ពិសេសក្រសួងអប់រំ យុវជន និងកីឡា ក្នុងការរៀបចំសិក្ខាសាលាស្តីពីពិធភាពនៃភាសាខ្មែរនេះនៅឆ្នាំក្រោយនិងឆ្នាំបន្តបន្ទាប់ទៀត និងសូមអញ្ជើញលោកគ្រូ អ្នកគ្រូ ដែលបង្រៀនភាសាខ្មែរនៅតាមខេត្តនានានៃព្រះរាជាណាចក្រកម្ពុជានិងនៅបរទេសឲ្យមកចូលរួមធ្វើបទបង្ហាញនិងចែករំលែកបទពិសោធឲ្យកាន់តែច្រើនថែមទៀត។

## II.២- បច្ចេកសព្ទ អក្ខរាវិរុទ្ធ និងអំណាន អនុម័តដោយ ក.ជ.ត.ខ.

### II.២.១- បច្ចេកសព្ទស្នើដោយគណៈកម្មការវប្បធម៌

| | |
|---|---|
| ១- ទូក-ង | យានតាមផ្លូវទឹកមួយប្រភេទមានទទឹងខ្លីមិនដល់ពីរម៉ែត្រ និង មានបណ្ដោយវែងរវាងពីម្ភៃទៅសាមសិបម៉ែត្រ ធ្វើពីឈើដោយផ្គុំឡើងពីមាឌទូក (លុងពីឈើគគីរមួយដើម) ក្បាលរំពេ ទងកន្ត្រៃ កុងទូក ខ្នង់ ខ្សែពុង... មានកន្សៃងើបខ្ពស់ ងឡើងព្រមទាំងគូរក្បាច់រចនាវិចិត្រផ្សេងៗលើផ្ទៃទូកខាងក្រៅ។ ទូក-ងច្រើនមានឈ្មោះទាក់ទងនឹងអមនុស្សដែលគេជឿថាមានឫទ្ធិតេជៈនាំឱ្យមានសេចក្ដីសុខ និង ជោគជ័យឬមានឈ្មោះទាក់ទងនឹងស្ថាននាម វត្ថុ សត្វបាតុភូតផ្សេងៗ។<br>បច្ចុប្បន្នឈ្មោះទូក-ងមានទាក់ទងនឹងនរនាមទៀតផង។ ទូក-ងប្រើសម្រាប់អុំឬចែវប្រណាំងក្នុងពិធីបុណ្យអុំទូក បណ្ដែតប្រទីប សំពះព្រះខែ អកអំបុក ឬបុណ្យភ្ជុំបិណ្ឌ និង ពិធីបុណ្យចេញវស្សា ជាដើម។ ប្រសិនបើទូកងប្រើចែវគេហៅថាទូកម្ដង។ ជាទូទៅ គេរក្សាទូកងទុកនៅតាមវត្តអារាម។<br>ឧ. ជម្ពូពានមានឫទ្ធិ, ខ្លាចុះភ្នំ, ផ្គរលាន់, សារាយអណ្ដែត, សរព្រះរាម, សម្បូណ៌មានជ័យ, ស្រីខ្មៅក្រាំងយ៉ូវ, រន្ទះពេជ្រក្ដាមប្រែ។ |
| ២- មាឌទូក-ង | ផ្នែកនៃទូក-ងធ្វើពីការលុងឈើគគីរមួយដើមនៅចន្លោះទងកន្ត្រៃខាងក្បាល និងទងកន្ត្រៃខាងកន្សៃ តែបើទូក-ងណាមិនមានទងកន្ត្រៃ មាឌទូក-ងនោះនៅចន្លោះក្បាលរំពេខាងក្បាលនិងក្បាលរំពេខាងកន្សៃ។<br> |
| ៣- ពោះទូក-ង | ផ្នែកកណ្ដាលនៃមាឌទូក-ងមានក្អេងធំជាងគេ។ |
| ៤- ទងកន្ត្រៃទូក-ង | ផ្នែកតំណនៃទូក-ងធ្វើពីឈើមួយកំណាត់ដែលគេលុងភ្ជាប់រវាងមាឌទូក-ង ជាមួយនឹងក្បាលរំពេ។ ទងកន្ត្រៃទូក-ងមាននៅខាងក្បាលនិងកន្សៃទូក។ |
| ៥- ក្បាលរំពេទូក-ង | ផ្នែកខាងចុងបំផុតនៃក្បាលនិងកន្សៃទូក-ងធ្វើពីឈើតាន់មួយកំណាត់ ដែលតភ្ជាប់ទៅនឹងទងកន្ត្រៃទូក-ង តែបើទូក-ងណាមិនមានទងកន្ត្រៃ ក្បាលរំពេនោះតភ្ជាប់ទៅនឹងមាឌទូក-ងតែម្ដង។ |

| | |
|---|---|
| ៦- ក្បាលទូក-ង | ផ្នែកខាងមុខនៃទូក-ង ដែលងឡើងបន្តិច ខ្ពស់ជាងគែមទូក ផ្គុំពីទងកន្ទ្រេនិងក្បាលរំពេ។ |
| ៧- កន្សៃទូក-ង | ផ្នែកខាងក្រោយ(កន្ទុយ)នៃទូក-ង ដែលងឡើងខ្ពស់ជាងក្បាលទូក ផ្គុំពីទងកន្ទ្រេនិងក្បាលរំពេ។ |
| ៨- ស្រឡោកោទូក-ង | ក្ដារសន្ទះគ្របគ្រង់កទូក-ងខាងក្បាលនិងខាងកន្សៃ ប្រើសម្រាប់ដាក់តង្វាយ។ លើសពីនេះទៀត ស្រឡោកោខាងក្បាលទូក-ង ប្រើសម្រាប់ឱ្យអ្នកបញ្ជាទូកយកដងច្រវាអុក បន្លឺសំឡេងជាសញ្ញាបញ្ជាដល់អ្នកអុំឬអ្នកចែវ។ គេនិយមប្រើឈើសំរោងធ្វើជាស្រឡោកោទូក-ង ព្រោះគេយល់ថា ជាឈើមានអមនុស្សនៅថែរក្សា នាំឱ្យទូកមានឫទ្ធិតេជះ។ |
| ៩- ក្ដារសៃមទូក-ង | ក្ដារភ្ជាប់បន្ថែមពីលើគែមសងខាងនៃទូក-ងដើម្បីឱ្យទូកមានគែមខ្ពស់និងជួយតភ្ជាប់ទងកន្ទ្រេនឹងមាឧទូកឱ្យជាប់មាំ។ អ្នកខ្លះហៅក្ដារសៃមទូក-ងនេះថា ក្ដារគែម ក្ដារស៊ីវ ក្ដារសោប ក្ដារកោប ក្ដារជើងក្រាប ក្ដារបង្ក្រាប ក្ដារឡើង...។ គេនិយមប្រើឈើស្រឡៅ ធ្វើជាក្ដារសៃមទូក-ង ព្រោះវាស្រាល។ |
| ១០- ខ្ទង់ទូក-ង | ឈើខណ្ឌទទឹងទូក-ងប្រើសម្រាប់អ្នកអុំអង្គុយឬលុតជង្គង់ និង ទប់មាត់ទូកឱ្យរឹងមាំ មិនឱ្យរីករួម ហើយ ក៏បង្ហាញពីចំណុះទូកផងដែរ។ ប្រសិនបើជាទូកចែវ គេជាប់ដាក់ជើងចែវទាំងសងខាងលើខ្ទង់ទូក។ |
| ១១- ខ្ទង់ព្រៃ | កំណាត់ឈើខណ្ឌទទឹងទូក-ង ប្រើបណ្ដោះអាសន្ន សម្រាប់ទុលទប់ទទឹងមាត់ទូកនៅពេលគេកម្ដៅបើកសាច់ទូកក្នុងដំណាក់កាលធ្វើទូកដើម្បីកុំឱ្យមាត់ទូករួមតូចវិញនៅពេលត្រជាក់ ព្រោះដំណាក់កាលនេះ ទូកមិនទាន់ភ្ជាប់កុងទូកនៅឡើយ។ |
| ១២- កុងទូក | កំណាត់ឈើដែលចាំងឱ្យកោងភ្ជាប់ទទឹងមាឧទូកពីខាងក្នុងសម្រាប់ទប់និងពង្រឹងមាឧទូកឱ្យមាំ។ កុងទូកមានពីរប្រភេទ គឺកុងបាតនិងកុងឃ្នួ។ |
| ១៣- កុងបាត | កំណាត់ឈើដែលគេចាំងឱ្យកោងភ្ជាប់ទទឹងបាតទូក ដើម្បីទប់និងពង្រឹងមាឧទូក។ |
| ១៤- កុងឃ្នួ | កំណាត់ឈើដែលគេចាំងឱ្យកោងវាយទាមភ្ជាប់មាឧទូកនិងក្ដារសៃមឱ្យជាប់មាំល្អ។ |
| ១៥- ខ្សែពុងទូក-ង | ខ្សែផ្ដៅឬ(បច្ចុប្បន្ន)ខ្សែកាបភ្ជាប់ទទឹងអែបស្របនឹងខ្ទង់ទូកងដើម្បីរឹតមាឧទូក ឱ្យកាន់តែមាំ។ ខ្សែពុងប្រើស្ទើរគ្រប់ខ្ទង់ទូក ដែលអ្នកខ្លះហៅថា ខ្សែល្បួត ខ្សែតម្លេច ឬ ខ្សែបន្តឹង។ |
| ១៦- ភ្នែកទូក-ង | ឈើឆ្លាក់ជារូបភ្នែកសម្រាប់ភ្ជាប់នៅផ្នែកចំហៀងសងខាងនៃក្បាលទូក ហើយអាចដោះចេញបាន។ ចំពោះទូក-ងខ្លះ គេគូររូបភ្នែកនៅផ្នែកចំហៀងសងខាងនៃក្បាលទូកតែម្ដង។ |

| | |
|---|---|
| **១៧- ណាទូក-ង** | គ្រឿងលម្អធ្វើពីកំណាត់សំពត់ប៉ាក់ឌិន អង្កាំ ភ្ជាប់ដោយកញ្ចក់ ជាដើម សម្រាប់ ដាក់ព្យួរនៅនឹងក្បាលរំពៃនៃក្បាលទូកនិងកន្សៃនៃទូក-ង។ |
| **១៨- ចន្ទល់ទូក-ង** | កំណាត់ឈើខ្លីប្រើសម្រាប់ទល់ពីកុងបាតទៅខ្ទង់ខ្លះនៃទូក-ងដើម្បីជួយពង្រឹងតួទូក។ ចន្ទល់ទូក-ងនេះ ត្រូវគេដាក់ឬវាយឱ្យរបូតចេញដើម្បីឱ្យល្បឿនទូកស្ទុះលឿនជាងមុន នៅពេលជិតដល់ទីផ្តាច់ព្រ័ត្រ។<br> |
| **១៩- ការធ្វើរម្ងរកន្ទេល** | ការធ្វើទូក-ង ដោយយកឈើមួយដើមមកចាំងឱ្យចេញជារាងមូល។ |
| **២០- បន្សាក់ទូក-ង** | រន្ធដែលគេស្វានពីខាងក្រៅជាច្រើនសម្រាប់ស្លង់កំណាត់កម្រាស់សាច់មាឌទូក-ង នៅពេលគេលុង។ |
| **២១- ស្នូលបន្សាក់ទូក-ង** | ស្នូលឬស្សីឬឈើសម្រាប់ស្លង់បន្សាក់ទូក-ង។ |
| **២២- បំពាំងទូក-ង** | បិទភ្ជិតមុខតំណក្តារស៊ែមនិងមាឌទូកមិនឱ្យជ្រាបទឹក ដោយប្រើអំបោះឆៅ ឬសរសៃបាវក្រចៅលាយការជ័រទឹក។ បំពាំងទូក-ងនេះ គេហៅម្យ៉ាងទៀតថា បិទមាត់នៀវ។ |
| **២៣- ពរទូក-ង** | លាបលើផ្ទៃទូក-ងដោយជ័រទឹកនិងជ័រចុងដើម្បីការពារការជ្រាបទឹក។ |
| **២៤- ចំណុះទូក-ង** | ចំនួនអ្នកអុំឬអ្នកចែវដែលផ្ទុកនៅក្នុងទូក-ង។ |
| **២៥- ខ្ទង់ក្បាលទូក-ង / ខ្ទង់អ្នកក្បាលទូក-ង** | ខ្ទង់ទី១នៃទូក-ង នៅមុខគេបង្អស់សម្រាប់អ្នកបញ្ជាទូកម្នាក់អង្គុយបញ្ជាការអុំ។ |
| **២៦- ខ្ទង់ស្នាឯកទូក-ង** | ខ្ទង់ទី២នៃទូក-ង នៅបន្ទាប់ពីខ្ទង់ក្បាលសម្រាប់អ្នកអុំម្នាក់អង្គុយអុំ។ |
| **២៧- ខ្ទង់ស្នាទីមទូក-ង** | ខ្ទង់ទី៣និងខ្ទង់ទី៤នៃទូក-ងនៅបន្តបន្ទាប់ខ្ទង់ស្នាឯកសម្រាប់អ្នកអុំពីរៗនាក់អង្គុយអុំ។ |
| **២៨- ខ្ទង់អុំរាបទូក-ង** | ខ្ទង់ទូក-ងបន្តបន្ទាប់ដែលនៅចន្លោះខ្ទង់ស្នាទីមនិងខ្ទង់ប្រាំជានសម្រាប់អ្នកអុំអង្គុយអុំពីរៗនាក់លើខ្ទង់នីមួយៗ។ |
| **២៩- ទ្រនះ** | ឧបករណ៍ធ្វើពីកំណាត់ឈើឬឫស្សី ប្រើសម្រាប់វាយទះដុំដីល្បាយឱ្យចេញជារាងក្អម ឆ្នាំង ថ្លាង ខ្វាង ឃ្លុះ ផើង ឪទិន ក្រឡ ពាង ជាដើម។ ទ្រនះមានច្រើនប្រភេទនិងច្រើនសណ្ឋាន ដូចជា ទ្រនះដំ ទ្រនះក ទ្រនះខិត ជាដើម។ |

| | |
|---|---|
| | នៅតំបន់ខ្លះ គេហៅ ស្លឹក-ក ឬ ល្អ។  |
| ៣០- ទ្រនះធំ | ឧបករណ៍ធ្វើពីកំណាត់ឈើសំប៉ែតធំជាងទ្រនះផ្សេងទៀត ខាងតូចសម្រាប់កាន់ ខាងធំសម្រាប់ទះ ប្រើសម្រាប់វាយទះដុំដីល្បាយឱ្យចេញជារាងក្អែង និងភ្ជិតបាតក្នុងការផលិត ក្អម ឆ្នាំង ថ្លាង ខ្វាង ឃ្លះ ផើង ឪទិន ក្រឡ ពាង ជាដើម។  |
| ៣១- ទ្រនះក | ឧបករណ៍ធ្វើពីកំណាត់ឈើរាងមូលទ្រវែង ហើយ តូចជាងទ្រនះផ្សេងទៀត ប្រើសម្រាប់វាយទះដុំដីល្បាយ ចាប់ឱ្យចេញរាងកក្អម កឆ្នាំង កថ្លាង កខ្វាង កឃ្លះ មាត់ផើង ឪទិន ក្រឡ ពាង ជាដើម។  |
| ៣២- ទ្រនល់ | ឧបករណ៍ធ្វើពីដីដុតរាងមូលកំប៉ោង ស្រដៀងនឹងឃ្លោកសាជៀវ ទាលផ្នែកខាងមុខ និង ម្ខាងទៀតស្ដួចសម្រាប់កាន់ ប្រើសម្រាប់ទប់ពីខាងក្នុង នៅពេលវាយ ទះ ដោយទ្រនះពីខាងក្រៅដើម្បីឱ្យចេញជារាងក្អមឬឆ្នាំង...។ អ្នកស្រុកកំពង់ឆ្នាំងនិងកំពង់ស្ពឺហៅថា "កិល" អ្នកស្រុកព្រៃវែង ហៅថា "តានិល"។ តាមឯកសារខ្លះហៅថា ក្លឹង។  |

| | |
|---|---|
| **៣៣- ខ្នួត** | ឧបករណ៍ធ្វើពីកំណាត់ឈើឬឫស្សីរាងទ្រវែងពាក់កណ្តាលស៊ីឡាំង ប្រើសម្រាប់កួតសម្អាតត្រង់ក និង ក្អេងនៃផ្ទៃខាងក្រៅក្អម ផ្ទាំង ថ្លាង ខ្ទាង ឃ្លះ... មុននឹងសាក់ក្បាច់។ អ្នកស្រុកខ្លះហៅថា ឈើជីកខ្នួត។  |
| **៣៤- ឈើសាក់** | ឧបករណ៍ធ្វើពីកំណាត់ឈើឬឫស្សីរាងសំប៉ែត ម្ខាងមានរាងរៀវនិងម្ខាងទៀតរាងដូចផ្លែសម ប្រើសម្រាប់សាក់ក្បាច់លើផ្ទៃខាងក្រៅក្អម ផ្ទាំង ថ្លាង ខ្ទាង ឃ្លះជាដើម។  |
| **៣៥- ខ្នង់ប្រាំធានទូក-ង** | ខ្នង់បន្តបន្ទាប់នៅផ្នែកកណ្តាលនៃទូក-ង ដែលនៅចន្លោះខ្នង់អុំរាបនិងខ្នង់យោងរាប សម្រាប់អ្នកអុំអង្គុយអុំពីរៗនាក់លើខ្នង់នីមួយៗ។ ដើម្បីបង្កើនល្បឿនទូកតាមអ្នកបញ្ជាទូក អ្នកអុំនៅខ្នង់ប្រាំធាននេះត្រូវងើបឈរដោយពិតជង្គង់ម្ខាងនឹងខ្នង់ទូក ឬ ងើបឈរពេញជំហរដើម្បីអុំ។ |
| **៣៦- ខ្នង់យោងរាប ទូក-ង** | ខ្នង់បន្តបន្ទាប់នៃទូក-ង ដែលនៅចន្លោះខ្នង់ប្រាំធាននិងខ្នង់យោងលយ សម្រាប់អ្នកអុំពីរៗនាក់លើខ្នង់នីមួយៗពិតជង្គង់ម្ខាងនឹងខ្នង់ទូកដើម្បីអុំ។ |
| **៣៧- ខ្នង់យោងលយ ទូក-ង** | ខ្នង់បន្តបន្ទាប់នៃទូក-ង ដែលនៅចន្លោះខ្នង់យោងរាបនិងខ្នង់យោងទឹម សម្រាប់អ្នកអុំឈរអុំពីរៗនាក់លើខ្នង់នីមួយៗ។ |
| **៣៨- ខ្នង់យោងទឹម ទូក-ង** | ខ្នង់បន្តបន្ទាប់នៃទូក-ង ដែលនៅចន្លោះខ្នង់យោងលយនិងខ្នង់កន្សៃ សម្រាប់អ្នកអុំឈរអុំនិងជួយអ្នកកន្សៃទូកក្នុងការតម្រង់ទិសទូក។ |
| **៣៩- ខ្នង់កន្សៃ ទូក-ង** | ខ្នង់នៅផ្នែកខាងក្រោយគេបង្អស់នៃទូក-ង សម្រាប់អ្នកអុំម្នាក់តម្រង់ទិសទូក។ |
| **៤០- ទ្រនះខាត់** | ឧបករណ៍ធ្វើពីកំណាត់ឫស្សី រាងសំប៉ែតតូច ប្រើសម្រាប់ខាត់សម្អាតរំលីងកម្ទេចកំទីដីលើក្បាច់នៃក្អេងផ្ទាំង ក្អម...។ អ្នកស្រុកនៅក្នុងតំបន់ខ្លះហៅថា ទ្រនះខិត។  |

| | |
|---|---|
| **៤១- ជន្លាយ** | ឧបករណ៍ធ្វើពីកំណាត់ឈើឬឫស្សី រាងសំប៉ែតទ្រវែងដែលម្ខាងមានពុម្ពក្បាច់ និងម្ខាងទៀតមានដៃសម្រាប់កាន់ ប្រើសម្រាប់វាយទះឱ្យចេញជាក្បាច់លើផ្ទៃខាងក្រៅក្អម ឆ្នាំង...។  |
| **៤២- អន្ទោក** | ឧបករណ៍ផលិតក្អម ឆ្នាំង... ដែលមានផែនពីរ (ថាសខាងលើមួយនិងជុំយោងខាងក្រោមមួយ) មានឈ្នាន់សម្រាប់ជាក់បង្វិល មានប៉ាដាង... ប្រើសម្រាប់បង្វិលដុំដីល្បាយដើម្បីឱ្យស្មូនចាប់ជារាងក្អម ឆ្នាំង...។  |
| **៤៣- ដីស្អិត** | ដីម៉ដ្ឋទន់ល្អិត សម្រាប់ធ្វើ ក្អម ឆ្នាំង... ។ ដីស្អិតអាចមាននៅតាមវាលស្រែនិងនៅ តាមភ្នំផងដែរ។ នៅតំបន់ខ្លះ គេហៅថា ដីឥដ្ឋ ឬ ដីក្អម។ |
| **៤៤- ដីស្អាត** | ដីគ្រើម មានជាតិស្អិតតិច ដែលប្រើលាយបញ្ចូលជាមួយដីស្អិតឱ្យទៅជាដីល្បាយសម្រាប់ធ្វើ ក្អម ឆ្នាំង... ដើម្បីការពារនឹងការប្រេះបែកនៅពេលដុត។ ជាទូទៅ ដី ស្អាតមានតែនៅតាមភ្នំខ្លះប៉ុណ្ណោះ។ អ្នកស្រុកនៅខេត្តកំពង់ឆ្នាំង ហៅថា ដីស្អាត។ |
| **៤៥- ថ្មពុក** | ថ្មផុយ គ្រសុស មានធាតុដី តែគ្មានជាតិស្អិត ដែលប្រើលាយបញ្ចូលជាមួយ ដីស្អិតឱ្យទៅជាដីល្បាយ សម្រាប់ធ្វើ ក្អម ឆ្នាំង... ដើម្បីការពារនឹងការប្រេះបែកនៅពេលដុត។ ជាទូទៅ ថ្មពុកមានតែនៅតាមភ្នំខ្លះប៉ុណ្ណោះ។ អ្នកស្រុកនៅខេត្តកំពង់ស្ពឺ តាកែវ ជាដើម ហៅថា ថ្មពុក។ |
| **៤៦- ដីជ័រ** | ដុំល្បាយដីឥដ្ឋ អង្កាម និង ទឹក ដែលគេយកទៅដុតឱ្យឆ្អិន ហើយ បុកលាយជាមួយដីស្អិតឱ្យទៅជាដីល្បាយ សម្រាប់ធ្វើក្អម ឆ្នាំង... ដើម្បីការពារនឹងការប្រេះ បែកនៅពេលដុត។ គេធ្វើដីជ័រនេះនៅតំបន់ណាដែល គ្មានដីស្អាត និង ថ្មពុក ដូចជា ខេត្តព្រៃវែង ជាដើម។  |

| | |
|---|---|
| ៤៧- ស្លឹកចៀរ | ស្លឹកឈើមួយប្រភេទប្រើជាឧបករណ៍សម្រាប់ចាប់ឱ្យចេញជាចំនៀរ ស្អាតល្អ នៅត្រង់មាត់ផ្ទាំង ថ្លាង ខ្ទាង... សម្រាប់ដាក់គម្រប។ អ្នកភូមិអណ្តូងឫស្សី ឃុំស្រែថ្មី ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ប្រើស្លឹកចៀរនេះជាចាំបាច់សម្រាប់ចាប់ចំនៀរ ហើយ នៅរៀងរាល់ឆ្នាំ ក្នុងថ្ងៃ១កើត ខែអស្សុជ អ្នកភូមិនេះ តែងធ្វើពិធីបុណ្យបេះស្លឹកចៀរនេះយកមកទុកប្រើប្រាស់។   |
| ៤៨- សាវៃ | ចម្រៀកកំណាត់សំពត់ប្រើជាឧបករណ៍សម្រាប់ចាប់ឱ្យចេញជាចំនៀរនិងរម្លីងមាត់ក្អម ផ្ទាំង... ឱ្យរលោងល្អ។ តំបន់ខ្លះនៃអ្នកខេត្តព្រៃវែងហៅថា សាវៃ។  |
| ៤៩- ត្បាល់ | កំណាត់ឈើឬកំណាត់ដើមត្នោត មានរាងមូលទ្រវែង( ស៊ីឡាំង ) ប្រើសម្រាប់ដាក់ទ្រដុំដីល្បាយ ពេលចាប់ជារាងក្អមឬផ្ទាំង។ តំបន់ខ្លះនៃអ្នកស្រុកនៅខេត្តព្រៃវែងហៅថា ឈើមូល។  |
| ៥០- កូនត្រី | គ្រាប់ដីតូចៗដែលមាននៅក្នុងល្បាយបន្ទាប់ពីលាយដីស្អិតស្ងួតជាមួយដីដំរ ឬដីស្អាត ឬក៏ថ្មពុក ដែលគេត្រូវរែងយកចេញ ដើម្បីបានជាដីល្បាយម៉ដ្ឋសម្រាប់ធ្វើក្អម ផ្ទាំង...។  |

| | |
|---|---|
| **៥១- ការប៉ែនដី** | សកម្មភាពលុង និង ទះ តប់ដុំដីល្បាយនៅលើត្បាល់ ដោយប្រើដៃចាប់ឱ្យចេញជារាងដំបូង មុននឹងចាប់ផ្ដើមធ្វើមាត់ក្អម ផ្ទាំង...។  |
| **៥២- ប៉ែន / ដីប៉ែន** | ដីល្បាយជារាងស៊ីឡាំងបានមកពីការប៉ែនដី សម្រាប់ធ្វើក្អម ផ្ទាំង...។  |
| **៥៣- រះមាត់** | សកម្មភាពសម្អាតមាត់ក្អម ផ្ទាំង... បន្ទាប់ពីមានទ្រង់ ទ្រាយជាមាត់រួចហើយ ដោយយកស្លឹកចៀប្ឫសារែមកចាប់ឱ្យចេញជាចំនៀរស្អាតរលោងល្អ។  |
| **៥៤- គោះភ្ជាប់ជើង** | ការវាយផ្នែកខាងក្រោមនៃប៉ែន ដែលបានធ្វើមាត់រួចឱ្យជាប់នឹងត្បាល់ មុននឹងចាប់ផ្ដើមវាយបើកតួខ្លួន។ |
| **៥៥- បំព្រំវិល** | ការវាយទះដោយប្រើទ្រនះនិងទ្រនល់ជុំវិញប៉ែន ធ្វើមាត់រួចដែលតម្កល់លើត្បាល់ឱ្យចេញជារូបរាងក្អម ផ្ទាំង...។ បំព្រំវិលរួមមានដំណាក់កាលវាយបើកនិងបំព្រំក្អេង។ |
| **៥៦- វាយបើក** | ការវាយទះដោយប្រើទ្រនះនិងទ្រនល់ជុំវិញប៉ែន ធ្វើមាត់រួចដែលតម្កល់លើត្បាល់ឱ្យប៉ោងចេញជារូបរាងក្អម ផ្ទាំង...។  |
| **៥៧- បំព្រំក្អេង** | ការវាយទះដោយប្រើទ្រនះនិងទ្រនល់ដើម្បីពង្រីកក្អេងបន្ថែមនិងលុបស្នាមទ្រនះឱ្យមានរូបរាងពេញលេញ បន្ទាប់ពីការវាយបើកតួក្អម ផ្ទាំង...។  |

| | |
|---|---|
| **៥៨- ចំនៀរ** | គែមរង្វង់មាត់ខាងក្នុងនៃផ្ទាំង ខ្វាង... សម្រាប់ទ្រគម្រប ផ្ទាំង ខ្វាង...។ ស្នូននៅ ខេត្តកំពង់ឆ្នាំងប្រើស្លឹកចៀរដើម្បីចាប់រាងចំនៀរ រីឯស្នូននៅខេត្តព្រៃវែងវិញ គេធ្វើ ចំនៀរនេះដោយប្រើសាវ៉ែ ។<br> |
| **៥៩- ដឹកខ្នួត** | អូសក្បួតជុំវិញដោយឈើដឹកខ្នួតនៅត្រង់កឱ្យមានគន្លាក់ស្អាតល្អនិងផ្នែកខាងលើនៃក្អេងឱ្យចេញជាទ្រនុងច្បាស់។<br> |
| **៦០- រម្លីងក្អេង** | ដុសជូតត្រង់ក្អេងនៃក្អម ផ្ទាំង... ឱ្យរលីង រលោងល្អ ដោយប្រើទ្រនះ និងកំណាត់ សំពត់ជ្រលក់ទឹក។<br> |
| **៦១- គោះជើង** | គោះឱ្យរបើកដាច់ចេញពីត្បាល់ឬឈើមូល ដោយប្រើទ្រនះទះតិចៗជុំវិញនៅជើងក្រោមនៃក្អម ផ្ទាំង... ដើម្បីលើកយកទៅសំងិល មុននឹងហ៊ុមបាត។<br> |
| **៦២- ហ៊ុមបាត** | វាយប្រមែប្រមុមភ្និតបាតក្អម ផ្ទាំង... ដោយប្រើទ្រនះនិងទ្រនល់ ។ ជាទូទៅ ពេលហ៊ុមបាត ស្នូនយកក្អម ផ្ទាំងនោះមកដាក់លើភ្លៅ។<br> |

| | |
|---|---|
| **៦៣- បំព្រំបាត** | វាយទះបន្តិចៗ លុបស្នាមទ្រនះបន្សល់ពីការហ៊ុមបាតនៃក្អម ឆ្នាំង... ឱ្យមានរាងស្អាតល្អ។  |
| **៦៤- រម្លីងបាត** | ដុសជូតជាចុងក្រោយនៅផ្នែកបាតនៃក្អម ឆ្នាំង... ឱ្យរលីង រលោងល្អ ដោយប្រើទ្រនះនិងកំណាត់សំពត់ជ្រលក់ទឹកឬដៃជ្រលក់ទឹក បន្ទាប់ពីបំព្រំបាតរួច។   |
| **៦៥- ទូក** | យានសម្រាប់ជិះឬដឹកជញ្ជូនតាមផ្លូវទឹក ច្រើនធ្វើពីឈើ មានរាងក្រឡូមសណ្ដូកវែង ផ្នែកខាងមុខហៅថាក្បាល ឯផ្នែកខាងក្រោយហៅថាកន្សៃ។ ទូកធ្វើពីឈើដែលគេយកទៅលុង ឬ ដោយផ្គុំក្ដារ(លើកក្ដារ)ច្រើនបន្ទះ មានសណ្ឋានប្លែកៗ ខ្លះតូច ខ្លះធំ ខ្លះវែង ខ្លះខ្លី។ ទូកមានប្រភេទខុសៗគ្នា ដូចជា ខ្លះជាទូកអុំ ទូកចែវ ទូកក្ដោង ឬ ទូកម៉ាស៊ីន ប្រើក្នុងមុខការផ្សេងៗគ្នា និង មានឈ្មោះហៅខុសៗគ្នាផងដែរ។ ឧ.ទូក-ង ទូកផ្កាចារ ទូកត្នោត...។ |
| **៦៦- ទូកផ្កាចារ** | ទូកមួយប្រភេទមានរាងដូចផ្កាចារ មានសណ្ឋានក្រឡូមសណ្ដូកវែង មានក្បាលនិងកន្សៃងើបខ្ពស់។ ទូកប្រភេទនេះអាចអុំក៏បាន ចែវក៏បាន ភាគច្រើនប្រើនៅតាមស្ទឹង បឹង អូរ ជាដើម។  |
| **៦៧- ទូកប៉ាឡា** | ទូកមួយប្រភេទ លើកក្ដារ ប៉ិតក្បាល ប៉ិតកន្សៃ ច្រើនមានទំហំតូចល្មម ហើយមិនកំណត់ថា ខាងណាជាក្បាល ខាងណាជាកន្សៃទេ។ ទូកប៉ាឡានេះ គេច្រើនប្រើជាទូកអុំ សម្រាប់ជិះតាមអូរ បឹង ស្ទឹង ទន្លេ ជាដើម។ ពាក្យ *ប៉ាឡា* នេះប្រហែលមានប្រភពមកពីពាក្យ *ប៉ាតឡាត*។ |

| | |
|---|---|
| |  |
| **៦៨- ទូកត្នោត** | ទូកមួយប្រភេទ ធ្វើពីដើមត្នោត ដែលគេលុងយកសាច់ស្រាយចេញ ដោយយកផ្នែកខាងគល់ធ្វើជាក្បាលទូក។ ទូកត្នោតប្រើការបាននៅជិតៗផង។  |
| **៦៩- ទូកម្លង** | ទូកមួយប្រភេទធ្វើពីឈើដែលគេលុង មានកន្សែងើបខ្ពស់ងឡើង ព្រមទាំងមានគូរក្បាច់រចនាវិចិត្រផ្សេងៗលើផ្ទៃទូកខាងក្រៅ។ ទូកម្លងមានចំណុះអាចផ្ទុកមនុស្សបានច្រើនគ្នា ហើយ ប្រើចែវដែលពាក់ត្រពែងដោយខ្សែភ្ជាប់នឹងជើងចែវកាន់យោគគាស់ទឹក ដើម្បីឱ្យទូកលឿន។ ទូកម្លងច្រើនមានឈ្មោះទាក់ទងនឹងអមនុស្សផ្សេងៗ ដែលគេជឿថាមានឫទ្ធិតេជះ ហើយ ជាទូទៅគេរក្សាទូកនេះទុកនៅតាមវត្តអារាម។ ទូកម្លងប្រើសម្រាប់ប្រណាំងក្នុងពិធីបុណ្យអុំទូក បណ្តែតប្រទីប សំពះព្រះខែ អកអំបុក បុណ្យភ្ជុំបិណ្ឌ និង ពិធីបុណ្យចេញព្រះវស្សាជាដើម។  |
| **៧០- ល្ខោនស្បែកធំ**<br>អ. Lakhaon Sbaek Thom ( Large Shadow Theatre ) | ទម្រង់សិល្បៈទស្សនីយភាពប្រភេទល្ខោន ដែលយកស្រមោលរូបចម្លាក់ស្បែកជាមូលដ្ឋាន មានលក្ខណៈសក្ការៈ សម្តែងឡើងជាឈុតខ្លីៗ តែនៅក្នុងរឿងរាមកេរ្តិ៍។ ក្នុងពេលសម្តែងគេយករូបចម្លាក់ ស្បែកនោះមកដើតពីខាងក្រោយផ្ទាំងសំពត់ស ដែលមានពន្លឺភ្លើង (កាលពីបុរាណ គេប្រើភ្លើងចន្លុះឬភ្លើងត្រឡោកដូង )ចាំងនៅពីខាងក្រោយបង្កើតជាស្រមោលលើផ្ទាំងសំពត់សនេះ ឬដើតពីខាងមុខផ្ទាំងសំពត់ស ហើយ មានឈុតខ្លះសិល្បករសម្តែងផ្ទាល់ |

| | |
|---|---|
| | តែម្តង។ រូបចម្លាក់ស្បែកនៅក្នុងល្ខោននេះ បានមកពីការដាប់ទម្លុះស្បែកគោ ជាផ្ទាំងរូបធំៗជារូបតួអង្គផ្សេងៗ ដូចជា តួយក្ស ទេវតា មនុស្ស ស្វា... ដែលមានលក្ខណៈនឹងថ្កល់។<br>ល្ខោនស្បែកធំកម្ពុជាបានបញ្ចូលជាស្នាដៃឯកនៃបេតិកភណ្ឌវប្បធម៌អរូបីរបស់មនុស្សជាតិ នៅថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០៥។ |
| **៧១- ល្ខោនស្បែកតូច**<br>អ. Lakhaon Sbaek Touch (Small shadow Theatre) | ទម្រង់សិល្បៈទស្សនីយភាពប្រភេទ ជាល្ខោនដែលយកស្រមោល ស្បែកជាមូលដ្ឋាន មានលក្ខណៈប្រជាប្រិយ ភាគច្រើនបែបកំប្លុកកំប្លែង អាចសម្តែងឡើងបានជាឈុតវែងឬខ្លីនូវរឿងជាច្រើន ដូចជា រឿងព្រេង និទាន រឿងប្រវត្តិសាស្ត្ររឿងទាក់ទងទៅនឹងជីវភាពរស់នៅរបស់មនុស្សក្នុងសង្គម។ ក្នុងពេលសម្តែងសិល្បករយករូបចម្លាក់ស្បែកមកដើតពីខាងក្រោយផ្ទាំងសំពត់ស ដែលមានពន្លឺភ្លើង(កាលពីបុរាណ គេ ប្រើភ្លើងចន្លុះឬភ្លើងត្រឡោកដូង) ចាំងនៅពីខាងក្រោយ បង្កើតជា ស្រមោលលើ ផ្ទាំងសំពត់ស។ រូបចម្លាក់ស្បែកនៅក្នុងល្ខោននេះបានមកពីការដាប់ទម្លុះស្បែកគោ ជាផ្ទាំងរូបតូចៗ ជារូបតួអង្គផ្សេងៗ ដូចជា តួតាឥសី កិន្នរី ទេវតា យក្ស មនុស្ស សត្វ វត្ថុ... ដែលអាចឱ្យធ្វើកាយវិការបានដូចជាលើកដៃ លើកជើង ឬហាមាត់និយាយ ឬ ក៏ច្រៀងជាដើម។<br>ឧ. ល្ខោនស្រមោលស្បែកតូច *រឿងលិនថោង រឿងម៉េម៉ាយក្តៅៗ រឿងសក់សដូនដំណើរសក់ខ្មៅ*។ |
| **៧២- ល្ខោនស្បែកពណ៌**<br>អ. Lakhaon Sbaek Por (Color Leather Theatre) | ទម្រង់សិល្បៈទស្សនីយភាពប្រភេទ ជាល្ខោនដែលយកចម្លាក់ស្បែកគោផាត់ពណ៌ដូចផ្ទាំងគំនូរមកសម្តែងជារឿងបានច្រើនប្រភេទ ដូចជាទេវកថា ជាតកជាដើម។ ចម្លាក់ស្បែកពណ៌នេះ បានមកពីការដាប់ទម្លុះស្បែកគោ ជារូបតួអង្គផ្សេងៗ មានដូចជាតួស្រី តួប្រុស រូបជិះសេះ ជិះរាជរថ រូបមនុស្សកំពុងអង្គុយពិភាក្សា... រួចគេយកពណ៌មកលាប ដូចផ្ទាំងគំនូរ។ រូបតួអង្គនីមួយៗ នៅក្នុងល្ខោនស្បែកពណ៌នេះ មានកាយវិការនឹងថ្កល់មិនអាចកម្រើកបាន។ ពេលសម្តែង សិល្បករស្លៀកពាក់ដូចតួអង្គក្នុងរូបចម្លាក់ស្បែកដែលខ្លួនកាន់មកដើតពីខាងមុខផ្ទាំងសំពត់ស រួចយកចម្លាក់ស្បែកនោះទៅដោតលើបារមួយ ហើយ សិល្បករនេះ មកសម្តែងជាតួអង្គផ្ទាល់តែម្តង។<br>ឧ. ល្ខោនស្បែកពណ៌ *រឿងរាមកេរ្តិ៍*។<br>ឧ. ល្ខោនស្បែកពណ៌ *រឿងព្រះជិនវង្ស*។ |
| **៧៣- ល្ខោនខោល /ភាណី / ល្ខោនពាក់មុខ**<br>អ. Lakhaon Khaol (Male Masked Theatre) | ទម្រង់សិល្បៈទស្សនីយភាពប្រភេទល្ខោនក្បាច់បុរាណ ដែលមានលក្ខណៈសក្ការៈ ហើយ អ្នកសម្តែងសុទ្ធតែប្រុសៗ បើទោះបីជាតួអង្គស្រី ក៏យកអ្នកសម្តែងប្រុសមកសម្តែងដែរ។ ជាទូទៅ តួសម្តែងពាក់មុខខ្នុក (របាំងមុខ) តួអង្គផ្សេងៗដូចជា មេទ័ពស្វា ពលស្វា មេទ័ពយក្ស សេនាយក្ស តាឥសី |

| | |
|---|---|
| | ជាដើម ហើយ សម្ដែងបានតែនៅក្នុងរឿងរាមកេរ្តិ៍មួយគត់។<br>ឧ. ល្ខោនខោល *ឈុតចម្បាំងវិរាពណ៍* ។ |
| **៧៤- ល្ខោនយីកេ**<br>អ. Lakhaon Yike<br>( Yike Theatre ) | ទម្រង់សិល្បៈទស្សនីយភាពប្រភេទជាល្ខោនច្រៀងរាំបែបបុរាណ ដែលរៀបរាប់ដំណើររឿងតាមរយៈអ្នកពោលជាចម្បងអមដោយស្គរយីកេ ហើយ បទចម្រៀងនិងក្បាច់រាំមានសភាពទន់ភ្លន់ មានលំនាំជាទឹករលក។ ល្ខោនយីកេមានបទភ្លេង/ចម្រៀងចំនួន៨៣បទ។<br>ឧ. ល្ខោនយីកេ *រឿងទុំទាវ, រឿងម៉ាក់ថឺង* ។ |
| **៧៥- ល្ខោនមហោរី**<br>អ. Lakhaon Mohori<br>( Mohari Theatre ) | ទម្រង់សិល្បៈទស្សនីយភាពប្រភេទជាល្ខោនច្រៀង រាំបែបបុរាណ ដែលមានវង់ភ្លេងនិងបទចម្រៀងមហោរីជាមូលដ្ឋាន។ មធ្យោបាយសម្ដែងមានលក្ខណៈចម្រុះដោយមានរួមបញ្ចូលផ្នែកខ្លះៗនៃទម្រង់ល្ខោនយីកេ ល្ខោនបាសាក់ ល្ខោនកំណាព្យ និងល្ខោននិយាយជាដើម ។<br>ឧ.ល្ខោនមហោរី *រឿងវិប្បដិសារីនៃព្រានព្រៃ* ។ |
| **៧៦- ល្ខោនកំណាព្យ**<br>អ. Lakhaon Komnap<br>( Poem Drama ) | ទម្រង់សិល្បៈទស្សនីយភាពប្រភេទជាល្ខោននិយាយ ដែលប្រើកំណាព្យនិងកម្រងកែវជាមូលដ្ឋានគួបផ្សំជាមួយនឹងកាយវិការក្នុង ការសម្ដែង។<br>ឧ. ល្ខោនកំណាព្យ *រឿងដើមឆ្កក្សាជាតិ រឿងកាកី រឿងព្រះរាជសម្ភារ* ។ |
| **៧៧- ល្ខោនភ្លេងការ**<br>អ. Lakhaon Pleng Kar ( Wedding Drama ) | ទម្រង់សិល្បៈទស្សនីយភាព ប្រភេទជាល្ខោនច្រៀង រាំ ដែលយកវង់ភ្លេងការខ្មែរបុរាណនិងបទភ្លេងការជាមូលដ្ឋានក្នុងការសម្ដែង។ ឧបករណ៍ក្នុងវង់ភ្លេងការខ្មែរបុរាណមាន ទ្រខ្មែរ ប៉ីអ ប៉ីពក ខ្សែដៀវ ចាប៉ីដងវែង និង ស្គរដៃ( ចំនួនពីរ )។ បទភ្លេងការខ្មែរ មានចំនួន១៣៣បទ ដែលបានរកឃើញ។<br>ឧ. ល្ខោនភ្លេងការ *រឿងខាន់ស្លា ខណ្ឌស្នេហ៍* ។ |
| **៧៨- ល្ខោនចម្រុះ**<br>អ. Lakhaon Chamros<br>( Mixed Theatre ) | ទម្រង់សិល្បៈទស្សនីយភាព ប្រភេទជាល្ខោននិយាយសម័យទំនើប ដែលរួមបញ្ចូលនូវទម្រង់សិល្បៈផ្សេងៗជាច្រើនទៀតក្នុងការសម្ដែង មានដូចជាល្ខោននិយាយ ល្ខោនយីកេ ល្ខោនបាសាក់ របាំប្រពៃណី របាំក្បាច់បុរាណ តន្ត្រី ចម្រៀងបុរាណនិងសម័យ ជាដើម។ បច្ចុប្បន្នមានការច្នៃគួបផ្សំបញ្ចូលនូវបច្ចេកវិទ្យាទំនើបបន្ថែម ដូចជាការបញ្ចាំងស្លាយ វីដេអូ ឬភាពយន្តឯកសារ។ ល្ខោនចម្រុះ ទើបតែមានកំណើតនៅក្នុងសម័យសង្គមរាស្ត្រនិយមនៅឆ្នាំ១៩៦៧។<br>ឧ. ល្ខោនចម្រុះ *រឿងប្រាសាទព្រះវិហារ* ដែលនិពន្ធឡើងដោយលោក ហង្ស ធន់ហាក់, លោក មាស គក, លោក ឆេង ផុន, លោក វណ្ណ មូលីវណ្ណ និង លោក ប៉ុល សំអឿន។ |
| **៧៩- ល្ខោននិយាយ**<br>អ. Lakhaon Niyeay<br>( Modern Spoken Theatre ) | ទម្រង់សិល្បៈទស្សនីយភាព ប្រភេទជាល្ខោនដែលយកពាក្យសម្ដីជាមូលដ្ឋានគួបផ្សំជាមួយនឹងកាយវិការក្នុងការសម្ដែង។ ល្ខោននិយាយនេះ មានកំណើតជាផ្លូវការនៅចុងឆ្នាំ១៩៥៤ ដោយបុគ្គលិកសិក្សាខ្មែរស្ថិតក្រោមអាណាព្យាបាលរបស់ក្រសួងអប់រំជាតិនិងវិចិត្រសិល្បៈ ដែលកាលនោះមានឈ្មោះថា |

| | |
|---|---|
| | «ល្ខោនជាតិ នៃប្រទេសកម្ពុជា»។<br>ឧ. ល្ខោននិយាយ *រឿងចិញ្ចៀនបញ្ចាំចិត្ត រឿងវង្សត្រកូលកំសត់ រឿងថ្មរាំ រឿងថៅកែចិត្តចោរ*...។ |
| **៨០- ល្ខោនពោលស្រី**<br>Lkhaon Pól Srei | ទម្រង់សិល្បៈទស្សនីយភាព ប្រភេទជាល្ខោនច្រៀងរាំមួយបែបដែលមានស្រីជាអ្នកពោលរៀបរាប់សាច់រឿង ហើយ អ្នកសម្តែងសុទ្ធតែស្រីៗ លើកលែងតែតួតាឥសី តួភ្លុក ឬ តួសត្វផ្សេងៗ ដែលជាទូទៅសម្តែងដោយមនុស្សប្រុស។ របៀបនៃការសម្តែង គឺអ្នកសម្តែងទាំងអស់សុទ្ធតែត្រូវ រាំ ច្រៀង និយាយដោយខ្លួនឯងផ្ទាល់ (ច្រៀងឯងរាំឯង) រីឯតួអង្គដែលមានពាក់មុខខ្នុក នៅពេលនិយាយ ឬច្រៀង គឺត្រូវបង្ហើបមុខនោះរុញឡើងលើ។<br>ឧ.ល្ខោនពោលស្រី *រឿងជ័យសែន*។ |
| **៨១- ល្ខោនបើកបទ**<br>Lkhaon Baek Bât | ទម្រង់សិល្បៈទស្សនីយភាព ប្រភេទជាល្ខោនច្រៀងរាំមួយបែប ដែលយកកាយវិការល្ខោនក្បាច់បុរាណខ្មែរជាមូលដ្ឋាន ហើយ តួសម្តែងត្រូវច្រៀងមុនភ្លេង (ច្រៀងបើកបទ) ទើបភ្លេងប្រគំបន្តតាមក្រោយ។ ល្ខោនបើកបទ មានដើមកំណើតប្រហែលក្នុងអំឡុងឆ្នាំ១៧៩៥ នៅខេត្តបាត់ដំបងក្នុងរជ្ជកាលព្រះបាទអង្គអេង។ ដើមឡើយ អ្នកសម្តែងនៃល្ខោនបើកបទជាអ្នកនៅលីវ។<br>ឧ. ល្ខោនបើកបទ សម្តែងរឿងរាមកេរ្តិ៍ គ្រង់ឈុតសិតាលុយភ្លើង។ |
| **៨២- ល្ខោនគែន**<br>Lkhaon Kén | ទម្រង់សិល្បៈទស្សនីយភាព ប្រភេទជាល្ខោនច្រៀងរាំមួយបែប ដែលយកកាយវិការល្ខោនក្បាច់បុរាណខ្មែរជាមូលដ្ឋាន ហើយ អ្នកសម្តែងទាំងអស់សុទ្ធតែស្រីៗ។ ពេលសម្តែងត្រូវច្រៀងនិងនិយាយខ្លួនឯង អមដោយឧបករណ៍គែន។ ល្ខោនគែនយកតាមឈ្មោះឧបករណ៍តន្ត្រីគ្រឿងផ្លុំម្យ៉ាងហៅថា «គែន»។ វង់ភ្លេងល្ខោនគែនមានគែនចំនួន ៣, ៤, ៥ ឬ ៦ (ពីសំឡេងធំគ្រលរទៅសំឡេងស្រួយ) រួមជាមួយឧបករណ៍តន្ត្រីផ្សេងទៀតមាន រនាតឯក រនាតធុង តាខេ ទ្រអ៊ូ ទ្រសោ ទ្រធេ ក្រាប់ ឈិង ស្គរថូន ស្គររមនា និងសម្ភោរ។ ក្នុងការសម្តែងល្ខោនគែន ភាគច្រើនគេយកបទភ្លេងមហោរីមកប្រើ។<br>ឧ. ល្ខោនគែន *រឿងក្រៃថោង*។ |
| **៨៣- ល្ខោនប្រាមោទ្យទ័យ**<br>Lkhaon Lkhaon Pramóttey | ទម្រង់សិល្បៈទស្សនីយភាព ប្រភេទជាល្ខោនបែបទំនើប ដែលយកចម្រៀងនិងតន្ត្រីសម័យជាមូលដ្ឋាន ហើយ អ្នកសម្តែងទាំងអស់សុទ្ធតែស្រីៗ លើកលែងតែតួភ្លុក។ ល្ខោននេះទទួលឥទ្ធិពលឬក៏យកលំនាំទាំងស្រុងពីល្ខោនច្រៀងបែបបស្ចិមប្រទេស (opérette ) ជាពិសេសពីប្រទេសបារាំង។ ល្ខោននេះមានដើមកំណើតនៅដើមស.វ.ទី២០ ប្រមាណក្នុងអំឡុងឆ្នាំ១៩២០ក្រោយសង្គ្រាមលោកលើកទី១ (១៩១៤-១៩១៨)។<br>ឧ. ល្ខោនបាមោទ្យទ័យ រឿង«*កេបកេបកូនល្អ*»។ |

| | |
|---|---|
| **៨៤- ល្ខោនអាប៉េ**<br>Lkhaon Apé | ទម្រង់សិល្បៈទស្សនីយភាព ប្រភេទជាល្ខោនច្រៀងរាំ និង និយាយ ច្នៃចេញពីល្ខោនក្បាច់បុរាណខ្មែរដែលជាទូទៅមានលក្ខណៈក្រមិចក្រមើម ជារឿងកំប្លុកកំប្លែង សម្ដែងឡើងដើម្បីកម្សាន្តសប្បាយ។<br>ឧ. ល្ខោនអាប៉េ *រឿងអន្ទិតសក់ខ្លី*។ |
| **៨៥- អាយ៉ៃ** | ទម្រង់សិល្បៈទស្សនីយភាពប្រភេទជាចម្រៀង ប្រើសំនួនវោហារ ឬ កំណាព្យកាព្យឃ្លោង មានរាំ មានកាយវិការបែបកំប្លុកកំប្លែងនិងមានវង់ភ្លេងការប្រគំក្នុងពេល សម្ដែង។ តាមឯកសារខ្លះ សិល្បៈអាយ៉ៃ ហៅតាមឈ្មោះយ៉ៃ (១៨៧៨-១៩៥៨) ដែលជាសិល្បករម្នាក់សម្ដែងក្នុងក្រុមសិល្បៈភ្លេងវង់ធំមួយក្រុមនៅភូមិត្រពាំងទា ឃុំពងទឹក ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល។ អាយ៉ៃមានពីរប្រភេទ គឺអាយ៉ៃឆ្លើយឆ្លង និង អាយ៉ៃរឿង។ |
| **៨៦- អាយ៉ៃឆ្លើយឆ្លង** | ប្រភេទសិល្បៈអាយ៉ៃដែលមានដៃគូប្រុសស្រី ច្រៀងឆ្លើយឆ្លងដេញប្រាជ្ញាគ្នាតាមរយៈការចោទនិងឆ្លើយដោះស្រាយសំណួរឬប្រស្នានានា ដោយប្រើសំនួនវោហារឬកំណាព្យកាព្យឃ្លោងដោយឥតព្រាងទុកដែលភាគច្រើនមានលក្ខណៈបញ្ឆិតបញ្ឆៀង លែបខាយ បង្កប់ន័យប្រៀបធៀប ឬ ន័យផ្ទុយគ្នា មានរាំមានកាយវិការបែបកំប្លុកកំប្លែង រួមទាំងមានវង់ភ្លេងការប្រគំក្នុងពេលសម្ដែង។<br>ឧ. អាយ៉ៃឆ្លើយឆ្លងលោក ព្រហ្ម ម៉ាញ និង អ្នកស្រី នួន សារី (យាយយ៉យ)។ |
| **៨៧- អាយ៉ៃរឿង** | ប្រភេទសិល្បៈអាយ៉ៃ ដែលលើកយករឿងបែបកំប្លែងមកសម្ដែង ដោយប្រើចម្រៀង កាយវិការ ពាក្យនិយាយឬប្រើសំនួនវោហារ ឬ ក៏កំណាព្យកាព្យឃ្លោង និងប្រើវង់ភ្លេងការក្នុងការសម្ដែង។<br>ឧ. អាយ៉ៃរឿង *ឪពុកក្មេករើសកូនប្រសា*។ |
| **៨៨- ចាប៉ី (ចម្រៀង)** | ទម្រង់សិល្បៈប្រភេទជាចម្រៀង ដែលប្រើចាប៉ីដងវែងជាមូលដ្ឋាន ច្រៀងរៀបរាប់ពីដំណើររឿង ព្រឹត្តិការណ៍ ប្រវត្តិការអប់រំ... ដោយប្រើសំនួនវោហារ កម្រងកែវ និង បទកំណាព្យ (ភាគច្រើន គេប្រើកំណាព្យបទពាក្យ៧)។ ចាប៉ីចែកចេញជាពីរប្រភេទ គឺចាប៉ីរឿង និង ចាប៉ីឆ្លើយឆ្លង។ |
| **៨៩- ចាប៉ីរឿង** | ប្រភេទសិល្បៈចាប៉ី ដែលច្រៀងតែម្នាក់ឯង(ច្រៀងទោល)ដោយអ្នកច្រៀងប្រើឧបករណ៍ចាប៉ីដងវែងដេញ កេះ ត្រែះប្រកបជាមួយចម្រៀង ដោយខ្លួនឯងផ្ទាល់ ហើយ ច្រើនច្រៀងរៀបរាប់អំពីរឿងជាតក រឿងព្រេងនិទាន ឬក៏រឿងរ៉ាវទាក់ទងទៅនឹងប្រវត្តិសាស្ត្រ ភូមិសាស្ត្រ ជំនឿ ប្រពៃណី ទំនៀមទម្លាប់ បញ្ហាជីវភាពសង្គម...។ អ្នកចម្រៀងចាប៉ីដងវែងល្បីៗមានដូចជា លោកតាចង្កូម៨ លោកតាពូថៅដៃ លោកតា ប្រាជ្ញ ឈួន លោកតា ម៉ម សុន លោកតា គង់ ណៃ លោកនេត ប៉េ ជាដើម។<br>ឧ. ចាប៉ីរឿងសុវណ្ណដូងខ្ចី ច្រៀងដោយ លោកតា ម៉ម សុន។ |

| | |
|---|---|
| **៩០- ចាប៉ីឆ្លើយឆ្លង** | ប្រភេទសិល្បៈចាប៉ី ដែលអ្នកច្រៀងប្រើឧបករណ៍ចាប៉ីដងវែងដេញ កេះ ត្រែះ ប្រកបជាមួយចម្រៀងដោយខ្លួនឯងដូចចាប៉ីរឿងដែរ ប៉ុន្តែ មានអ្នកច្រៀងពីរនាក់ឬលើសពីនេះ ដោយច្រៀងចោទ និង ឆ្លើយដោះស្រាយសំណួរ ឬ ប្រស្នាដេញប្រាជ្ញាគ្នា លែបខាយគ្នាក្នុងភាពថ្លៃថ្នូរ ដោយសំនួនវោហារជាកំណាព្យកាព្យឃ្លោងឬ កម្រងកែវឥតព្រាងទុក។<br>ឧ. ចាប៉ីឆ្លើយឆ្លងច្រៀងដោយលោកតា ប្រាជ្ញ ឈួន និង លោកតា គង់ ណៃ ស្ដីពីពិធីបុណ្យចូលឆ្នាំថ្មី។ |
| **៩១- ខ្សែដៀវ** | ទម្រង់សិល្បៈប្រភេទជាចម្រៀង ដោយអ្នកច្រៀងប្រើឧបករណ៍សាដៀវដេញ កេះ ប្រកបជាមួយចម្រៀងដោយខ្លួនឯងផ្ទាល់ផង ឬ ពេលខ្លះក៏មានអ្នកដេញសាដៀវជំនួសឱ្យផងក៏មាន ហើយ ច្រៀងរៀបរាប់រឿង ច្រៀងអប់រំ ច្រៀងរំលឹកដាស់តឿន ឬ ច្រៀងទូន្មានប្រៀនប្រដៅ (ច្រៀងទោល និង ច្រៀងដេញប្រាជ្ញាចោទឆ្លើយគ្នា) តាមរយៈបទកំណាព្យ ឬ រឿងព្រេងនិទាន ជាដើម។<br>ឧ. ចម្រៀងខ្សែដៀវរបស់អ្នកកិម្សេភាសាអ៊ូ ហៅ ង៉ុយ ច្រៀងពីច្បាប់កេរកាលថ្មី។ |
| **៩២- សិល្បៈនិទានរឿង** | ទម្រង់សិល្បៈប្រភេទជាការនិទានរបស់មនុស្សម្នាក់អំពីរឿងរ៉ាវឬប្រវត្តិទាក់ទងទៅនឹងសាសនា ជំនឿ ប្រពៃណី ទំនៀមទម្លាប់ ឬ ក៏ជីវភាពសង្គម... ដោយប្រើពាក្យពេចន៍ សំនួនវោហារ បទកំណាព្យកាព្យឃ្លោង កម្រងកែវ ឬក៏ជួនកាលអាចមានការគួបផ្សំនូវកាយវិការ និង ឧបករណ៍ផ្សេងៗបង្កើតបានជាសំឡេង។<br>អ្នកសម្ដែងដែលមានទេពកោសល្យខ្ពស់អាចប្ដូរសំឡេងបានជាច្រើនបែប ដូចជាធ្វើជាសំឡេងស្រី ប្រុស ចាស់ ក្មេង រហូតដល់សំឡេងសត្វផ្សេងៗទៀតផង។<br>ឧ. លោកតា គ្រុឌ និទានរឿងរាមកេរ្តិ៍។ |
| **៩៣- សិល្បៈសៀក** | ទម្រង់សិល្បៈទស្សនីយភាព ដែលមានលក្ខណៈក្លៀវក្លា សង្ហា សមសួន អ្នកសម្ដែងទាំងអស់សុទ្ធសឹងប្រើកម្លាំងសាច់ដុំ កម្លាំងប្រាជ្ញា ប៉ិនភ្នែក ភាពប៉ិនប្រសប់ដ៏អស្ចារ្យរបស់ខ្លួនប្រកបដោយទេពកោសល្យនិងសោភណភាពខ្ពស់។ ទម្រង់សិល្បៈទស្សនីយភាពនេះមានតួសម្ដែងចម្រុះដូចជា តួមនុស្ស តួសត្វ តួត្លុក តួរហស្សកម្ម...។ សិល្បៈសៀកខ្មែរមានតាំងពីសម័យបុរាណរហូតដល់បច្ចុប្បន្ន។<br>ឧ. លោក ចៅហ្វា សម្ដែងសៀករហស្សកម្មដោយធ្វើឱ្យមាន់ស្មោរចេះរងាវ។ |

## II.២.២- បច្ចេកសព្ទស្នើដោយគណៈកម្មការប្រវត្តិវិទ្យា

| | |
|---|---|
| **១- កាលវិទ្យា**<br>អ. Chronology<br>បារ. Chronologie ( f. ) | ការសិក្សាអំពីលំដាប់នៃព្រឹត្តិការណ៍ប្រវត្តិសាស្ត្រ។<br>ឧ. ភ្នែកទាំងគូនៃប្រវត្តិវិទ្យា គឺកាលវិទ្យានិងភូមិវិទ្យា។ |
| **២- កាលប្រវត្តិ**<br>អ. Chronological<br>បារ. Chronologique | ដែលរៀបតាមលំដាប់កាល។<br>ឧ. បញ្ជីឈ្មោះតាមលំដាប់កាលប្រវត្តិ។ |
| **៣- កាលសម័យ**<br>អ. Period<br>បារ. Période ( f. ) | រយៈពេលមួយនៃប្រវត្តិសាស្ត្រដែលវែងជាងសម័យ។<br>ឧ. កាលសម័យបុរេអង្គរចែកជាពីរសម័យគឺ សម័យនគរភ្នំនិងសម័យចេនឡា។ |
| **៤- សម័យ**<br>អ. Epoch<br>បារ. Époque ( f. ) | រយៈពេលមួយនៃប្រវត្តិសាស្ត្រដែលមានព្រឹត្តិការណ៍ពិសេសឬការប្រែប្រួលណាមួយផ្ទុះឡើង។<br>ឧ. សម័យសាធារណរដ្ឋខ្មែរ ចាប់ផ្ដើមបន្ទាប់ពីព្រឹត្តិការណ៍ថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០។ |
| **៥- មុនគ្រិស្តសករាជ**<br>( មុនគ.ស. )<br>អ. Before Christ ( B.C. )<br>Before the Common Era ( B.C.E. )<br>បារ. av. J.-C. | ការកំណត់ឆ្នាំមុនកំណើតព្រះយេស៊ូគ្រិស្ត។<br>ឧ. ព្រះពុទ្ធបរិនិព្វាននៅឆ្នាំ៥៤៣ មុនគ.ស.។ |
| **៦- គ្រិស្តសករាជ** ( គ.ស. )<br>អ. Anno Domini ( A.D. )<br>Common Era ( C.E. )<br>បារ. Ère chrétienne<br>( Ap.J.C. ) | ការកំណត់ឆ្នាំចាប់ពីថ្ងៃកំណើតព្រះយេស៊ូគ្រិស្ត។<br>ឧ. សម័យអង្គរចាប់ផ្ដើមពីឆ្នាំ៨០២ នៃគ្រិស្តសករាជ។ |
| **៧- ពុទ្ធសករាជ ( ព.ស. )**<br>អ. Buddhist Era<br>បារ. Ère bouddhique | ការកំណត់ឆ្នាំចាប់ពីក្រោយថ្ងៃដែលព្រះពុទ្ធបរិនិព្វានទៅបានមួយថ្ងៃ។<br>ឧ. ឆ្នាំ២៥០០ នៃព.ស. ត្រូវនឹងឆ្នាំ១៩៥៧ នៃគ.ស.។ |
| **៨- អ៊ិស្លាមសករាជ**<br>អ. Muslim Era<br>បារ. Ère musulmane | ការកំណត់ឆ្នាំចាប់ពីថ្ងៃដែលមហាម៉ាត់រត់គេចពីក្រុងឡាម៉ិច ( La Mecque ) ទៅក្រុងមេឌីន ( Medine ) នៅគ.ស. ៦២២។ |
| **៩- សករាជ**<br>អ. Era<br>បារ. Ère ( f. ) | សម័យឬស័កដែលកើតមានបុគ្គលឬហេតុអស្ចារ្យណាមួយ។<br>ឧ. សករាជ ម៉ីជី ( Ere Meiji ) នៅជប៉ុន ចន្លោះគ.ស.១៨៦៨ និង គ.ស. ១៩១២។ |

| | |
|---|---|
| **១០- ចុល្លសករាជ**<br>អ. Lesser Era<br>បារ. Petite ère | សករាជតូច។ ការរាប់ឆ្នាំចាប់ពីថ្ងៃដែលព្រះបាទបទុមសុរិយវង្សបានកំណត់ទុកចាប់ពីថ្ងៃចន្ទ ១២កើត ខែចេត្រ ឆ្នាំកុរ ឯកស័ក ពុទ្ធសករាជ ១១៨៣។<br>ឧ. ព្រះបាទនរោត្តមសោយរាជ្យនៅ ច.ស. ១២២១ ត្រូវនឹង គ.ស. ១៨៦០។ |
| **១១- មហាសករាជ**<br>អ. Great Era<br>បារ. Grande ère | សករាជធំ។ ការរាប់ឆ្នាំចាប់ពីថ្ងៃដែលសម្តេចព្រះអរិជ្ជពលពាហនោ (ព្រះកេតុមាលា) បានកំណត់ទុកក្នុងពុទ្ធសករាជ៦២១ ត្រូវនឹងគ្រិស្ត សករាជ៧៨។<br>ឧ. ព្រះបាទនរោត្តមឡើងសោយរាជ្យ ម.ស. ១៧៨២ ត្រូវនឹងគ.ស. ១៨៦០។ |
| **១២- ជំនាន់**<br>អ. Generation<br>បារ. Géneration (f.) | -រយៈពេលមធ្យមដែលក្មេងម្នាក់ធំធាត់ក្លាយជាមនុស្សពេញវ័យ ដែលមានកូនរបស់ខ្លួន(ជាទូទៅមានរយៈពេលប្រមាណ៣០ឆ្នាំ)។<br>-រយៈពេលណាមួយដែលមនុស្សមានវ័យស្រករគ្នា បានដឹងឮឬចូលរួមក្នុងព្រឹត្តិការណ៍សំខាន់ៗនានាជាមួយគ្នា។<br>ឧ. ជំនាន់សម្តេច សីហនុ, ជំនាន់ លន់ នល់, ជំនាន់ ប៉ុល ពត។ |
| **១៣- សហស្សវត្សរ៍**<br>អ. Millennium<br>បារ. Millénaire (m.) | រយៈកាលមួយពាន់ឆ្នាំ ឬ មួយខួបពាន់ឆ្នាំ (មានន័យថា រយៈកាល១ ០០០ ឆ្នាំម្តងៗ)។<br>ឧ. ប្រវត្តិសាស្ត្រកម្ពុជាចាប់ផ្តើមនៅដើមសហស្សវត្សរ៍ទី១នៃគ្រិស្តសករាជ។ |
| **១៤- សតវត្សរ៍**<br>អ. Century<br>បារ. Siècle (m.) | រយៈកាលមួយរយឆ្នាំ ឬ មួយខួបរយឆ្នាំ (មានន័យថា រយៈកាល១០០ ឆ្នាំម្តងៗ)។<br>ឧ. ព្រះពុទ្ធទ្រង់បរិនិព្វាននៅពាក់កណ្តាលសតវត្សរ៍ទី៦មុនគ.ស.។ |
| **១៥- ទសវត្សរ៍**<br>អ. Decade<br>បារ. Décennie (f.) | រយៈកាលដប់ឆ្នាំ ឬ ខួបដប់ឆ្នាំ (មានន័យថា រយៈកាល១០ឆ្នាំម្តងៗ)។<br>ឧ. ពួកខ្មែរក្រហមបានដណ្តើមកាន់កាប់អំណាចនៅប្រទេស កម្ពុជាក្នុងពាក់កណ្តាលទសវត្សរ៍ទី៨ នៃសតវត្សរ៍ទី២០។ |
| **១៦- យុគ**<br>អ. Age<br>បារ. Age (m.) | ចន្លោះពេលនៃកាលភូគព្ភសាស្ត្រ (interval of geological time)។<br>ឧ. យុគលោហៈ មានអាយុកាលចាប់ពី ២ ០០០ ឆ្នាំមុនគ.ស. រហូតមកដល់បច្ចុប្បន្ន។ |
| **១៧- យុគទឹកកក**<br>អ. Ice Age or Glacial Age<br>បារ. Période glaciaire | ដំណាក់កាលដែលផែនដីគ្របបណ្តប់មួយផ្នែកដោយទឹកកក គឺចាប់ផ្តើមពី ២លានឆ្នាំមកដល់ ១ម៉ឺនឆ្នាំមុនគ.ស.។ |
| **១៨- យុគថ្មបំបែក**<br>អ. Paleolithic<br>បារ. Paléolithique | ដំណាក់កាលដំបូងនៃសង្គមមនុស្សដែលចេះយកថ្មធម្មជាតិមកបំបែកធ្វើឧបករណ៍ប្រើប្រាស់។ ក្រៅពីឧបករណ៍ថ្ម មនុស្សក៏ចេះយកឆ្អឹង ស្នែង និង ឈើ ធ្វើជាឧបករណ៍ប្រើប្រាស់ផងដែរ។<br>ឧ. យុគថ្មបំបែកចាប់ផ្តើមដោយកំណើតមនុស្សដំបូងដែលមានអាយុកាលប្រហែលជា ១,៨លានឆ្នាំមុន រហូតដល់ប្រហែល១០ ០០០ឆ្នាំមុន គ.ស.។ |

| | |
|---|---|
| | ឧបករណ៍ថ្ម នៅស្ថានីយល្អាងស្ពាន<br> <br>បណ្ដាញព័ត៌មានវប្បធម៌ខ្មែរ www.khmerrenaissance.info |
| **១៩- យុគថ្មកណ្ដាល**<br>អ. Mesolithic<br>បារ. Mésolithique ( m. ) | ដំណាក់កាលអន្តរកាលចន្លោះយុគថ្មបំបែកនិងយុគថ្មរំលីងដែលនៅពេលនោះ មនុស្សយកបំណែកថ្មមកធ្វើជាឧបករណ៍ប្រើប្រាស់ ដោយមានការកែច្នៃនិងរចនាឧបករណ៍នោះ ជាច្រើនប្រភេទ។<br>ឧ. យុគថ្មកណ្ដាលចាប់ផ្ដើមពីប្រហែលជា ១០ ០០០ឆ្នាំមុនរហូតដល់ ប្រហែល ៨ ០០០ឆ្នាំមុនគ.ស.។<br><br>Aterian stone tool |
| **២០- យុគថ្មរំលីង**<br>អ. Neolithic<br>បារ. Néolithique ( m. ) | ដំណាក់កាលចុងក្រោយនៃយុគថ្ម ដែលនៅពេលនោះ មនុស្សកថ្មមកបំបែក ហើយ រំលីងឬសំលៀងធ្វើជាឧបករណ៍ប្រើប្រាស់។ នៅក្នុងយុគនេះ មនុស្សចេះធ្វើកសិកម្មផងដែរ។<br>ឧ. យុគថ្មរំលីងចាប់ផ្ដើមពីប្រហែលជា ៨ ០០០ឆ្នាំមុនគ.ស. រហូតដល់ ប្រហែល ៥ ០០០ឆ្នាំមុនគ.ស.។<br>ពូថៅថ្មរំលីងមកពីស្ថានីយសំរោងសែន<br> |
| **២១- យុគលោហៈ**<br>អ. Metal Age<br>បារ. Age des métaux | ដំណាក់កាលបន្ទាប់ពីយុគថ្មរំលីងដែលមនុស្សចេះយកលោហៈមកប្រើប្រាស់។ យុគលោហៈចែកចេញជាបី គឺយុគស្ពាន់, យុគសំរឹទ្ធ និង យុគដែក។<br>ឧ. យុគលោហៈនៅកម្ពុជាមានអាយុកាលតាំងពី១ ៥០០ឆ្នាំ មុនគ.ស.។ |

| | |
|---|---|
| | ឧបករណ៍ប្រើប្រាស់ធ្វើពីដែក<br>  |
| **២២- យុគស្ពាន់**<br>អ. Copper Age<br>បារ. Age du cuivre | ដំណាក់កាលដែលមនុស្សចេះយកស្ពាន់មកធ្វើជារូបធាតុដើមសម្រាប់ផលិតឧបករណ៍ប្រើប្រាស់ អាវុធ និង គ្រឿងអលង្ការ។<br>ឧ. យុគស្ពាន់គិតចាប់ផ្ដើមពី ៣ ៥០០ឆ្នាំ មក ២ ៣០០ឆ្នាំមុន គ.ស.។<br><br>Reconstruction of Ötzi's copper axe (c. 3300 BC) |
| **២៣- ស័កទី១**<br>អ. Paleozoic era<br>បារ. Paléozoïque /<br>Ère Primaire (f.) | ស័កភូគព្ភសាស្ត្រ (ère géologique) ដែលមានរយៈពេល២៩១លានឆ្នាំ (ពី៥៤២ ដល់ ២៥១លានឆ្នាំកន្លងទៅ ដែលគេនិយមហៅថា*ស័កមច្ឆជាតិ* (Ère des Poissons)។ |
| **២៤- ស័កទី២**<br>អ. Mesozoic era<br>បារ. Ère mésozoïque/<br>Ère secondaire (f.) | ស័កភូគព្ភសាស្ត្រពី២៥១លានឆ្នាំ ដល់៦៥លាន ឆ្នាំកន្លងទៅ។ លក្ខណៈសម្គាល់នៃស័កទី២នេះគឺការប្រែប្រួលយ៉ាងខ្លាំងខាងរុក្ខជាតិនិងសត្វ។ សត្វដាយណូស័រ(**Dinosaurs**) បានកើតនិងស្លាប់នៅក្នុងស័កនេះ។ ដូច្នេះហើយបានជាគេនិយមហៅស័កនេះថាជាស័កដាយណូស័រ។ |
| **២៥- ស័កទី៣**<br>អ. Cenozoic Era<br>បារ. Ère cénozoïque /<br>Ère tertiaire (f.) | ស័កភូគព្ភសាស្ត្រ ដែលបានចាប់ផ្ដើមពី៦៥លានឆ្នាំកន្លងទៅ។ ជួនកាល គេហៅស័កទី៣នេះថាជាស័ក*ថនិកសត្វ គឺសត្វចិញ្ចឹមកូននឹងទឹកដោះ* (Mammals)។ |
| **២៦- ស័កទី៤**<br>អ. Quaternary period<br>បារ. Ère quaternaire (f.) | ស័កភូគព្ភសាស្ត្រ ដែលបានចាប់ផ្ដើមពី២,៦លានឆ្នាំកន្លងទៅ។ ស័កនេះមានលក្ខណៈសម្គាល់ដោយការលេចឡើងនូវហូមីនីដ (Hominids) ជាថនិកសត្វទ្វេបាត(សត្វចិញ្ចឹមកូននឹងទឹកដោះមានជើងពីរ) និង ជាបុព្វបុរសរបស់មនុស្សបច្ចុប្បន្ន។ |
| **២៧- យុគដែក**<br>អ. Iron Age<br>បារ. Age du fer | ដំណាក់កាលដែលមនុស្សយកដែកមកប្រើប្រាស់បន្តពីសំរិទ្ធ។<br>ឧ. យុគដែកចាប់ផ្ដើមពី ១ ២០០ឆ្នាំមុនគ.ស.។ |

| | |
|---|---|
| | ឧបករណ៍ប្រើប្រាស់ធ្វើពីដែក<br> |
| **២៨- កាលសម័យបុរេប្រវត្តិ**<br>អ. Prehistoric Times<br>បារ. Temps préhistoriques (m.) | កាលសម័យដែលចាប់ផ្ដើមពីការកកើតមនុស្សលើផែនដីប្រហែល៥លានឆ្នាំមុននិងបញ្ចប់ដោយការបង្កើតអក្សរប្រហែលជាង៥០០០ឆ្នាំកន្លងទៅ។<br>ឧ. ប្រទេសអេហ្ស៊ីប និង មេសូប៉ូតាមី ឆ្លងផុតពីកាលសម័យបុរេប្រវត្តិ នៅឆ្នាំ ៣ ០០០មុនគ.ស.។ |
| **២៩- បុរេប្រវត្តិវិទ្យា**<br>អ. Prehistory / Prehistoric science<br>បារ. Préhistoire (science préhistorique) | វិទ្យាសាស្ត្រឬមុខវិជ្ជា(discipline)ដែលសិក្សាអំពីអ្វីៗដែលបានកើត ឡើងមុនពេលមនុស្សចេះប្រើប្រាស់អក្សរ។<br>ឧ. -ជំពូកថ្មីមួយក្នុងបុរេប្រវត្តិវិទ្យាខ្មែរ ឥឡូវនេះបានចាប់ផ្ដើមហើយ។<br>-បុរេប្រវត្តិវិទ្យាធ្វើការសិក្សាអំពីជីវភាពរបស់មនុស្សដំបូងៗ។ |
| **៣០- បុរេប្រវត្តិសាស្ត្រ**<br>អ. Prehistory<br>បារ. Préhistoire (f.) | កាលសម័យមុនមានឯកសារសរសេរ។<br>ឧ. ទេវកថាដែលមាននិទានតាំងពីបុរេប្រវត្តិសាស្ត្រ។ |
| **៣១- អ្នកបុរេប្រវត្តិសាស្ត្រ**<br>អ. Specialist in prehistory<br>បារ. Spécialiste en préhistoire | អ្នកជំនាញខាងបុរេប្រវត្តិវិទ្យា។ |
| **៣២- បុរេប្រវត្តិវិទូ**<br>អ. Prehistorian<br>បារ. Préhistorien (m.) | អ្នកប្រាជ្ញខាងបុរេប្រវត្តិវិទ្យា។<br>ឧ. លោកជាបុរេប្រវត្តិវិទូតែម្នាក់គត់ នៅក្នុងសាកលវិទ្យាល័យនេះ។ |
| **៣៣- បុរេប្រវត្តិ**<br>អ. Prehistoric<br>បារ. Préhistorique (adj.) | នៃបុរេប្រវត្តិសាស្ត្រ។<br>ឧ. ស្ថានីយបុរេប្រវត្តិជាច្រើនត្រូវបានរកឃើញនៅក្នុងប្រទេសកម្ពុជា (សំរោងសែន អន្លង់ផ្ដៅ ម្លូព្រៃ ល្អាងស្ពាន ...)។ |
| **៣៤- យុគទឹកកក**<br>អ. Ice Ages or Glacial Ages<br>បារ. Période glaciaire | កាលសម័យយ៉ាងយូរដែលទឹកកកបានគ្របដណ្ដប់លើផ្ទៃផែនដីក្នុងអតីតកាល។ យុគទឹកកកមាន៥ដំណាក់កាលៈ ទី១ប្រមាណ (២៤០០-២១០០ លានឆ្នាំមុន) (2.4-2.1 billion years ago), ទី២ (៨៥០-៦៣៥ លានឆ្នាំមុន (850- 635 million years ago), ទី៣ (៤៦០-៤៣០ លានឆ្នាំមុន) (460-430 million years ago), ទី៤ (៣៥០-២៥០ លានឆ្នាំ |

| | |
|---|---|
| | មុន) (350-250 million years ago) និង ទី៥ គឺចាប់ពីជាង២លានឆ្នាំមុន មកដល់ ១០ ០០០ឆ្នាំមុន។<br><br> |
| **៣៥- ដើមយុគថ្មបំបែក**<br>អ. Lower Palaeolithic<br>បារ. Paléolithique inférieur | ដំណាក់កាលដំបូងនៃបុរេប្រវត្តិសាស្ត្រ ដែលសម្គាល់ដោយការលេចឡើងនៃមនុស្សនៅទ្វីបអាហ្វ្រិក។ ដំណាក់កាលនេះសង្គមមនុស្សចេះច្នៃឧបករណ៍សាមញ្ញៗ ដោយគ្រាន់តែយកដុំថ្មមកបំបែកធ្វើជាពូថៅថ្ម សម្រាប់កាប់ឬចាំងឈើខ្លះៗ និង មានអាយុប្រហែល ៣ ៣០០ ០០០ឆ្នាំដល់ ៣០០ ០០០ ឆ្នាំមុន (around 3.3 million - 300,000 years ago)។<br><br>ពូថៅថ្ម- Paléolithique inférieur-Collection Noulet -Muséum de Toulouse |
| **៣៦- កណ្តាលយុគថ្មបំបែក**<br>អ. Middle Paleolithic<br>បារ. Paléolithique moyen | ដំណាក់កាលកណ្តាលនៃយុគថ្មបំបែក ដែលសង្គមមនុស្សចេះកែច្នៃឧបករណ៍ជាច្រើនពីបំណែកថ្មឱ្យទៅជាកាំបិតថ្ម ពូថៅថ្ម ខ្ទាសថ្ម និង ចាប់ប្រើឧបករណ៍ពីឈើ ស្នែង និង ឆ្អឹងផងដែរ។ ដំណាក់កាលនេះមានអាយុពី៣០០ ០០០ឆ្នាំដល់ ៣០ ០០០ឆ្នាំមុន (From 300,000 to 30,000 years ago)។<br>ឧ. ពូថៅថ្ម រកឃើញនៅស្ថានីយស្ពានស្វាយយូ នៅក្នុងភូមិរលួច ឃុំស្វាយ ជ្រះ ស្រុកក្រចេះ ខេត្តក្រចេះ។<br>(ធុយ ចាន់ធួន និង អាល់ប្រិច១៩៩៦)<br><br> |
| **៣៧- ចុងយុគថ្មបំបែក**<br>អ. Upper Palaeolithic, Late Stone Age | ដំណាក់កាលចុងក្រោយនៃយុគថ្មបំបែក ដែលសង្គមមនុស្សចេះកែច្នៃឧបករណ៍ជាច្រើនពីបំណែកថ្ម និងមានការប្រើកម្ទេចថ្មតូចៗសម្រាប់ស៊កឬសៀតនឹងឆ្អឹងសត្វ ធ្វើជាដំបង។ មនុស្សចាប់ផ្តើមមានជំនឿ។ ដំណាក់កាលនេះមាន |

| | |
|---|---|
| បារ. Paléolithique supérieur | អាយុពី ៣០ ០០០ឆ្នាំដល់ ១០ ០០០ឆ្នាំមុន (From 30,000 to 10,000 years ago)។<br>ឧ. រូបចម្លាក់ព្រះនាង វេនូស ឡូសែល (Venus of Laussel) ក្នុងសម័យកាលចុងយុគថ្មបំបែក មកពីស្ថានីយឡូសែល ប្រទេសបារាំង (Venus of Laussel, an Upper Paleolithic carving)។<br> |
| **៣៨- ឯកសារគ**<br>អ. Non-written record<br>បារ. Document muet<br>(m.) | ឯកសារដែលគ្មានការកត់ត្រាជាលាយលក្ខណ៍អក្សរ ដូចជា ក្អម ផ្ទាំង និងវត្ថុសិល្បៈផ្សេងៗទៀត។<br>ប្រភេទឯកសារគ<br>   |
| **៣៩- ឯកសារសរសេរ**<br>អ. Written record<br>បារ. Document écrit<br>(m.) | ឯកសារជាលាយលក្ខណ៍អក្សរដែលកត់ត្រានូវហេតុការណ៍ឬព្រឹត្តិការណ៍នានាទុកជាចំណេះដឹង។<br>ឧ. សិលាចារឹកជាប្រភេទឯកសារសរសេរ។<br> |
| **៤០- ប្រវត្តិវិទ្យា**<br>អ. History<br>បារ. Histoire (f.)<br>(science historique) | វិទ្យាសាស្ត្រឬមុខវិជ្ជា (discipline) ដែលសិក្សាអំពីអ្វីៗដែលបានកើតឡើងចាប់ពីពេលមនុស្សចេះប្រើប្រាស់អក្សរ។ |

| | |
|---|---|
| **៤១- ប្រវត្តិសាស្ត្រ**<br>អ. History<br>បារ. Histoire (f.) | កម្រងនៃចំណេះដឹងដែលកត់ត្រានិងវិភាគព្រឹត្តិការណ៍អតីតកាល។ |
| **៤២- កាលសម័យ ប្រវត្តិសាស្ត្រ**<br>អ. Historic times<br>បារ. Période historique (f.) | ដំណាក់កាលនៃប្រវត្តិសាស្ត្រចាប់ពីមនុស្សចេះប្រើអក្សរនិងរក្សាទុកឯកសារសរសេរ។<br>ឧ. កាលសម័យប្រវត្តិសាស្ត្រចាប់ផ្ដើមពី ៣ ០០០ ឆ្នាំមុនគ.ស. ដោយផ្អែកលើឯកសារសរសេរនៅអេហ្ស៊ីបនិងមេសូប៉ូតាមី។ |
| **៤៣- បុរាណសម័យ**<br>អ. Ancient Times<br>បារ. Antiquité (f.) | ដំណាក់កាលនៃប្រវត្តិសាស្ត្រចាប់ពី ៣ ០០០ ឆ្នាំមុនគ.ស. រហូតដល់ គ.ស. ៥០០។<br>ឧ. ការដួលរលំនៃចក្រភពរ៉ូមខាងលិចនៅគ.ស. ៤៧៦ ជាចុងបញ្ចប់នៃបុរាណសម័យ។ |
| **៤៤- មជ្ឈិមសម័យ**<br>អ. Middle Age<br>បារ. Moyen Age (m.) | ដំណាក់កាលនៃប្រវត្តិសាស្ត្រសកលលោកចាប់ពីគ.ស. ៥០០ រហូតដល់ គ.ស. ១ ៥០០។<br>ឧ. ការរកឃើញទ្វីបអាម៉េរិកដោយលោកគ្រីស្តូហ្វ កូឡុំ (Christopher Colombus) នៅគ.ស. ១៤៩២ ជារយៈពេលចុងក្រោយនៃមជ្ឈិមសម័យ។ |
| **៤៥- បុនសម័យ**<br>អ. Renaissance<br>បារ. Renaissance (f.) | ដំណាក់កាលនៃប្រវត្តិសាស្ត្រចន្លោះស.វ.ទី១៤ និង ទី១៧ នៃគ.ស. តាមរយៈ ការរស់ឡើងវិញនៃតម្លៃវប្បធម៌អឺរ៉ុបនិងការលេចឡើងនូវគំនិតភ្លឺស្វាង (ទស្សនវិជ្ជាពន្លឺ) របស់ទស្សនវិទូនៅទ្វីបអឺរុប។<br>ឧ. Leonardo da Vinci, ជាអ្នកប្រាជ្ញអ៊ីតាលី នៃបុនសម័យ។ |
| **៤៦- នវសម័យ**<br>អ. Modern Times<br>បារ. Temps modernes (m.) | ដំណាក់កាលនៃប្រវត្តិសាស្ត្រចាប់ពីគ.ស.១៤៩២ ឬ ១៥០០ រហូតដល់បដិវត្តន៍បារាំងឆ្នាំ១៧៨៩ ឬ ដល់ពេលបច្ចុប្បន្ន។<br>- តាមប្រវត្តិវិទូបារាំង ១៤៩២(គ្រីស្តូហ្វ កូឡុំ Christopher Colombus រកឃើញទ្វីបអាម៉េរិក) ដល់ ១៧៨៩ (បដិវត្តន៍បារាំង)។<br>- តាមប្រវត្តិវិទូអាម៉េរិក ១៥០០ (គ្រីស្តូហ្វ កូឡុំ Christopher Colombus រកឃើញទ្វីបអាម៉េរិក តែមានការសម្រួលកាលបរិច្ឆេទដោយយកឆ្នាំ ១៥០០) ដល់បច្ចុប្បន្ន។ |
| **៤៧- សហសម័យ**<br>អ. Contemporary Epoch<br>បារ. Epoque contemporaine (f.) | ដំណាក់កាលនៃប្រវត្តិសាស្ត្រចាប់ពីគ.ស.១៧៨៩ ឬ ១៩១៧ រហូតដល់បច្ចុប្បន្ន។<br>- តាមប្រវត្តិវិទូបារាំង ចាប់ពីគ.ស. ១៧៨៩(បដិវត្តន៍បារាំង) រហូតដល់បច្ចុប្បន្ន។<br>- តាមប្រវត្តិវិទូសូវៀត ចាប់ពីគ.ស. ១៩១៧ (បដិវត្តន៍ខែតុលា) រហូតដល់បច្ចុប្បន្ន។ |

| | |
|---|---|
| **៤៨- មនុស្សបុរេប្រវត្តិ**<br>អ. Prehistoric man (human)<br>បារ. Homme préhistorique (m.) | មនុស្សដែលរស់នៅក្នុងកាលសម័យបុរេប្រវត្តិ។<br>ឧ. មនុស្សបុរេប្រវត្តិ មានឈ្មោះផ្សេងៗតាមលំដាប់នៃការវិវត្ត ដូចជា អូស្ត្រាឡូពីតែក (Australopithèques) ហូម៉ូហាប៊ីលីស (Homo Habilis) ហូម៉ូអេរិចទូស (Homo Erectus) ហូម៉ូនេអង់ឌែតាល់ (Homo neandertalensis) ហូម៉ូសាព្យាង (Homo Sapiens) ជាដើម។<br><br>Prehistoric Humans |
| **៤៩- អូស្ត្រាឡូពីតែក**<br>អ. Australopithecus<br>បារ. Australopithèques | មនុស្សបុរេប្រវត្តិដំបូងបង្អស់រស់នៅអេត្យូពី ទ្វីបអាហ្វ្រិក(Ethiopie, Afrique) កាលពី៣ ទៅ ៤លានឆ្នាំមុន ដែលគេបានរកឃើញសំណល់ឆ្អឹងនៅឆ្នាំ ១៩៧៤។ **លលាដ៍ក្បាលអូស្ត្រាឡូពីតែក**<br> |
| **៥០- ហូម៉ូហាប៊ីលីស**<br>អ. Homo Habilis<br>បារ. Homme habile (m.) | មនុស្សបុរេប្រវត្តិដំបូងដែលវិវត្តបន្តពីអូស្ត្រាឡូពីតែក ហើយ ចេះយកថ្មមកធ្វើជាឧបករណ៍ប្រើប្រាស់។ ពួកគេរស់នៅអាហ្វ្រិកខាងកើតជាក្រុមៗ មានកម្ពស់១,៤០ម៉ែត្រ និង មានទម្ងន់ចន្លោះពី៣០និង៤០គ.ក្រ.។<br>ហូម៉ូហាប៊ីលីស មានន័យថា មនុស្សប៉ិនប្រសប់ (Homme habile)។<br>លលាដ៍ក្បាលហូម៉ូហាប៊ីលីស<br> |
| **៥១- ហូម៉ូអេរិចទូស**<br>អ. Homo Erectus | មនុស្សបុរេប្រវត្តិ ដែលវិវត្តបន្តពីហូម៉ូហាប៊ីលីស (Homme habile) ហើយ គេបានរកឃើញនៅទ្វីបអាហ្វ្រិក (ពីព្រោះជាទ្វីបដែលមានកម្តៅជាងគេ នៅសម័យដែលភពផែនដីត្រជាក់ខ្លាំង)។ ហូម៉ូអេរិចទូស មានមាឌធំជាងមុន |

| | |
|---|---|
| បារ. Homo Erectus<br>(Homme debout) (m.) | មានកម្ពស់ប្រហែល១,៥០ម៉ែត្រ និង មានទម្ងន់ប្រហែល ៥០គ.ក្រ.។ ហូម៉ូអេរិចទូស ដែលមានន័យថាមនុស្សឈរ (Homme debout) បានរកឃើញភ្លើងកាលពី៥០០ ០០០ឆ្នាំមុន។<br>លលាដ៍ក្បាលហូម៉ូអេរិចទូស<br><br> |
| **៥២- ហូម៉ូនេអង់ឌែតាល់**<br>អ. Homo neandertalensis<br>បារ. Homo neandertalensis<br>(L'homme de Néanderthal) | មនុស្សបុរេប្រវត្តិដែលវិវត្តបន្តពីហូម៉ូអេរិចទូស (Homo Erectus) ហើយ គេបានរកឃើញនៅជ្រលងភ្នំនេអង់ឌែតាល់ (ប្រទេសអាល្លឺម៉ង់)។ ហូម៉ូនេអង់ឌែតាល់មានកម្ពស់ប្រហែល ១,៧០ម៉ែត្រ (បុរស) និង១,៦០ម៉ែត្រ (ស្ត្រី)។ បុរសមានទម្ងន់ ប្រហែល ១០០គ.ក្រ.។<br>លលាដ៍ក្បាលហូម៉ូនេអង់ឌែតាល់<br><br> |
| **៥៣- ហូម៉ូសាព្យាង**<br>អ. Homo Sapiens<br>បារ. Homo Sapiens<br>(L'homme qui pense) | មនុស្សបុរេប្រវត្តិ ដែលវិវត្តបន្តពីហូម៉ូនេអង់ឌែតាល់ (Homo neandertalensis) ចេញដំណើរពីទ្វីបអាហ្វ្រិក ហូម៉ូសាព្យាង ទៅរស់នៅក្នុងទ្វីបអឺរ៉ុប និង ទ្វីបដទៃទៀត។ ហូម៉ូសាព្យាង មានន័យថា មនុស្សចេះគិត (L'homme qui pense)។<br>លលាដ៍ក្បាលហូម៉ូសាព្យាង<br><br> |

| | |
|---|---|
| **៥៤- មនុស្សក្រូម៉ាញ៉ុង**<br>អ. Cro-Magnon man<br>បារ. Homme de Cro-Magnon (m.) | មនុស្សទំនើបដំបូងនៅទ្វីបអឺរ៉ុបក្នុងយុគថ្មបំបែកដែលគេរកឃើញផូស៊ីលដំបូងនៅប្រទេសបារាំង មានអាយុកាលប្រហែល ៤៣ ០០០ឆ្នាំមុន។ ទំហំខួរក្បាលប្រហែលជា ១ ៦០០សង់ទីម៉ែត្រគូប ដែលធំជាងទំហំខួរក្បាលមនុស្សទូទៅបច្ចុប្បន្ន (១ ៤៦៦សង់ទីម៉ែត្រគូប)។<br><br>Reconstruction of a Cro-Magnon woman and child. |
| **៥៥- មនុស្សប៉េកាំង**<br>អ. Peking man<br>បារ. Homme de Pékin (m.) | មនុស្សដែលគេបានរកឃើញផូស៊ីល ដោយការធ្វើកំណាយដំបូងនៅជូគូទៀន (Zhoukoudian) ក្បែរប៉េកាំងប្រទេសចិន ចន្លោះឆ្នាំ១៩២៣-១៩២៧ ដែលមានអាយុកាលប្រហែល ៧៥០ ០០០ឆ្នាំមុន។ ក្នុងការធ្វើកំណាយជាច្រើនលើកក្រោយមក គេរកឃើញទំហំខួរក្បាលខុសៗគ្នា។ កំណាយនៅឆ្នាំ១៩៣៦ រកឃើញថា ខួរក្បាលមនុស្សប្រុសពេញវ័យមានទំហំ ១ ២២៥សង់ទីម៉ែត្រគូប មនុស្សស្រីពេញវ័យមានទំហំ ១ ០១៥សង់ទីម៉ែត្រគូប យុវជនវ័យជំទង់ប្រុសមានទំហំ ១ ០៣០សង់ទីម៉ែត្រគូប។<br><br>Forensic facial reconstruction of Homo erectus pekinensis |
| **៥៦- មនុស្សជ្វា**<br>អ. Java man<br>បារ. Homme de Java (m.) | មនុស្សដែលគេបានរកឃើញផូស៊ីលនៅឆ្នាំ១៨៩១ នៅទ្រីនីលង៉ាវី (Trinil Ngawi) ជ្រលងទន្លេសូឡូជ្វាភាគខាងកើតឥណ្ឌូនេស៊ីមានអាយុកាលប្រហែល ១ ៨១០ ០០០-១ ៦៦០ ០០០ឆ្នាំ។<br><br>A 1922 reconstruction of the skull of Java Man (based on Trinil 2). |

| | |
|---|---|
| **៥៧- មនុស្សរូងភ្នំ**<br>អ. Cave-dweller<br>បារ. Homme des cavernes | មនុស្សបុព្វកាលដែលយករូងធម្មជាតិជាជម្រករស់នៅ ។<br>ឧ. នៅចន្លោះឆ្នាំ១៩៦៥ និង ឆ្នាំ១៩៦៩ លោក កាបូណែល (Cabonnel) និង លោក ដាលីប្រ៊ីយ៉ាស (Dalibrias) បានធ្វើការរុករកក្នុងរូងភ្នំដែលជាជម្រករបស់មនុស្សបុរេប្រវត្តិ នៅភ្នំក្បាលរមាស ខេត្តកំពត។ |
| **៥៨- អរិយជន / អារ្យជន**<br>អ. Civilized people<br>បារ. Peuple civilisé (m.) | ជនរស់នៅក្នុងរដ្ឋ ដែលមានប្រព័ន្ធគ្រប់គ្រង វប្បធម៌ និង របៀបរស់នៅជឿនលឿន។<br>ឧ. នៅក្នុងបណ្តាប្រទេសជឿនលឿនមានអរិយជនច្រើន។ |
| **៥៩- អនរិយជន / អនារ្យជន**<br>អ. Barbarian<br>បារ. Barbare (m./f.) | ជនរស់នៅក្នុងសង្គម ដែលមិនមានប្រព័ន្ធគ្រប់គ្រង វប្បធម៌ និង របៀបរស់នៅជឿនលឿន។<br>ឧ. ពួករ៉ូម៉ាំងបានប្រើពាក្យ «អនរិយជន/អនារ្យជន» សម្រាប់ហៅក្រុមមនុស្សមួយចំនួនដូចជា កុលសម្ព័ន្ធអាល្លឺម៉ង់ (Germanics) សែលធ៍ (celts) អ៊ីបេរី (Iberians) ត្រាស៊ី (Thracians) និងប៉ាស្សឺ (Parthians) ជាដើម។ |
| **៦០- ទាសភាព**<br>អ. Slavery<br>បារ. Esclavage | ភាពជាម្ចាស់កម្មសិទ្ធិរបស់មនុស្សម្នាក់ទៅលើមនុស្សផ្សេងទៀតទាំងជីវិត និងពលកម្ម ដោយចាត់ទុកជាទ្រព្យសម្បត្តិរបស់ខ្លួនដែលអាចទិញនិងលក់បាន។ ទាសភាពមានការជាប់ទាក់ទងយ៉ាងជិតស្និទ្ធទៅលើបុរេវិនិច្ឆ័យខាងជាតិសាសន៍ ពណ៌សម្បុរ ដែលគេយល់ថា ជាតិសាសន៍មួយមានឧត្តមភាពលើជាតិសាសន៍មួយផ្សេងទៀត។ |
| **៦១- ទាសករ**<br>អ. Slave<br>បារ. Esclave | មនុស្សដែលត្រូវបានគេគ្រប់គ្រង លក់ដូរ និង បង្ខំឱ្យធ្វើការគ្រប់បែបយ៉ាងដោយគ្មានលក្ខខណ្ឌដើម្បីផលប្រយោជន៍ម្ចាស់ទាសករ ហើយ សូម្បីតែជីវិតរបស់ខ្លួនក៏គ្មានកម្មសិទ្ធិដែរ។<br>ឧ. រូបភាពស្តីពីទាសករកំពុងធ្វើការក្នុងអណ្តូងរ៉ែ នៅក្រិកបុរាណ។<br> |
| **៦២- ផ្លូវសូត្រ**<br>អ. Silk road<br>បារ. route de la soie | បណ្តាញផ្លូវពាណិជ្ជកម្មតភ្ជាប់រវាងទ្វីបអាស៊ី អឺរ៉ុប និងអាហ្វ្រិក ដែលលាតសន្ធឹងចម្ងាយ១០ ០០០ គីឡូម៉ែត្រ ពីឆ្នាំ២០៦ មុនគ.ស. ដល់ឆ្នាំ២២០នៃគ.ស. តាមរយៈការធ្វើពាណិជ្ជកម្មសូត្រចិនយ៉ាងសន្ធឹកសន្ធាប់។<br>មួយផ្នែកនៃផ្លូវពាណិជ្ជកម្មនេះនៅអាស៊ីកណ្តាលត្រូវបានពង្រីកនៅឆ្នាំ១១៤ មុនគ.ស. ដោយសន្តតិវង្សហាន។ ពាណិជ្ជកម្មតាមផ្លូវសូត្រ ជាកត្តាជំរុញដ៏ចម្បងក្នុងការអភិវឌ្ឍអរិយធម៌ចិន ឥណ្ឌា ពែក្ស អឺរ៉ុប និងអារ៉ាប់។ |

| | |
|---|---|
| | ផ្លូវនេះក៏បាននាំមកនូវ បច្ចេកវិទ្យា សាសនា ទស្សនវិជ្ជា និង ជំងឺរាតត្បាត ផ្សេងៗ។ ផែនទីបណ្តាញផ្លូវសូត្រ<br><br> |
| **៦៣- សក្តិភូមិ**<br>អ. feudalism<br>បារ. féodalité | ការគ្រប់គ្រងរដ្ឋដោយព្រះរាជាដែលភាគច្រើនផ្អែកលើច្បាប់សាសនា ដែលក្នុងនោះដីធ្លី និង ប្រជាជនជាកម្មសិទ្ធិផ្តាច់មុខរបស់ព្រះអង្គ។<br>២. របបសក្តិភូមិបានចាប់ផ្តើមនៅអឺរ៉ុបខាងលិចនៅក្នុងអំឡុងសតវត្សរ៍ទី៩ និងឈានដល់ចំណុចកំពូលនៅសតវត្សរ៍ទី១២និង១៣។ |
| **៦៤- អរិយធម៌បុរាណ**<br>អ. Ancient Civilization<br>បារ. Civilisation antique | អរិយធម៌ជាមូលដ្ឋានគ្រឹះនៃពិភពលោកបច្ចុប្បន្នដែលត្រូវបានកសាងឡើងនៅបុរាណសម័យ នៅតាមសំណង់នានាដែលជាវប្បធម៌ជឿនលឿនរបស់ពួកអេហ្ស៊ីប មេសូប៉ូតាមី ឥណ្ឌា ចិន ក្រិក រ៉ូម៉ាំង ម៉ាយ៉ា និង ជនជាតិដទៃទៀត ដែលយើងអាចដឹងបានដោយសារ បុរាណវត្ថុវិទ្យា និង ឯកសារសរសេរ។ |
| **៦៥- ជំនួញទាសករ**<br>អ. Slave trade<br>បារ. commerce des esclaves / Traite des Noirs | អំពើជួញដូរមនុស្សដែលកើតមាននៅមហាសមុទ្រអាត្លង់ទិកនិងទ្វីបអាហ្វ្រិក ចាប់ពីស.វ.ទី១៥ ដល់ស.វ.ទី១៩។ ជំនួញនេះបានកើតឡើងដោយជនជាតិអឺរ៉ុបទិញមនុស្សពីទ្វីបអាហ្វ្រិក ហើយ នាំយកទៅធ្វើជាទាសករនៅទ្វីបអាម៉េរិក និង នៅតាមចម្ការអាណានិគម។<br>២. ក្មេងជំទង់ៗរងចាំឡើងកប៉ាល់ទៅធ្វើទាសករនៅក្រៅប្រទេសដែលជាសកម្មភាពនៃជំនួញទាសករ។<br> |
| **៦៦- ប្រព័ន្ធវណ្ណៈ**<br>អ. Caste system<br>បារ. système des castes | ការចែកវណ្ណៈសង្គមនៅក្នុងសាសនាហិណ្ឌូ ដែលបានចាប់ផ្តើមនៅឆ្នាំ៧០០ មុនគ.ស. ក្នុងនោះមានវណ្ណៈ៤គឺ ព្រាហ្មណ៍ ក្សត្រិយ៍ វៃស្យៈ និងសូទ្រៈ។ ក្រៅពីវណ្ណៈទាំងបួននេះមានពួកចណ្ឌាលដែលជាមនុស្សកើតចេញពីបិតាវណ្ណៈសូទ្រៈនិងមាតាវណ្ណៈព្រាហ្មណ៍។ |
| **៦៧- វណ្ណៈព្រាហ្មណ៍**<br>អ. Brahmin | នៅប្រទេសឥណ្ឌា គឺជាវណ្ណៈទីមួយក្នុងសាសនាហិណ្ឌូ រួមមាន អ្នកបួស សាស្ត្រាចារ្យ និង អ្នកថែរក្សាចំណេះដឹងពិសិដ្ឋនិងទំនៀមទម្លាប់សាសនា |

| | |
|---|---|
| បារ. Brahmin | ពីជំនាន់មួយទៅជំនាន់មួយទៀត។<br>នៅប្រទេសកម្ពុជាសម័យបច្ចុប្បន្ន គេបានកំណត់ពួកបារគូបុរោហិតក្នុងព្រះបរមរាជវាំងថា ជាពួកព្រាហ្មណ៍។ |
| **៦៨- វណ្ណៈក្សត្រិយ៍**<br>អ. kshatriya<br>បារ. kshatriya | នៅប្រទេសឥណ្ឌា គឺជាវណ្ណៈទីពីរតាមប្រពៃណីនៃសាសនាហិណ្ឌូ រួមមានអ្នកដឹកនាំនិងវីរជនយោធា ដែលបានកំណត់នៅក្នុងប្រព័ន្ធសង្គមនៃគម្ពីរវេទ ដោយមានភារកិច្ចការពារនិងដឹកនាំសង្គមហិណ្ឌូ។<br>ចំណែកក្នុងសង្គមខ្មែរវិញ «វណ្ណៈក្សត្រិយ៍» ជាវង្សក្សត្រ ដែលជាថ្នាក់ទី១នៃសង្គម សំដៅទៅលើព្រះមហាក្សត្រនិងព្រះរាជវង្សានុវង្ស។ |
| **៦៩- វណ្ណៈវៃស្យៈ**<br>អ. Vaishya<br>បារ. Vaishya | នៅប្រទេសឥណ្ឌា គឺជាវណ្ណៈទីបីតាមប្រពៃណីនៃសាសនាហិណ្ឌូ រួមមានអ្នកចិញ្ចឹមសត្វ អ្នកធ្វើស្រែចម្ការ សិប្បករ ពលករ អ្នកជំនួញ ជាដើម។<br><br>អ្នកលក់ដូរផលិតផលក្នុងសង្គមឥណ្ឌា ដែលស្ថិតក្នុងវណ្ណៈវេស្សៈ។ |
| **៧០- វណ្ណៈសូទ្រៈ**<br>អ. Shudra<br>បារ. Shudra | នៅប្រទេសឥណ្ឌា គឺជាវណ្ណៈទីបួនតាមប្រពៃណីនៃសាសនាហិណ្ឌូ រួមមានអ្នកបម្រើវណ្ណៈព្រាហ្មណ៍ ក្សត្រិយ៍ និង វៃស្យៈ។ |
| **៧១- សាមន្តរាជ**<br>អ. Vassal<br>បារ. Vassal (m.) | ស្តេចចំណុះដែលស្ថិតនៅក្រោមអំណាចអធិរាជ។ សាមន្តរាជត្រូវនាំសួយសារអាករទៅថ្វាយអធិរាជជាប្រចាំ។<br>ឧ. មុនឆ្នាំ៥៥០ នៃគ.ស. ស្តេចសាមន្តរាជនៃនគរចេនឡាតែងតែនាំសួយសារអាករថ្វាយអធិរាជនគរភ្នំ។ |
| **៧២- សាមន្តរដ្ឋ**<br>អ. Vassal State<br>បារ. Etat vassal (m.) | រដ្ឋនានាដែលចំណុះឱ្យចក្រភពណាមួយមានអំណាចខ្លាំង។<br>ឧ. នគរចម្ប៉ាជាសាមន្តរដ្ឋរបស់ចក្រភពអង្គរក្នុងសម័យព្រះបាទជ័យវរ្ម័នទី៧។ |
| **៧៣- អធិរាជ**<br>**អ.** Emperor<br>**បារ.** Empereur (m.) | មហាក្សត្រឬមហារាជដែលមានអំណាចលើសាមន្តរាជនានានិងគ្រប់គ្រងលើដែនដីចក្រភពទាំងមូល។<br>ឧ. គូប្លៃខាន់(Kublai Khan) ជាអធិរាជនៃចក្រភពម៉ុងហ្គោល (ឆ្នាំ១២៦០-១២៩៤ នៃគ.ស.)។ |

| | |
|---|---|
| | <br>អធិរាជ គូប្លៃខាន់ (Kublai Khan) |
| **៧៤- ចក្រវាលទិន /**<br>**ចក្កវាឡទិន**<br>**ឬ ស្តេចចក្រវាល**<br>អ. Universal Monarch<br>បារ. Monarque universel | ព្រះរាជាដែលគ្រប់គ្រងលើចក្រភព។ |
| **៧៥- ទេវរាជ**<br>អ. God King<br>បារ. Dieu-Roi (m.) | ព្រះរាជាដែលបង្កើតអំណាចទិព្វ ជាអាទិទេពផងនិងមនុស្សលោកផង ដើម្បីមានអំណាចខាងស្មារតីលើសាមន្តរាជ។<br>ឧ. នៅឆ្នាំ៨០២ ព្រះបាទជ័យវរ្ម័នទី២ បានបង្កើតលទ្ធិទេវរាជនៅមហេន្ទ្របវ៌ត (ភ្នំគូលេន)។ |
| **៧៦- ចក្រភព**<br>អ. Empire<br>បារ. Empire (m.) | ប្រទេសឬរដ្ឋច្រើនដែលបញ្ចូលគ្នា ហើយ គ្រប់គ្រងដោយអធិរាជឬរដ្ឋាភិបាលមួយ ដែលរចនាសម្ព័ន្ធគ្រប់គ្រងនយោបាយត្រូវបានបង្កើតឡើងនិងគ្រប់គ្រងតាមមធ្យោបាយពីរយ៉ាង៖<br>១- ចក្រភពតាមគោលការណ៍ទឹកដី ផ្អែកលើការឈ្លានពាននិងត្រួតត្រាទឹកដីដោយប្រើកម្លាំងយោធា។<br>២- ចក្រភពបែបអនុត្តរភាពនិយមតាមការបង្ខិតបង្ខំ ដែលត្រួតត្រាមិនផ្ទាល់តាមរយៈអំណាច។<br>ឧ. ចក្រភពអង្គរចាប់ផ្តើមនៅដើមសតវត្សរ៍ទី៩ ដល់ពាក់កណ្តាលសតវត្សរ៍ទី១៥នៃគ.ស.។ |
| **៧៧- ចក្រភពអេហ្ស៊ីប**<br>អ. Egyptian Empire<br>បារ. Empire d'Egypte (m.) | រដ្ឋដែលមានអត្ថិភាពប្រមាណពីឆ្នាំ១៥៥០មុនគ.ស.ដល់ឆ្នាំ១០៧៧មុនគ.ស.។ ចក្រភពនេះបង្កើតឡើងដោយបានវាយដណ្តើមយកទឹកដីបាប៊ីឡូន (Babylone) ពែក (Perse) អាស៊ីរី (Assyrie) លីប៊ី (Libye) គូស (Koush) និង ហ៊ីទីត (Hitittes)។ រាជធានីចក្រភពនេះ គឺទីក្រុងតែប (Thèbes) អាកេតាតង់ (Akhetaten) ពី-រ៉ាមេស (Pi-Ramesses) និង ម៉មភីស (Memphis)។ ពួកគេកាន់សាសនាអេហ្ស៊ីបបុរាណនិងសាសនាអាតេនីស (Athenism) និង ប្រើភាសាអេហ្ស៊ីបបុរាណ នូប៊ី (Nubie) ហើយនិង កាណានីត (Canaanite)។ |

| | |
|---|---|
| | អតីតចក្រភពអេហ្ស៊ីបនេះបានក្លាយទៅជាប្រទេស អេហ្ស៊ីប(Egypte) ស៊ូដង់(Soudan) លីប៊ី(Libye) ប៉ាឡេស្ទីន(Palestine) អ៊ីស្រាអែល (Israel) លីបង់(Liban) ស៊ីរី(Syrie) និង ហ្ស៊កដានី(Jordanie)។<br><br><br>ចក្រភពអេហ្ស៊ីបបុរាណក្នុងអំឡុងសតវត្សរ៍ទី១៥មុនគ.ស. |
| **៧៨- ចក្រភពបាប៊ីឡូន**<br>អ. Babylonian Empire<br>បារ. Empire babylonien (m.) | រដ្ឋដែលមានអត្ថិភាពប្រមាណពីឆ្នាំ១៨៩៥ដល់ឆ្នាំ១៥៩៥មុនគ.ស.។ ចក្រ-ភពនេះបានបង្កើតឡើងដោយជនជាតិអាកាដ(Akkad)បុរាណ និងមានមូលដ្ឋាននៅតំបន់មេសូប៉ូតាមីភាគកណ្ដាល (បច្ចុប្បន្នគឺប្រទេសអ៊ីរ៉ាក់និងប្រទេសនៅជាប់ឈូងសមុទ្រពែក)។ ចក្រភពនេះរីកចម្រើនដល់កំពូលក្នុងរាជ្យស្ដេចហាំមួរ៉ាប៊ី (Hammourabi) ពីឆ្នាំ១៧៩២ ដល់ឆ្នាំ១៧៥២មុនគ.ស. ហើយ មានរាជធានីនៅបាប៊ីឡូន។ ពួកគេគោរពសាសនាឯកទេពនិយម ដោយមិនបដិសេធ ពហុទេពនិយម(Henotheism) និងប្រើប្រាស់ភាសាអាកាដ(Akkad) ព្រមទាំងភាសាអារ៉ាម៉េអង់(araméen) ដែលស្ថិតក្នុងអំបូរភាសាអាហ្វ្រិក-អាស៊ី។<br><br><br>ផែនទីចក្រភពបាប៊ីឡូន |

| | |
|---|---|
| **៧៩- ចក្រភពពែរ្ស**<br>អ. Persian Empire<br>បារ. Empire perse (m.) | ចក្រភពមួយដែលមានប្រទេសពែរ្ស(អ៊ីរ៉ង់) ជាមជ្ឈមណ្ឌល។ ចក្រភព ពែរ្ស ដំបូងត្រូវបានបង្កើតឡើងដោយស៊ីរូសមហារាជ (Cyrus le Grand) នៅឆ្នាំ ៥៥០មុនគ.ស.។ សន្តតិវង្សពែរ្សត្រូវបានកាត់ផ្តាច់ដោយការវាយដណ្តើមពីពួកអ៊ិស្លាមនៅគ.ស.៦៥១ ហើយ សន្តតិវង្សអ៊ិស្លាមបានចូលមកបន្តនៅសម័យបន្ទាប់មក។ នៅក្នុងសម័យទំនើបសន្តតិវង្សអ៊ិស្លាមនានាបានគ្រប់គ្រងប្រទេសអ៊ីរ៉ង់ ហើយ ចាប់ពីឆ្នាំ១៩៧៩ ប្រទេសអ៊ីរ៉ង់បានក្លាយជាសាធារណរដ្ឋអ៊ិស្លាម។<br><br><br>ផែនទីនៃចក្រភពពែរ្ស |
| **៨០- ចក្រភពរ៉ូម**<br>អ. Roman Empire<br>បារ. Empire romain (m.) | រដ្ឋដែលមានអត្ថិភាពពីឆ្នាំ២៧មុនគ.ស.ដល់ឆ្នាំ៤៧៦នៃគ.ស. និង ស្ថិតក្រោមការដឹកនាំរបស់អធិរាជ អូហ្គុស (Auguste)។ ចក្រភពនេះបានរីកចម្រើនដល់កំពូលនាឆ្នាំ១១៧នៃគ.ស. ក្នុងរាជ្យស្តេច ត្រាហ្សង់(Trajan) ដោយមានផ្ទៃដីទំហំ ៥ ០០០ ០០០ គ.ម.$^{២}$ ហើយ គ្របដណ្តប់លើតំបន់ជុំវិញសមុទ្រមេឌីទែរ៉ាណេ(Méditerranée) មួយផ្នែកនៃទ្វីបអឺរ៉ុប អាហ្វ្រិក និង អាស៊ី។ ពួកគេគោរពសាសនារ៉ូមបុរាណនិងបន្ទាប់មកកាន់សាសនាគ្រិស្ត។ រាជធានីនៃចក្រភពនេះគឺរ៉ូម(Rome) និង កុងស្តង់ទីណូប(Constantinople)។ ពួកគេប្រើភាសាឡាតាំង និងភាសាក្រិកបុរាណ។ ចក្រភពរ៉ូមបានបែងចែកជាពីរនៅឆ្នាំ៣៩៥នៃ គ.ស. គឺចក្រភពរ៉ូមខាងលិចនិងរ៉ូមខាងកើត។ ចក្រភពរ៉ូមខាងលិចបានដួលរលំនៅឆ្នាំ៤៧៦ ឯចក្រភពរ៉ូមខាងកើតបន្តស្ថិតស្ថេរហូតដល់ឆ្នាំ១៤៥៣។ ចក្រភពរ៉ូមជាមហាអំណាចសេដ្ឋកិច្ច វប្បធម៌ នយោបាយ និង យោធាដ៏ធំបំផុតមួយក្នុងពិភពលោកនាសម័យនោះ។ |

| | |
|---|---|
| | <br>ចក្រភពរ៉ូមបានបែងចែកជាពីរ នៅគ.ស.៣៩៥ |
| **៨១- ចក្រភពរ៉ូមពិសិដ្ឋ**<br>អ. Holy Roman Empire<br>បារ. Saint-Empire romain (m.) | ចក្រភពរ៉ូមពិសិដ្ឋ គឺជាបណ្តុំនយោបាយមួយនៃទឹកដីអឺរ៉ុបខាងលិចនិងអឺរ៉ុបកណ្តាលនៅមជ្ឈិមសម័យដែលដឹកនាំដោយបណ្តាអធិរាជរ៉ូម។ ចាប់ពីសតវត្សរ៍ទី១០រហូតដល់សម័យណាប៉ូលេអុង(Napoléon) ចក្រភពរ៉ូមពិសិដ្ឋបានចាត់ទុកខ្លួនឯងថាជាអ្នកបន្តវេនពេញច្បាប់ពីចក្រភពរ៉ូមខាងលិច។ គុណនាម«ពិសិដ្ឋ» បានលេចឡើងនៅក្នុងរជ្ជកាលរបស់ហ្វ្រេដេរិក បាបឺរូស (Frédéric Barberousse) នៅគ.ស.១១៥៧ ដើម្បីធ្វើឱ្យអំណាចស្តេចមានលក្ខណៈជាទេវៈ។<br><br>ចក្រភពរ៉ូមពិសិដ្ឋក្នុងអំឡុងឆ្នាំ១៦០០នៃគ.ស. |
| **៨២- ចក្រភពប៊ីហ្សង់**<br>អ. Byzantine Empire<br>បារ. Empire byzantin | ចក្រភពរ៉ូមខាងកើតដែលយកឈ្មោះតាមរាជធានីប៊ីហ្សង់ (Byzance រាជធានីប៊ីហ្សង់ក្រោយមកត្រូវប្តូរឈ្មោះទៅជាកុងស្តង់ទីណូប)ជារដ្ឋដែលមានអត្ថិភាពពីឆ្នាំ៤៧៦ ដល់ឆ្នាំ១៤៥៣ នៃគ.ស.។ ចក្រភពនេះត្រូវបានគេស្គាល់ថាជា |

| | |
|---|---|
| | ចក្រភពរ៉ូមខាងកើតនាចុងបុរាណសម័យ ហើយ មានការរីកចម្រើនដល់កំពូលនាឆ្នាំ៥៥៥ នៃគ.ស. ក្នុងរាជ្យស្តេចហ៊្សូស្ទីនីញ៉ាងទី១ (Justinien I, 527-565) ដោយការពង្រីកទឹកដីទៅកាន់អាហ្វ្រិកខាងជើង អ៊ីតាលី និង រ៉ូម ដែលមានផ្ទៃដីទំហំ ២ ៤០០ ០០០ គ.ម២។ រាជធានីនៃចក្រភពនេះគឺ កុងស្តង់-ទីណូប។ ពួកគេគោរពសាសនាគ្រិស្តនិងប្រើភាសាឡាតាំង រួមទាំងភាសាក្រិកបុរាណផង។ ចក្រភពនេះបានដួលរលំនៅឆ្នាំ១៤៥៣នៃគ.ស. បន្ទាប់ពីពួកតួកគី(អូតូម៉ង់) វាយដណ្តើមបានទីក្រុងកុងស្តង់ទីណូប។<br>**L'Empire byzantin au temps de Justinien (527 - 565)**<br><br><br>វិសាលភាពទឹកដីប៊ីហ្សង់តាំងនាឆ្នាំ៥៥៥ នៃគ.ស. |
| **៨៣- ចក្រភពអូតូម៉ង់**<br>អ. Ottoman Empire<br>បារ. Empire ottoman (m.) | រដ្ឋអ៊ិស្លាមដែលមានប្រទេសតួកគីជាមជ្ឈមណ្ឌល មានអត្ថិភាពពីឆ្នាំ១២៩៩-១៩២២ ដែលបង្កើតនៅភាគពាយព្យអាណាតូលី (Anatolie)ដោយអូស្មាន់បេ (Osman Bey)។ ចក្រភពនេះបានរីកចម្រើនដល់កម្រិតកំពូលរបស់ខ្លួននៅក្នុងរាជ្យស៊ូឡេម៉ាន់ទី១(Suleiman I) ដែលគ្របដណ្តប់ទៅលើភាគខាងកើតសមុទ្រមេឌីទែរ៉ាណេ (ភាគអាគ្នេយ៍ទ្វីបអឺរ៉ុប) ដោយរាប់បញ្ចូលទាំងអាហ្វ្រិកខាងជើង និងអឺរ៉ុបកណ្តាល។ ចក្រភពនេះមានរាជធានីដំបូង គឺសូអ៊ុត (Söğüt) បន្ទាប់មកនៅប៊ួសា(Bursa) នៅអេឌៀន(Edirne) និង ចុងក្រោយនៅកុងស្តង់ទីណូប(Constantinople)។<br>ភាសាដែលគេប្រើផ្លូវការគឺ អូតូម៉ង់ និង តួកគី។ ក្រោយមកចក្រភពនេះបានដួលរលំនៅដើមសតវត្សទី២០។ |

| | |
|---|---|
| | <br>The Ottoman provinces and vassal states, 1609 |
| **៨៤- ចក្រភពម៉ុងហ្គោលី**<br>អ. Mongol Empire<br>បារ. Empire mongol<br>(m.) | រដ្ឋដែលបង្កើតឡើងដោយហ្សង់ហ្ស៊ីខាន់(Genghis Khan) មានអត្ថិភាពពីឆ្នាំ១២០៦ ដល់ឆ្នាំ១៣៦៨នៃគ.ស.។ ចក្រភពនេះបានរីកចម្រើនដល់កំពូលនាឆ្នាំ១២៧៩(ក្នុងរាជ្យគូប្លៃខាន់ Kublai Khan) ដោយមានផ្ទៃដីសរុប ៣៣លានគ.ម.$^{២}$ ដែលលាតសន្ធឹងពីសមុទ្រជប៉ុនទៅអឺរ៉ុបខាងកើត និង ភាគខាងជើងគ្របដណ្ដប់មួយផ្នែកធំនៃស៊ីបេរី ឯភាគខាងត្បូងគ្របដណ្ដប់អាស៊ីអាគ្នេយ៍ ឧបទ្វីបឥណ្ឌា ខ្ពង់រាបអ៊ីរ៉ង់ និងមជ្ឈិមបូព៌ា។ ភាពខ្លាំងរបស់កងទ័ពម៉ុងហ្គោលីគឺជំនាញខាងទ័ពសេះនិងបាញ់ព្រួញ។ ជនម៉ុងហ្គោលីគោរពសាសនាសាម៉ាន់(Shamanisme)និងសាសនាព្រះពុទ្ធ។ រាជធានីសំខាន់ៗនៃចក្រភពនេះគឺអាវ៉ាហ្គា ( Avarga) ការ៉ាក្ករូម (Karakoroum) និងខាន់បាលីក ( Khanbaliq)។ ពួកគេប្រើភាសាម៉ុងហ្គោលី ភាសាចិន និង ភាសាដទៃទៀត។<br><br>The relict states of the Mongol Empire |
| **៨៥- ចក្រភពជិន (ចិន)**<br>អ. Qin (Tchin) Empire<br>បារ. Empire Qin (m.) | រដ្ឋដែលមានអត្ថិភាពពីឆ្នាំ២២១ ដល់ ឆ្នាំ២០៦មុនគ.ស. បង្កើតឡើងដោយព្រះអង្គម្ចាស់ចេង(Zheng)និងមានទីតាំងនៅសានស៊ី(Shaanxi)។ ចក្រភពនេះចាប់ផ្ដើមពង្រីកទឹកដីដោយផ្ដួលរំលំរាជវង្សជូ(Zhou) នៅឆ្នាំ២២១មុនគ.ស. និង មានការរីកចម្រើនដល់កំពូលនាឆ្នាំ២១០ មុនគ.ស.។ ព្រះអង្គម្ចាស់ចេងដែលមានគោរមងារជា ហួងទី(Huangdi) ឬ ជិនស៊ីហួងទី (Qin Shi Huangdi) ជាអធិរាជចិនទី១និងជាអ្នកបានចាប់ផ្ដើមកសាងមហាកំពែងចិនដើម្បីការពារព្រំដែនភាគខាងជើងប្រទេស។ មហាកំពែងចិនត្រូវបានបញ្ចូល |

<table>
<tr>
<td></td>
<td>ក្នុងបញ្ជីបេតិកភណ្ឌពិភពលោក ដោយអង្គការយូណេស្កូក្នុងឆ្នាំ១៩៨៧។ រាជធានីនៃចក្រភពនេះ គឺស៊ានយ៉ាង (Xianyang)។ ពួកគេប្រើភាសាចិនបុរាណ។




ចក្រភពជិនអំឡុងឆ្នាំ២១០ មុនគ.ស.</td>
</tr>
<tr>
<td>៨៦- ចក្រភពជិង<br>អ. Qing Empire<br>បារ. Empire Qing<br>(Ch'ing) (m.)</td>
<td>រដ្ឋដែលមានអត្ថិភាពពីឆ្នាំ១៦៤៤ ដល់ ឆ្នាំ១៩១២នៃគ.ស. បង្កើតឡើង ដោយអធិរាជជីងនាម ស៊ុនជិ (Shunzhi, 1644-1661)។ នៅឆ្នាំ១៧៩០ ចក្រភពនេះមានផ្ទៃដីទំហំ ១៤ ៧០០ ០០០ គ.ម.$^{2}$ និង ប្រជាជនប្រមាណ៣០១លាននាក់។ រាជធានីនៃចក្រភពនេះ គឺប៉េកាំង។ ពួកគេគោរពសាសនាព្រះពុទ្ធ ខុងជឺ តាវ... និង ប្រើភាសាម៉ង់ដារ៉ាំង ម៉ាន់ជូ ព្រមទាំងភាសាផ្សេងៗទៀត។ ចក្រភពនេះដួលរលំដោយសារចលនាបះបោរ វូឆាង(Wuchang) ដែលបានទម្លាក់អធិរាជិនី ដូវ៉ាហ្គ័រ ឡុងយូ (Dowager Longyu) ចេញពីអំណាចនៅថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ១៩១២។ អតីតចក្រភពជីងនេះ សព្វថ្ងៃគឺជាផ្នែកខ្លះនៃប្រទេស អាហ្វហ្គានីស្ថាន ប៊ូតង់ ចិន ឥណ្ឌា កាហ្សាក់ស្ថាន កៀហ្ស៊ីស៊ីស្ថាន ម៉ុងហ្គោលី មីយ៉ាន់ម៉ា ប៉ាគីស្ថាន រុស្ស៊ី តាហ្ស៊ីគីស្ថាន និង តៃវ៉ាន់។




ចក្រភពជិងនៅចុងស.វ.ទី១៨</td>
</tr>
</table>

| | |
|---|---|
| **៨៧- ចក្រភពម៉ៅរ្យៈ**<br>អ. Maurya Empire<br>បារ. Empire de Maurya | រដ្ឋដែលមានអត្ថិភាពពីឆ្នាំ៣២២ ដល់ ឆ្នាំ១៨៥ មុនគ.ស. បង្កើតឡើងដោយសន្តតិវង្សម៉ៅរ្យៈ (dynastie Maurya) ក្នុងប្រទេសឥណ្ឌាសម័យបុរាណ។ ចក្រភពនេះមានផ្ទៃដីទំហំ ៥លានគ.ម$^{២}$។ អតីតចក្រភពម៉ៅរ្យៈនេះ សព្វថ្ងៃគឺជាផ្នែកខ្លះនៃប្រទេសឥណ្ឌា អាហ្វហ្កានីស្ថាន បង់ក្លាដែស ប៉ាគីស្ថាន ប៊ូតង់ អ៊ីរ៉ង់ ម៉ាល់ឌីវ មីយ៉ាន់ម៉ា ចិន នេប៉ាល់ និង ស្រីលង្កា។ រាជធានីនៃចក្រភពនេះ គឺបាដលិបុត្រ (Pataliputra សព្វថ្ងៃ គឺក្រុងប៉ាតណា Patna)។ ពួកគេគោរពសាសនាហិណ្ឌូ សាសនាព្រះពុទ្ធ និងសាសនាដទៃទៀត។ ពួកគេប្រើភាសាឥណ្ឌាបុរាណ ដូចជាភាសាមគធៈ–(Magadha) សំស្ក្រឹត(Sanskrit) ប្រាក្រឹត(Prakrit) ជាដើម។<br><br><br>វិសាលភាពនៃចក្រភពម៉ៅរ្យៈ |
| **៨៨- ចក្រភពគុប្តៈ**<br>អ. Gupta Empire<br>បារ. Empire de Gupta | រដ្ឋដែលមានអត្ថិភាពប្រមាណពីឆ្នាំ២៤០ រហូតដល់ឆ្នាំ៥៥០នៃគ.ស.បង្កើតឡើងដោយមហារាជស្រីគុប្តៈ (maharaja Sri Gupta)។ ចក្រភពនេះមានផ្ទៃដីទំហំ ៣ ៥០០ ០០០គ.ម.$^{២}$។ អតីតចក្រភពនេះ សព្វថ្ងៃគឺជាផ្នែកខ្លះនៃប្រទេសឥណ្ឌា ប៉ាគីស្ថាន បង់ក្លាដែស និងនេប៉ាល់។ ចក្រភពនេះបានរីកចម្រើនដល់កំពូល ដែលកត់សម្គាល់ដោយការបង្កើត និងរកឃើញផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម សិល្បៈ អក្សរសាស្ត្រ តក្កវិជ្ជា គណិតវិទ្យា តារាសាស្ត្រ សាសនា និងទស្សនវិជ្ជា។ រាជធានីនៃចក្រភពនេះគឺបាដលិបុត្រ (Pataliputra)។ ពួកគេគោរពសាសនាហិណ្ឌូ សាសនាព្រះពុទ្ធ និងប្រើភាសាសំស្ក្រឹត (Sanskrit)និងប្រាក្រឹត(Prakrit)។ |

| | |
|---|---|
| | <br><br>វិសាលភាពនៃចក្រភពគុប្តៈ |
| **៨៩- ចក្រភពម៉ូហ្គោល**<br>អ. Mughal (Moghul ) Empire<br>បារ. Empire moghol | រដ្ឋដែលមានអត្ថិភាពពីឆ្នាំ១៥៣០ដល់ឆ្នាំ១៧០៧នៃគ.ស. បង្កើតឡើងដោយអធិរាជម៉ូហ្គោល។ នៅឆ្នាំ១៧០៧ ចក្រភពនេះមានផ្ទៃដីទំហំ៤ ០០០ ០០០ គ.ម$^{២}$។ អតីតចក្រភពនេះសព្វថ្ងៃគឺជាផ្នែកខ្លះនៃប្រទេសអាហ្វហ្គានីស្ថាន បង់ក្លាដែស ឥណ្ឌា និង ប៉ាគីស្ថាន។ រាជធានីនៃចក្រភពនេះគឺអាហ្គ្រា(Agra) ហ្វាតេពួរ សិក្រី (Fatehpour Sikri) ឡាហ័រ (Lahore) ជាដើម។ ពួកគេគោរពសាសនាអ៊ិស្លាម និង ប្រើភាសាពែរ្សជាផ្លូវការ។ រាជ្យស្តេចសះហ្សាហាន់ (Shah Jahan, 1628-1658) ត្រូវបានគេចាត់ទុកថាជាយុគមាសនៃស្ថាបត្យកម្មម៉ូហ្គោល ដោយមានការកសាងនូវសំណង់ជាច្រើន ដូចជា ចេតិយធ្វើពីថ្មម៉ាបពណ៌ស តាច់ ម៉ាហាល់ (Taj Mahal,1632-1653) ដែលត្រូវបានបញ្ចូលក្នុងបញ្ជីបេតិកភណ្ឌពិភពលោកដោយអង្គការយូណេស្កូក្នុងឆ្នាំ១៩៨៣។<br><br><br>វិសាលភាពនៃចក្រភពម៉ូហ្គោល នាឆ្នាំ១៧០៧ |

| | |
|---|---|
| **៩០- ចក្រភពអាំងកា**<br>អ. Inca Empire<br>បារ. Empire inca (m.) | រដ្ឋដែលមានអត្ថិភាពពីឆ្នាំ១៤៣៨ដល់ឆ្នាំ១៥៣៣។ ចក្រភពនេះបង្កើតឡើងដោយស្តេចប៉ាចាគូតិច(Pachacutec, 1438-1471) ដែលមានផ្ទៃដីធំបំផុតមួយនៅទ្វីបអាម៉េរិក មុនការមកដល់របស់លោក គ្រីស្តូហ្វ កូឡុំ ឆ្នាំ១៤៩២ ដោយមានផ្ទៃដីទំហំ ២ ០០០ ០០០ គ.ម$^{២}$ (ឆ្នាំ១៥២៧)។ អតីតចក្រភពនេះសព្វថ្ងៃគឺជាផ្នែកខ្លះនៃប្រទេសប៉េរូ អេក្វាទ័រ និង មួយភាគនៃប្រទេសបូលីវី អាហ្សង់ទីន ស៊ីលី កូឡុំប៊ី។ រាជធានីនៃចក្រភពនេះគឺ គូស្កូ (Cuzco)។ ពួកគេគោរពសាសនាអាំងកា និង ប្រើភាសាកេឈ្វា (Quechua)។<br><br><br>វិសាលភាពនៃចក្រភពអាំងកា |
| **៩១- ចក្រភពស្រីវិជ័យ**<br>អ. Srivijaya Empire<br>បារ. Empire de Srivijaya (m.) | រដ្ឋដែលមានអត្ថិភាពពីឆ្នាំ៦៥០ដល់ឆ្នាំ១៣៧៧នៃគ.ស. មានទីតាំងស្ថិតនៅលើកោះស៊ូម៉ាត្រានៃប្រទេសឥណ្ឌូណេស៊ីសព្វថ្ងៃ។ មហារាជទី១នៃចក្រភពនេះគឺជាពុនតា ហ៉ង់ស្រី ជ័យណាសា (Dapunta Hyang Sri Jayanasa)។ អតីតចក្រភពនេះ សព្វថ្ងៃគឺជាផ្នែកខ្លះនៃប្រទេសព្រុយណេ ឥណ្ឌូណេស៊ី ម៉ាឡេស៊ី សិង្ហបុរី និង ថៃ។ ចក្រភពនេះបានរីកចម្រើនដល់កំពូលក្នុងសតវត្សរ៍ទី៨ ដែលមានទឹកដីគ្របដណ្តប់មួយផ្នែកធំនៃកោះជ្វា ជ្រោយម៉ាឡាយូ កោះស៊ូម៉ាត្រាទាំងមូល។ ចក្រភពស្រីវិជ័យបានជះឥទ្ធិពលទៅលើភូមិភាគអាស៊ីអាគ្នេយ៍មួយភាគធំ និងជាមជ្ឈមណ្ឌលសាសនាព្រះពុទ្ធដ៏សំខាន់មួយពីស.វ.ទី៨ដល់ស.វ.ទី១២។ រាជធានីសំខាន់ៗនៃចក្រភពនេះគឺ សៃលេន្ទ្រ(Sailendra) និង ប៉ាលេមបាង (Palembang) ជាដើម។ ពួកគេគោរពពុទ្ធសាសនាមហាយាន សាសនាហិណ្ឌូ និងសាសនាម៉ាឡេបុរាណ ហើយ ប្រើភាសាម៉ាឡេបុរាណនិងភាសាសំស្ក្រឹត។ |

| | |
|---|---|
| | <br><br>ការពង្រីកវិសាលភាពនៃចក្រភពស្រីវិជ័យនាស.វ.ទី៨នៃគ.ស. |
| **៩២- ចក្រភពខ្មែរ (សម័យអង្គរ)**<br>អ. Khmer Empire<br>បារ. Empire Khmer ( m. ) | រដ្ឋដែលមានអត្ថិភាពចាប់ពីស.វ.ទី៩ដល់ស.វ.ទី១៥នៃគ.ស.។ ចក្រភពនេះមានផ្ទៃដីទំហំ ១ ២០០ ០០០ គ.ម²។ អតីតចក្រភពនេះ សព្វថ្ងៃគឺប្រទេសកម្ពុជាទាំងមូល និង ផ្នែកខ្លះនៃប្រទេសឡាវ ថៃ ម៉ាឡេស៊ី និងវៀតណាម។ រាជធានីនៃចក្រភពនេះគឺ ភ្នំគូលែន ហរិហរាល័យ យសោធរបុរៈ កោះកេរ និងអង្គរ។ ពួកគេគោរពសាសនាហិណ្ឌូ សាសនាព្រះពុទ្ធ និងប្រើភាសាខ្មែរបុរាណ សំស្ក្រឹត និងបាលី។<br><br> |

| | |
|---|---|
| **៩៣- ចក្រភពប្រេស៊ីល**<br>អ. Empire of Brazil<br>បារ.Empire du Brésil | រដ្ឋដែលមានអត្ថិភាពពីឆ្នាំ១៨២២ដល់ឆ្នាំ១៨៨៩ ដែលបង្កើតឡើងដោយអធិរាជប៉េត្រូទី១ Pedro I និង ប៉េត្រូទី២ Pedro II និងមានផ្ទៃដីទំហំ ៨ ៣៦៣ ១៨៦ គ.ម.$^{២}$ (១៨៨៩)។ អតីតចក្រភពនេះ សព្វថ្ងៃក្លាយទៅជាប្រទេសប្រេស៊ីលនិងផ្នែកខ្លះនៃប្រទេសអ៊ុយរូហ្គាយ (Uruguay)។ រាជធានីនៃចក្រភពនេះគឺ រីយ៉ូ ដឺ ហ្សាណេរ៉ូ (Rio de Janeiro)។ ពួកគេគោរពសាសនារ៉ូម៉ាំងកាតូលិកនិងប្រើភាសាព័រទុយហ្គាល់។ ប្រទេសប្រេស៊ីលបានក្លាយជាដែនដីអាណានិគមរបស់ព័រទុយហ្គាល់ និង ជាមជ្ឈមណ្ឌលនៃចក្រភពអាណានិគមព័រទុយហ្គាល់ នៅឆ្នាំ១៨០៨។ ចក្រភពប្រេស៊ីលបានដួលរលំដោយសាររដ្ឋប្រហារយោធានៅថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ១៨៨៩ដែលបានបង្កើតឡើងនូវរបបសាធារណរដ្ឋផ្តាច់ការមួយ។<br><br>ការពង្រីកចក្រភពប្រេស៊ីលក្នុងអំឡុងឆ្នាំ១៨២២-១៨២៨ |
| **៩៤- ចក្រភពអាណានិគម**<br>អ. Colonial Empire<br>បារ. Empire colonial | ចក្រភពអាណានិគមគឺជាទឹកដីដែលរដ្ឋមានកម្លាំងយោធានិងកម្លាំងនាវាយ៉ាងធំនោះ បានចាប់យកមកធ្វើជាកម្មសិទ្ធិ។ សម្រាប់បណ្តាប្រទេសអឺរ៉ុបខាងលិចចក្រភពអាណានិគមត្រូវបានបង្កើតឡើងនៅសម័យមហាដំណើររុករក (Période d'exploration) របស់ពួកអឺរ៉ុប ដោយសារវឌ្ឍនភាពនៃនាវាចរណ៍ (Progrès dela navigation) និងការប្រើប្រាស់កាំភ្លើងជាទូទៅ (Généralisation des armes à feu)។<br><br><br>ចក្រភពអាណានិគម |

| | |
|---|---|
| **៩៥- ចក្រភពអាណានិគមអេស្ប៉ាញ**<br>អ. Spanish colonial Empire<br>បារ. Empire colonial espagnol (m.) | រដ្ឋដែលមានអត្ថិភាពចាប់ពីឆ្នាំ១៤៩២ដល់ឆ្នាំ១៩៧៥ គឺចាប់ពីការធ្វើដំណើរទៅដល់ទ្វីបអាម៉េរិករបស់គ្រីស្តូហ្វ កូឡុំ រហូតដល់ការបាត់បង់ដែនដីអាណានិគមចុងក្រោយនៅទ្វីបអាហ្វ្រិក។ ចក្រភពនេះមានអំណាចខ្លាំងចាប់ពីស.វ. ទី១៦ដល់ទី១៨ ដោយបានគ្រប់គ្រងទឹកដីទ្វីបអាម៉េរិក អាហ្វ្រិក និងអូសេអានី ដែលមានផ្ទៃដី ទំហំ ២៧ ០០០ ០០០ គ.ម²។ រាជធានីនៃចក្រភពនេះគឺម៉ាឌ្រីដ (Madrid)។ ពួកគេប្រើភាសាអេស្ប៉ាញ។<br><br>ដែនដីចក្រភពអាណានិគមអេស្ប៉ាញ |
| **៩៦- ចក្រភពអាណានិគមព័រទុយហ្គាល់**<br>អ. Portuguese colonial Empire<br>បារ. Empire colonial portugais(m.) | រដ្ឋដែលមានអត្ថិភាពពីឆ្នាំ១៤១៥ដល់ឆ្នាំ១៩៩៩ (ដែនដីម៉ាកាវទទួលបានឯករាជ្យ)។ ចក្រភពនេះបានបង្កើតឡើងនូវអាណានិគមដំបូងគេបង្អស់ក្នុងប្រវត្តិសាស្ត្រ និង ជាចក្រភពអាណានិគមដែលមានអាយុវែងជាងគេ ព្រមទាំងបានគ្រប់គ្រងផ្លូវសមុទ្រច្រើនជាងគេផងដែរ។ ចក្រភពនេះបានគ្រប់គ្រងទឹកដីអាម៉េរិកខាងត្បូង (មួយភាគធំនៃទឹកដីប្រេស៊ីល) ផ្នែកខ្លះនៃទ្វីបអាហ្វ្រិកនិងអាស៊ី។ ប្រទេសប្រេស៊ីលបានក្លាយជាដែនដីអាណានិគមរបស់ព័រទុយហ្គាល់ និង ជាមជ្ឈមណ្ឌលនៃចក្រភពអាណានិគមព័រទុយហ្គាល់ នៅឆ្នាំ១៨០៨។ រាជធានីនៃចក្រភពនេះគឺ លីសបោន(Lisbonne)។ ពួកគេប្រើភាសាព័រទុយ-ហ្គាល់។<br><br>ដែនដីចក្រភពអាណានិគមព័រទុយហ្គាល់ |

| | |
|---|---|
| **៩៧- ចក្រភពបារាំងទី១**<br>អ. First French Empire<br>បារ. Premier Empire français (m.) | រដ្ឋដែលមានអត្ថិភាពពីឆ្នាំ១៨០៤ដល់ឆ្នាំ១៨១៤ ក្រោមរាជកិច្ចដឹកនាំរបស់ព្រះចៅអធិរាជ ណាប៉ូឡេអុង បូណាប៉ាត (Napoléon Bonaparte)។ នៅឆ្នាំ១៨១២ ចក្រភពនេះគ្របដណ្តប់លើទឹកដីបច្ចុប្បន្ននៃប្រទេសអាល្លឺម៉ង់ អ៊ីតាលី អេស្ប៉ាញ ប៉ូឡូញ និងអូទ្រីស។ រាជធានីនៃចក្រភពនេះគឺ ប៉ារីស។ ប្រជាជននៃចក្រភពនេះត្រូវបានតម្រូវឱ្យគោរពសាសនាគ្រិស្តនិកាយរ៉ូម៉ាំងកាតូលិកនិងប្រើភាសាបារាំង។<br><br>ចក្រភពបារាំងទី១ នាឆ្នាំ១៨១២ |
| **៩៨- ចក្រភពបារាំងទី២**<br>អ. Second French Empire<br>បារ. Second Empire français (m.) | រដ្ឋដែលមានអត្ថិភាពពីឆ្នាំ១៨៥២ដល់ឆ្នាំ១៨៧០។ ចក្រភពនេះស្ថិតក្រោមរាជកិច្ចដឹកនាំរបស់ព្រះចៅអធិរាជ ណាប៉ូឡេអុងទី៣ និងមានទឹកដីធំទូលាយនាឆ្នាំ១៨៦៧។ ចក្រភពនេះគ្របដណ្តប់លើទឹកដីអតីតដែនដីអាណានិគមរួមមាន តុងកឹង អាណ្ណាម កូសាំងស៊ីន(បច្ចុប្បន្ន វៀតណាម) ប្រទេសអាល់ហ្សេរី កម្ពុជា សេណេហ្គាល់ ហ្គាបុង និងផ្នែកខ្លះនៃប្រទេសឥណ្ឌា។ រាជធានីនៃចក្រភពនេះគឺ ប៉ារីស។ ប្រជាជននៃអតីតដែនដីចក្រភពនេះ ត្រូវបានតម្រូវឱ្យប្រើភាសាបារាំង។<br><br><br>ចក្រភពបារាំងទី២ |

| | |
|---|---|
| **៩៩- ចក្រភពជប៉ុន**<br>អ. Empire of Japan<br>បារ. Empire du Japon<br>(m.) | រដ្ឋដែលមានអត្ថិភាពចាប់ពីឆ្នាំ១៨៦៨ដល់ឆ្នាំ១៩៤៧ (ចាប់ពីសម័យម៉ីជិដល់ក្រោយសង្គ្រាមលោកលើកទី២)។ ចក្រភពនេះរីកចម្រើនដល់កំពូលនាឆ្នាំ១៩៤២ ដោយមានផ្ទៃដីទំហំ៧ ៤០០ ០០០ គ.ម² និងជាមហាអំណាចដែនសមុទ្រដ៏ធំមួយក្នុងប្រវត្តិសាស្ត្រ។ ចក្រភពនេះគ្របដណ្តប់លើប្រទេសកូរ៉េ បណ្តាប្រទេសអាស៊ីអាគ្នេយ៍ទាំងមូល ផ្នែកខ្លះលើទឹកដីបច្ចុប្បន្ននៃប្រទេសចិន រុស្ស៊ី និងកោះមួយចំនួនក្នុងមហាសមុទ្រប៉ាស៊ីហ្វិក។ រាជធានីសំខាន់នៃចក្រភពនេះគឺ តូក្យូ។<br><br>ចក្រភពជប៉ុនក្នុងឆ្នាំ១៩៤២ |
| **១០០- ចក្រភពអាល្លឺម៉ង់**<br>អ. German Empire<br>បារ. Empire d'Allemagne | រដ្ឋមួយមានអត្ថិភាពពីឆ្នាំ១៨៧១ដល់ឆ្នាំ១៩១៨ ដែលគ្រប់គ្រងជាបន្តបន្ទាប់ដោយព្រះចៅអធិរាជហ្គីយ៉ូម១(Guillaume I ១៨៧១-១៨៨៨) អធិរាជហ្វ្រេដេរិក(Frederick ១៨៨៨-១៨៨៨) អធិរាជហ្គីយ៉ូម២(Guillaume II) នៃប្រទេសព្រូស។ ចក្រភពនេះមានទឹកដីធំទូលាយនាឆ្នាំ១៩១៨ ដែលមានទំហំប្រមាណ៥៤០ ៨៥៧ គ.ម² និងបានគ្របដណ្តប់លើទឹកដីបច្ចុប្បន្ននៃប្រទេសជាច្រើននៅទ្វីបអឺរ៉ុប និងដែនដីឯនាយសមុទ្រ។ រាជធានីនៃចក្រភពនេះគឺ បែរឡាំង។ ភាគច្រើននៃប្រជាជនរបស់អតីតដែនដីចក្រភពនេះគោរពសាសនាគ្រិស្តនិកាយប្រូតេស្តង់ និងប្រើភាសាអាល្លឺម៉ង់ (Deuch)។<br><br><br>ចក្រភពអាល្លឺម៉ង់ក្នុងឆ្នាំ១៨៧១ |

| | |
|---|---|
| **១០១- ចក្រភពអាណានិគមហូឡង់**<br>អ. Dutch colonial Empire<br>បារ. Empire colonial néerlandais(m.) | ទឹកដីដែលប្រទេសហូឡង់បានចាប់យកមកធ្វើជាកម្មសិទ្ធិដោយប្រើកម្លាំងយោធា កងកម្លាំងនាវា និងដោយសារការរុករក ការធ្វើពាណិជ្ជកម្ម ចាប់ពីស.វ.ទី១៧ ដល់ពាក់កណ្ដាលទសវត្សរ៍ទី៦នៃស.វ.ទី២០។ ទឹកដីអាណានិគមនេះមាននៅអាស៊ីអាគ្នេយ៍ ដូចជា ហ្វីលីពីន ឥណ្ឌូណេស៊ី ជាដើម នៅអាហ្វ្រិកខាងត្បូង ដូចជា សេណេហ្កាល់ សៀរ៉ាឡេអូន លីប៊ី ជាដើម និងផ្នែក ខ្លះនៃទ្វីបអាម៉េរិកខាងត្បូង ដូចជា ស៊ីលី ផ្នែកខ្លះនៃប្រទេសប្រេស៊ីល និងផ្នែកខ្លះនៃឥណ្ឌា។ រាជធានីនៃចក្រភពនេះ គឺអាំស្ទែដាំ (Amsterdam)។ ប្រជាជន នៃចក្រភពនេះប្រើភាសាហូឡង់។<br><br>ដែនដីចក្រភពអាណានិគមហូឡង់ |
| **១០២- ចក្រភពអាណានិគមអង់គ្លេស**<br>អ. British colonial Empire<br>បារ. Empire colonial britannique (m.) | ទឹកដីដែលប្រទេសអង់គ្លេសបានចាប់យកមកធ្វើជាកម្មសិទ្ធិ ចាប់ពីចុងស.វ.ទី១៦ដល់ដើមស.វ.ទី២០ តាមរយៈការប្រើកម្លាំងយោធា កងកម្លាំងនាវា និងការធ្វើពាណិជ្ជកម្ម(ប៉ុស្តិ៍ពាណិជ្ជកម្ម)។ ចក្រភពនេះគ្រប់គ្រងដោយព្រះមហាក្សត្រនៃចក្រភពអង់គ្លេស (Royaume-Uni) រួមមានដែនដីអាណានិគម និងដែនដីអាណាព្យាបាល ដែលមានផ្ទៃដីទំហំ៣៣ ៦៧០ ០០០ គ.ម.$^២$ ដោយរួមមានផ្នែកខ្លះនៃទ្វីបអាម៉េរិក អាហ្វ្រិក អាស៊ី និងទ្វីបអូសេអានី។ រាជធានីនៃចក្រភពនេះគឺឡុងដ៍។ ប្រជាជននៃចក្រភពនេះគោរពសាសនាគ្រិស្តនិកាយផ្សេងៗគ្នា និងប្រើភាសាអង់គ្លេស។<br><br>ដែនដីចក្រភពអាណានិគមអង់គ្លេស |

| | |
|---|---|
| **១០៣- ចក្រភពអាណានិគមបារាំង**<br>អ. French colonial Empire<br>បារ. Empire colonial français (m.) | ទឹកដីដែលប្រទេសបារាំងបានចាប់យកមកធ្វើជាកម្មសិទ្ធិ ចាប់ពីឆ្នាំ១៥៣៤ ដល់ឆ្នាំ១៩៨០ តាមរយៈការប្រើកម្លាំងយោធា និងកងកម្លាំងនាវា។ ក្នុងអំឡុង ស.វ.ទី១៩និងទី២០ ចក្រភពអាណានិគមបារាំង ជាចក្រភពធំទី២បន្ទាប់ពីចក្រភពអង់គ្លេស ដែលមានផ្ទៃដីទំហំ១២ ៣៤៧ ០០០គ.ម$^{២}$ ដោយរួមមានផ្នែកខ្លះនៃទ្វីបអាមេរិក ទ្វីបអាហ្វ្រិក ទ្វីបអឺរ៉ុប និងទ្វីបអាស៊ី។ រាជធានីនៃចក្រភពនេះគឺ ប៉ារីស។ ប្រជាជននៃចក្រភពនេះគោរពសាសនាគ្រិស្តនិកាយរ៉ូម៉ាំងកាតូលិក និងប្រើភាសាបារាំង។<br><br> |
| **១០៤- រាជាណាចក្រព្រូស**<br>អ. Kingdom of Prussia<br>បារ. Royaume de Prusse (m.) | រដ្ឋដែលមានអត្ថិភាពពីឆ្នាំ១៧០១ដល់ឆ្នាំ១៩១៨ គ្រប់គ្រងដោយព្រះចៅហ្វ្រេដេរិកទី១ (Frédéric I) ដែលសោយរាជ្យដំបូងពីឆ្នាំ១៧០១-១៧១៣) និងស្តេចចុងក្រោយគឺព្រះចៅហ្គីយ៉ូមទី២ (Guillaume II) ដែលសោយរាជ្យពីឆ្នាំ១៨៨៨-១៩១៨)។ រាជាណាចក្រនេះមានផ្ទៃដីទំហំ ៣៤៨ ៧៧៩ គ.ម$^{២}$ (ឆ្នាំ១៩១០)។ អតីតរាជាណាចក្រនេះ សព្វថ្ងៃគឺជាផ្នែកខ្លះនៃប្រទេសបែលហ្ស៊ិក សាធារណរដ្ឋឆែក ដាណឺម៉ាក អាល្លឺម៉ង់ លីទុយអានី ប៉ូឡូញ និងរុស្ស៊ី។ រាជធានីនៃរាជាណាចក្រនេះគឺ បែរឡាំង។ ប្រជាជននៃរាជាណាចក្រនេះភាគច្រើនគោរពសាសនាគ្រិស្តនិកាយប្រូតេស្តង់ និងប្រើភាសាអាល្លឺម៉ង់។<br><br>រាជាណាចក្រព្រូស ស្ថិតក្នុងចក្រភពអាល្លឺម៉ង់នាឆ្នាំ១៨៧១ |

| | |
|---|---|
| **១០៥- ចក្រភពរុស្ស៊ី**<br>អ. Russian Empire<br>បារ. Empire de Russie<br>(m.) | រដ្ឋដែលមានអត្ថិភាពពីឆ្នាំ១៧២១ដល់បដិវត្តន៍រុស្ស៊ីឆ្នាំ១៩១៧ ចាប់ពីការឡើងសោយរាជ្យនៃព្រះចៅអធិរាជព្យែរទី១(Pierre I,1721-1725) និងស្ដេចចុងក្រោយគឺព្រះចៅនីកូឡាទី២ (Nicolas II, ១៨៩៤-១៩១៧)។ ចក្រភពនេះរីកចម្រើនដល់កំពូលនាឆ្នាំ១៨៦៦ ដោយមានផ្ទៃដីទំហំ២២ ៨០០ ០០០ គ.ម$^{២}$ និងបានលាតសន្ធឹងពីអឺរ៉ុបខាងកើតឆ្លងកាត់ទ្វីបអាស៊ីរហូតដល់អាម៉េរិកខាងជើង។ អតីតចក្រភពនេះ សព្វថ្ងៃគឺជាផ្នែកខ្លះនៃប្រទេសរុស្ស៊ី អ៊ុយក្រែន បេឡារុស ម៉ុលដាវី រូម៉ានី ហ្វាំងឡង់ អេស្តូនី ឡេតូនី លីទុយអានី ប៉ូឡូញ អាមេនី ហ្ស៊កហ្ស៊ី អាស៊ែបៃហ្សង់ អ៊ីរ៉ង់ កាហ្សាក់ស្ថាន កៀហ្ស៊ីស៊ីស្ថាន តាហ្ស៊ីគីស្ថាន អ៊ូសបេគីស្ថាន តួកម៉េនីស្ថាន តួកគី ម៉ុងហ្គោលី ចិន សហរដ្ឋអាម៉េរិក (អាឡាស្កា) និងអាហ្វហ្គានីស្ថាន។ រាជធានីនៃចក្រភពនេះគឺ សាំងប៉េទែស្បួ (Saint-Pétersbourg) និងមូស្គូ (Moscou)។ ប្រជាជននៃចក្រភពនេះគោរពសាសនាគ្រិស្តនិកាយអ័រតូដុក រុស្ស៊ី និងប្រើភាសារុស្ស៊ី។<br><br><br>ចក្រភពរុស្ស៊ីនាស.វ.ទី១៨ |
| **១០៦- ចក្រភពអូទ្រីស-ហុងគ្រី**<br>អ. Austria-Hungarian Empire<br>បារ. Empire d'Autriche-Hongrie /Empire austro-hongrois<br>(m.) | រដ្ឋដែលមានអត្ថិភាពពីឆ្នាំ១៨៦៧ដល់ឆ្នាំ១៩១៨ដែលគ្រប់គ្រងដោយព្រះចៅអធិរាជអូទ្រីស ហ្វ្រង់ស្វ័រ ហ្សូសេហ្វទី១(François-Joseph I, ១៨៦៧-១៩១៦) និងស្ដេចចុងក្រោយគឺព្រះចៅសាលទី១(Charles I, ១៩១៦-១៩១៨)។ នៅឆ្នាំ១៩១៤ ចក្រភពនេះមានផ្ទៃដីទំហំ៦៧៦ ៦១៥ គ.ម$^{២}$។ អតីតចក្រភពនេះសព្វថ្ងៃជាផ្នែកខ្លះនៃប្រទេសអូទ្រីស ហុងគ្រី បូស្នី-ហ៊ែរសេហ្គោវីន ក្រូអាស៊ី សាធារណរដ្ឋឆែក អ៊ីតាលី ម៉ុងតេណេហ្គ្រោ ប៉ូឡូញ រូម៉ានី ស៊ែប៊ី ស្លូវ៉ាគី ស្លូវេនី និងអ៊ុយក្រែន។ រាជធានីនៃចក្រភពនេះគឺ វីយែន (Vienne)។ ប្រជាជននៃចក្រភពនេះគោរពសាសនាគ្រិស្តនិកាយរ៉ូម៉ាំងកាតូលិក(Catholique romaine) អ័រតូដុក(Église orthodoxe) និងសាសនាដទៃទៀត និងប្រើភាសាអាល្លឺម៉ង់ និងហុងគ្រី។ |



ចក្រភពអូទ្រីស-ហុងគ្រី

**១០៧- អាល្លឺម៉ង់ណាស៊ី**

អ. Nazi Germany

បារ. Allemagne nazie (f.)

រដ្ឋអាល្លឺម៉ង់ដែលមានអត្ថិភាពពីឆ្នាំ១៩៣៣ដល់ឆ្នាំ១៩៤៥ ដឹកនាំដោយអាដុល ហ៊ីត្លែ(Adolf Hitler) ដែលប្រកាន់យកណាស៊ីនិយម (Nazisme)។ ពាក្យ ណាស៊ីនិយមនេះ មកពីពាក្យ «ជាតិ-សង្គមនិយម» (National-Socialisme) ជាមនោគមវិជ្ជានយោបាយរបស់គណបក្សជាតិ-សង្គមនិយម ពលករអាល្លឺម៉ង់ (Parti national-socialiste des travailleurs allemands) ដែលជាគណបក្សនយោបាយស្តាំនិយមជ្រុល បង្កើតឡើងនៅប្រទេសអាល្លឺម៉ង់នៅឆ្នាំ១៩២០ និងដឹកនាំដោយអាដុល ហ៊ីត្លែ។ មនោគមវិជ្ជានេះចាត់ទុកពូជសាសន៍អារ្យ៉ែន (Race aryenne) ថាជាពូជសាសន៍ខ្ពស់ជាងគេ។ ណាស៊ីនិយមជាលទ្ធិប្រកាន់ពូជសាសន៍និងជាលទ្ធិប្រឆាំងជ្វីហ្វ(Racisme et antisémitisme)។

នៅឆ្នាំ១៩៣៩ រដ្ឋនេះមានផ្ទៃដីទំហំ៦៣៣ ៧៨៦ គ.ម$^{២}$ ដោយបានឈ្លានពានលើប្រទេសអូទ្រីស ឆេកូស្លូវ៉ាគី ប៉ូឡូញ ហូឡង់ បែលហ្ស៊ិក បារាំង (តំបន់អាល់សាសឡូរ៉ែន Alsance-Lorraine) សហភាពសូវៀត(ទីក្រុងកាលីនីនក្រាដ Kaliningrad) ន័រវែស ស៊ុយអែត លុចសំបួ និងអ៊ីស្លង់។ រដ្ឋធានីនៃរដ្ឋនេះគឺ បែរឡាំង។



| | |
|---|---|
| **១០៨- សម័យរុករក**<br>អ. Age of Exploration<br>បារ. Âge de l'exploration | សម័យពីស.វ.ទី១៥ដល់ទី១៧ ដែលការរុករកឯនាយសមុទ្រដ៏ធំ បានលេចឡើងជាកត្តាដ៏មានអានុភាពនៃវប្បធម៌អឺរ៉ុប។ ទឹកដីជាច្រើនដែលពួកអឺរ៉ុបមិនបានស្គាល់ពីមុនត្រូវបានរកឃើញនៅសម័យនោះ។ លក្ខណៈសម្គាល់នៃសម័យនេះ គឺការមកដល់នៃអ្នកតាំងទីលំនៅ និងអ្នកឈ្លានពានមកពីទ្វីបមួយដែលគេមិនធ្លាប់បានស្គាល់។ លើសពីនេះ អ្នករុករកខ្លះបានធ្វើនាវាចរណ៍ដើម្បីស្វែងយល់អំពីពិភពលោកឱ្យកាន់តែច្រើន។ ទោះក្នុងមូលហេតុណាក៏ដោយក៏សម័យរុករកបានជួយឱ្យមានការរីកចម្រើននូវចំណេះដឹងខាងភូមិសាស្ត្រ។<br>អ្នករុករកដែលមានឈ្មោះល្បីសម័យនោះមានដូចជា គ្រិស្តូហ្វ កូឡុំ (Christophe Colomb, 1451-1506) វ៉ាស្កូ ដឺហ្គាម៉ា(Vasco de Gama, 1460/1469-1524) និងហ្វែឌីណង់ ម៉ាហ្សេឡង់ (Ferdinand Magellan, 1480-1521) ជាដើម។<br><br><br>ផែនទីបង្ហាញពីដំណើររុករកដែនដីថ្មី |
| **១០៩-រាជាណាចក្រស៊ុលតង់**<br>អ. Sultanate<br>បារ. Sultanat (m.) | រដ្ឋឬប្រទេសដែលដឹកនាំដោយស៊ុលតង់(ស្តេច) ហើយកាន់សាសនាអ៊ិស្លាម។<br>ឧ. រាជាណាចក្រស៊ុលតង់ម៉ាឡាកា ជារដ្ឋសម័យបុរាណនៃប្រទេសម៉ាឡេស៊ី។ |
| **១១០- រាជាណាចក្រ ស៊ុលតង់ម៉ាឡាកា**<br>អ .Sultanate of Malacca<br>បារ. Sultanat de Malacca (m.) | រដ្ឋដែលមានអត្ថិភាពពីឆ្នាំ១៤០០ដល់ឆ្នាំ១៥១១ គ្រប់គ្រងដោយស៊ុលតង់អ៊ីសកាន់ដាសះ(Sultan Iskandar Shah)។ រាជធានីនៃរាជាណាចក្រនេះគឺម៉ាឡាកា។ ប្រជាជននៃរាជាណាចក្រនេះគោរពសាសនាហិណ្ឌូ និងអ៊ិស្លាម ហើយប្រើភាសាម៉ាឡេបុរាណ(ម៉ាឡាយូ)។ អតីតរាជាណាចក្រនេះ សព្វថ្ងៃជាផ្នែកខ្លះនៃប្រទេសម៉ាឡេស៊ី សិង្ហបុរី ថៃ និងឥណ្ឌូណេស៊ី។<br><br>រាជាណាចក្រស៊ុលតង់ម៉ាឡាកា នាចុងស.វ.ទី១៥ |

<table>
<tr>
<td>១១១- រាជាណាចក្រ<br>ស៊ុលតង់ដេលី<br>អ .Delhi sultanate<br>បារ. Sultanat de Delhi(m.)</td>
<td>រដ្ឋដែលមានអត្ថិភាពពីឆ្នាំ១២០៦ដល់ឆ្នាំ១៥២៦ គ្រប់គ្រងដោយសន្តតិវង្ស៥ បន្តបន្ទាប់គ្នាគឺ សន្តតិវង្សមូហ្ស៊ី (dynastie des Muizzî, 1206-1290) ខាល់ជី(dynastie des Khaldjî, 1290-1320) ទូគ្លុក (dynastie de Tughlûq, 1320-1414) សាយីត (dynastie des Sayyîd, 1414-1451) និង ឡូឌី(Lodî, 1451-1526)។ រាជធានីនៃរាជាណាចក្រនេះ គឺ ដេលី(Delhi)។ ប្រជាជននៃរាជាណាចក្រនេះគោរពសាសនាអ៊ិស្លាមនិកាយស៊ុននីត និងប្រើភាសាពែរ្ស។ អតីតរាជាណាចក្រនេះ សព្វថ្ងៃជាផ្នែកខ្លះនៃប្រទេសអាហ្វហ្កានីស្ថាន បង់ក្លាដែស ឥណ្ឌា និងប៉ាគីស្ថាន។<br><br><br><br>រាជាណាចក្រស៊ុលតង់ដេលី</td>
</tr>
<tr>
<td>១១២- រាជាណាចក្រ<br>ស៊ុលតង់បះម៉ានី<br>អ. Baḥmani Sultanate<br>បារ. Sultanat Baḥmanî (m.)</td>
<td>រដ្ឋដែលមានអត្ថិភាពពីឆ្នាំ១៣៤៧ដល់ឆ្នាំ១៥២៧ គ្រប់គ្រងដោយស៊ុលតង់ អាឡា អ៊ូឌីន បះម៉ាន់(Alāʾud-Dīn Baḥman) នៅឆ្នាំ១៣៤៧។ រាជធានីនៃរាជាណាចក្រនេះគឺ អះសាណាបាដ(Aḥsanābād)។ ប្រជាជននៃរាជាណាចក្រនេះគោរពសាសនាអ៊ិស្លាម។ នៅក្រោយឆ្នាំ១៥១៨ រាជាណាចក្រនេះត្រូវបានបែកខ្ញែកជា៥រដ្ឋផ្សេងៗគ្នា គឺអះម៉ាដណាហ្គា(Aḥmad-nâgar) ហ្គោលកុងដា(Golkonda) ប៊ីដា(Bîdâr) បេរ៉ា(Berâr) និងប៊ីហ្សាពួរ (Bîjâpur) ហើយរដ្ឋទាំង៥នេះត្រូវបានគេស្គាល់ថាជារាជាណាចក្រស៊ុលតង់ដេកង់(sultanats de Dekkan)។<br><br><br><br>រាជាណាចក្រស៊ុលតង់ បះម៉ានី នាឆ្នាំ១៤៧០</td>
</tr>
</table>

<table>
<tr>
<td>១១៣- រាជាណាចក្រ ស៊ុលតង់ម៉ាតារ៉ាំ<br>អ. Mataram Sultanate<br>បារ. Sultanat de Mataram (m.)</td>
<td>រដ្ឋដែលមានអត្ថិភាពពីឆ្នាំ១៥៨៧ដល់ឆ្នាំ១៧៥៥ គ្រប់គ្រងដោយស៊ុលតង់សេណូប៉ាទី(Senopati, ១៥៨៧-១៦០១) និងស៊ុលតង់ ប៉ាគូប៊ូវ៉ូណូទី១ (Pakubuwono I, ១៦៧៧-១៦៨១)។ រាជធានីនៃរាជាណាចក្រនេះ គឺកូតា ហ្គេដ(Kota Gede)។ ប្រជាជននៃរាជាណាចក្រនេះគោរពសាសនាអ៊ិស្លាម និងប្រើភាសាជ្វា។ រដ្ឋនេះបានរីកចម្រើនដល់កំពូលនៅក្នុងរាជ្យស៊ុលតង់ អាហ្គុង ហាន់យ៉ូក្រូគុស៊ូម៉ូ(Agung Hanyokrokusumo, 16130-1645) ហើយចាប់ផ្ដើមធ្លាក់ចុះ នៅពេលព្រះអង្គសោយទិវង្គតនៅឆ្នាំ១៦៤៥។<br><br>រាជាណាចក្រម៉ាតារ៉ាំ ក្នុងរាជ្យស៊ុលតង់ អាហ្គុង ហាន់យ៉ូក្រូគូស៊ូម៉ូ</td>
</tr>
<tr>
<td>១១៤- ចក្រភពម៉ារ៉ាថា<br>អ. Maratha Empire<br>បារ. Empire marathe</td>
<td>រដ្ឋដែលមានអត្ថិភាពពីឆ្នាំ១៦៧៤ដល់ឆ្នាំ១៨២០ គ្រប់គ្រងដោយព្រះចៅស៊ីវ៉ាហ្ស៊ី(Shivâjî, 1674-1680) និងចុងក្រោយគឺព្រះចៅប្រាតាស៊ីង (Pratapsingh, 1808-1818)។ នៅឆ្នាំ១៦៧៤ ចក្រភពនេះមានផ្ទៃដីទំហំ២ ៨០០ ០០០ គ.ម$^2$។ រាជធានីនៃចក្រភពនេះគឺរ៉ៃហ្គាដ(Raigad)។ អតីតចក្រភពនេះ សព្វថ្ងៃជាផ្នែកខ្លះនៃប្រទេសបង់ក្លាដែស ឥណ្ឌា និងប៉ាគីស្ថាន។ ប្រជាជននៃចក្រភពនេះគោរពសាសនាហិណ្ឌូ និងប្រើភាសាម៉ារ៉ាធី(Marathi)។ ចក្រភពនេះបានដួលរលំ ហើយត្រូវបានបញ្ចូលទៅក្នុងដែនដីឥណ្ឌាអង់គ្លេស នៅឆ្នាំ១៨២០។<br><br><br>ចក្រភពម៉ារ៉ាថា ពីឆ្នាំ១៦៧៤ដល់ឆ្នាំ១៨១៨</td>
</tr>
</table>

| | |
|---|---|
| **១១៥- រាជាណាចក្រ<br>ស៊ុលតង់យោគយ៉ាកាតា**<br>អ. Yogyakarta Sultanate<br>បារ. Sultanat de Yogyakarta | រដ្ឋដែលមានអត្ថិភាពពីឆ្នាំ១៧៥៥ដល់ឆ្នាំ១៩៤៥ គ្រប់គ្រងដោយស៊ុលតង់អ៊ីកហាមេងគូ(ISKS Hamengku, 1755-1792) និងស៊ុលតង់ចុងក្រោយអ៊ីកហាមេងគូ ប៊ូវ៉ូណូទី៩(ISKS Hamengku Buwono IX, 1940-1950)។ រាជធានីនៃរាជាណាចក្រនេះគឺ យោគយ៉ាកាតា។ រាជាណាចក្រនេះបង្កើតឡើងក្រោយពីមានសន្ធិសញ្ញាហ្ស៊ីយ៉ង់ទី(Giyanti)ថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ១៧៥៥។ ប្រជាជននៃរាជាណាចក្រនេះគោរពសាសនាអ៊ិស្លាមនិងប្រើភាសាជ្វា។ រាជាណាចក្រនេះបានទទួលឯករាជ្យពីហូឡង់នៅថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ១៨៣០។ នៅថ្ងៃទី១៥ ខែសីហា ឆ្នាំ១៩៤៥ រាជាណាចក្រនេះត្រូវបានបញ្ចូលទៅក្នុងប្រទេសឥណ្ឌូណេស៊ី។<br><br><br>រាជាណាចក្រស៊ុលតង់យោគយ៉ាកាតា ឆ្នាំ១៨៣០ |
| **១១៦- ចក្រភពឥណ្ឌា<br>អង់គ្លេស**<br>អ. British Raj<br>បារ. Raj britannique | រដ្ឋនៅអនុទ្វីបឥណ្ឌាដែលមានអត្ថិភាពពីឆ្នាំ១៨៥៨ដល់ឆ្នាំ១៩៤៧។ ចក្រភពនេះបង្កើតឡើងដោយអាណានិគមអង់គ្លេសលើប្រទេសឥណ្ឌា ដែលមានផ្ទៃដីទំហំ ៤ ៩០៣ ៣១២ គ.ម$^{២}$ (ឆ្នាំ១៩៣៨)។ ប្រជាជននៃចក្រភពនេះប្រើភាសាអង់គ្លេសនិងភាសាផ្សេងៗទៀតតាមតំបន់នានា។ រាជធានីនៃចក្រភពនេះគឺកាល់កាត្តា(Calcutta)និងញូវដែលី(New Delhi)។ អតីតចក្រភពនេះ សព្វថ្ងៃជាប្រទេសឥណ្ឌា ផ្នែកខ្លះនៃប្រទេសបង់ក្លាដែស មីយ៉ាន់ម៉ា និងប៉ាគីស្ថាន។ ចក្រភពនេះបានបញ្ចប់នៅពេលដែលឥណ្ឌាបានទទួលឯករាជ្យនៅឆ្នាំ១៩៤៧។<br><br>ចក្រភពឥណ្ឌាអង់គ្លេស |

<table>
<tr>
<td>១១៧- ចក្រភពសេហ្វាវីដ<br>អ. Safavid Empire<br>បារ. Empire Séfévide</td>
<td>រដ្ឋនៅចក្រភពពែរ្ស(អ៊ីរ៉ង់បច្ចុប្បន្ន)ដែលមានអត្ថិភាពពីឆ្នាំ១៥០១ដល់ឆ្នាំ១៧៣៦ គ្រប់គ្រងដោយព្រះចៅអ៊ីស្មាអ៊ីលទី១(Ismail I, ១៥០១-១៥២៤) និងចុងក្រោយដោយព្រះចៅអាបាសទី៣(Abbas III, ១៧៣២-១៧៣៦។ រាជធានីនៃចក្រភពនេះគឺ តាប្រ៊ីស(Tabriz) កាសវីន(Qazvin) និងអ៊ីសប៉ាហាន់(Ispahan)។ អតីតចក្រភពនេះ សព្វថ្ងៃជាផ្នែកខ្លះនៃប្រទេសអាហ្វហ្គានីស្ថាន អាមេនី អាស៊ែបៃហ្សង់ ហ្សកហ្ស៊ី អ៊ីរ៉ង់ អ៊ីរ៉ាក់ កូវ៉ែត ប៉ាគីស្ថាន រុស្ស៊ី ស៊ីរី តួកគី តួកម៉េនីស្ថាន និងអ៊ូសបេគីស្ថាន។ ប្រជាជននៃចក្រភពនេះគោរពសាសនាអ៊ិស្លាម និងប្រើភាសាពែរ្ស និងអាស៊ែបៃហ្សង់។<br><br><br>ចក្រភពសេហ្វាវីដក្នុងរាជ្យស្តេចសះ អាបាស់មហារាជ</td>
</tr>
<tr>
<td>១១៨- ចក្រភពសាសានីដ<br>អ. Sasanian Empire<br>បារ. Empire sassanide</td>
<td>រដ្ឋដែលមានអត្ថិភាពពីឆ្នាំ២២៤ដល់ឆ្នាំ៦៥១គ្រប់គ្រងដោយព្រះចៅអាដាសៀទី១(Ardashir I, ២២៤-២៤១) និងចុងក្រោយគឺព្រះចៅសដឺហ្គែដទី៣(Yazdegerd III, ៦៣២-៦៥១)។ ចក្រភពនេះមានផ្ទៃដីទំហំ៦ ៦០០ ០០០ គ.ម$^{២}$។ រាជធានីនៃចក្រភពនេះ គឺអ៊ីស្តាក(Istakhr) និងតេស៊ីផុន(Ctesiphon)។ អតីតចក្រភពនេះសព្វថ្ងៃជាផ្នែកខ្លះនៃប្រទេសអាហ្វហ្គានីស្ថាន អាមេនី អាស៊ែ-បៃហ្សង់ ឥណ្ឌា អេហ្ស៊ីប អ៊ីរ៉ង់ អ៊ីរ៉ាក់ អ៊ីស្រាអែល និងប្រទេសអាស៊ីខ្លះទៀត។ ប្រជាជននៃចក្រភពនេះប្រើភាសាពែរ្ស និងភាសាផ្សេងៗទៀតតាមតំបន់នានា ។</td>
</tr>
<tr>
<td>១១៩- ក្រុមហ៊ុនអង់គ្លេស នៃឥណ្ឌាខាងកើត<br>អ. East India Company<br>បារ. Compagnie britannique des Indes orientales</td>
<td>ក្រុមហ៊ុនអង់គ្លេស ដែលបង្កើតឡើងនៅឆ្នាំ១៦០០ តាមព្រះរាជបញ្ជារបស់មហាក្សត្រី អេលីសាបែតទី១(Élisabeth I) ដើម្បីជំរុញវិស័យពាណិជ្ជកម្មជាមួយនឹងបណ្តាប្រទេសនៃឧបទ្វីបឥណ្ឌា។ ក្រោយមកក្រុមហ៊ុននេះត្រូវបានគេស្គាល់ថា ក្រុមហ៊ុនភាគហ៊ុនអង់គ្លេស ហើយត្រូវបានរំលាយនៅឆ្នាំ១៨៧៤។ ស្នាក់ការរបស់ក្រុមហ៊ុននេះតាំងនៅទីក្រុងឡុងដ៍នៃប្រទេសអង់គ្លេស។</td>
</tr>
<tr>
<td>១២០- សហភាពសាធារណរដ្ឋសង្គមនិយមសូវៀត</td>
<td>រដ្ឋសហព័ន្ធដែលមានអត្ថិភាពពីឆ្នាំ១៩២២ដល់ឆ្នាំ១៩៩១ ដឹកនាំដោយឯកបក្សតាមលទ្ធិកុម្មុយនីស្ត។ សហភាពនេះត្រូវបានបង្កើតឡើង</td>
</tr>
</table>

| | |
|---|---|
| អ. Union of Soviet Socialist Republics<br>បារ. Union des Républiques Socialistes Soviétiques | ដោយរដ្ឋជាសមាជិកចំនួន១៥ និងមានរដ្ឋធានីតាំងនៅទីក្រុងមូស្គូ។ រដ្ឋទាំង១៥នោះរួមមាន៖ សហព័ន្ធរុស្ស៊ី អ៊ុយក្រែន បេឡារុស ម៉ុលដាវី លីទុយអានី ឡេតូនី អេស្តូនី អាមេនី ហ្សកហ្ស៊ី អាស៊ែបៃហ្សង់ កាហ្សាក់ស្ថាន អ៊ូសបេគីស្ថាន តាហ្ស៊ីគីស្ថាន តួកម៉េនីស្ថាន និងកៀហ្ស៊ីស៊ីស្ថាន។ សហភាពនេះមានផ្ទៃដីទំហំ ២២ ៤០២ ២០០ គ.ម$^2$ និងមានប្រជាជនប្រមាណ២៩៣ ០៤៧ ៥៧១ នាក់ (ឆ្នាំ១៩៩១)។ មេដឹកនាំសំខាន់ៗនៃសហភាពសាធារណរដ្ឋសង្គមនិយមសូវៀត រួមមាន វ្លាឌីមៀ លេនីន (Vladimir Lenin) ជាអគ្គលេខាធិការបក្ស(ប្រមុខរដ្ឋ) ដំបូង និង មីខាអ៊ីល ហ្គ័របាឆូវ (Mikhail Gorbachev) ជាអគ្គលេខាធិការបក្សចុងក្រោយនៃសហភាពសាធារណរដ្ឋសង្គមនិយមសូវៀត (១៩៨៥-១៩៩១)។<br><br>ទឹកដីនៃសហភាពសាធារណរដ្ឋសង្គមនិយមសូវៀត |
| **១២១- សាលត៍**<br>(កិច្ចចរចាកម្រិតអាវុធយុទ្ធសាស្ត្រ)<br>អ. Strategic Arms Limitation Talks<br>បារ. Pourparlers sur la limitation des armes stratégiques | ការចរចាស្តីពីការកំណត់កម្រិតអាវុធយុទ្ធសាស្ត្រ។ អាវុធយុទ្ធសាស្ត្រប្រើសម្រាប់បាញ់តម្រង់ទៅដល់ទឹកដីបច្ចាមិត្ត (ផ្ទុយពីអាវុធធម្មតាដែលប្រើបានត្រឹមទីសមរភូមិប៉ុណ្ណោះ)។ សហរដ្ឋអាម៉េរិកនិងសហភាពសាធារណរដ្ឋសង្គមនិយមសូវៀតបានចុះហត្ថលេខាលើសន្ធិសញ្ញានេះចំនួនពីរលើកមកហើយ គឺសាល់ត៍១(SALT-I) ថ្ងៃទី២៦ ខែឧសភា ឆ្នាំ១៩៧២ និងសាល់ត៍២(SALT-II) នៅថ្ងៃទី១៦ ខែមិថុនា ឆ្នាំ១៩៧៩ ប៉ុន្តែសន្ធិសញ្ញាចុងក្រោយនេះពុំបានទទួលសច្ចាប័នពីព្រឹទ្ធសភាអាម៉េរិកទេ។ នៅក្នុងអំឡុងឆ្នាំ១៩៨០ កិច្ចព្រមព្រៀងសាល់ត៍ត្រូវបានជំនួសដោយកិច្ចព្រមព្រៀងស្តារត៍(START) វិញ។ |
| **១២២- ស្តាត**<br>(សន្ធិសញ្ញាកាត់បន្ថយអាវុធយុទ្ធសាស្ត្រ)<br>អ. START (Strategic Arms Reduction Treaty)<br>បារ. Traité de réduction des armes stratégiques | សន្ធិសញ្ញាផ្តើមចេញពីសហរដ្ឋអាម៉េរិក(ស.រ.អា.)-សហភាពសាធារណរដ្ឋសង្គមនិយមសូវៀត(ស.ស.ស.ស.) ហើយត្រូវបានចុះហត្ថលេខាលើកទី១ (ស្តាត១) ដោយស.រ.អា.- ស.ស.ស.ស. និងលើកទី២(ស្តាត២) ដោយអាម៉េរិក រុស្ស៊ី បេឡារុស អ៊ុយក្រែន និងកាហ្សាក់ស្ថាន។ សន្ធិសញ្ញាទាំងនេះត្រូវបានបង្កើតឡើងដើម្បីកាត់បន្ថយអាវុធនុយក្លេអ៊ែរនិងអាវុធយុទ្ធសាស្ត្រផ្សេងទៀត។ |



B-52 détruits à la suite du traité de réduction des armes stratégiques.
B-52 Bombers cut up in Arizona for compliance with Russian Treaty, Dec 23, 2013

**១២៣- ស្តាត១**
(សន្ធិសញ្ញាកាត់បន្ថយអាវុធយុទ្ធសាស្ត្រ)
អ. START I (Strategic Arms Reduction Treaty I)
បារ. Traité de réduction des armes stratégiques I

ស្តាត១ ត្រូវបានចុះហត្ថលេខានៅថ្ងៃទី៣១ ខែកក្កដា ឆ្នាំ១៩៩១ ដោយសហរដ្ឋអាមេរិក(ស.រ.អា.) និងសហភាពសាធារណរដ្ឋសង្គមនិយមសូវៀត (ស.ស.ស.ស.)។ ៥ខែក្រោយមក ស.ស.ស.ស. ត្រូវបានដួលរលំ ហើយបន្សល់ទុកនូវរដ្ឋឯករាជ្យ៤ដែលមានអាវុធនុយក្លេអ៊ែរជាយុទ្ធសាស្ត្រៈ រុស្ស៊ី (Russia) បេឡារុស(Belarus) អ៊ុយក្រែន(Ukraine) និងកាហ្សាក់ស្ថាន (Kazakhstan)។ នៅថ្ងៃទី២៣ ខែឧសភា ឆ្នាំ១៩៩២ ស.រ.អា. និងរដ្ឋ៤ទៀតដែលបន្តពីស.ស.ស.ស. បានចុះហត្ថលេខាលើពិធីសារលីស្បោន ដើម្បីឱ្យប្រជាជាតិទាំង៥នេះចូលទៅក្នុងក្របខណ្ឌនៃកិច្ចព្រមព្រៀង។

ស្តាត១បានចូលជាធរមាននៅថ្ងៃទី៥ ខែធ្នូ ឆ្នាំ១៩៩៤ នៅពេលដែលភាគីទាំងប្តូរលិខិតូបករណ៍នៃសច្ចាប័ននៅទីក្រុងប៊ុយដាប៉ែស(Budapest)។ សន្ធិសញ្ញានេះត្រូវបានបញ្ចប់នៅថ្ងៃទី៥ ខែធ្នូឆ្នាំ២០០៩។



ប្រធានាធិបតី **ហ្សក ប៊ូស** និង **មីខាអ៊ីល ហ្គោរបាឆូវ** ចុះហត្ថលេខាលើកិច្ចព្រមព្រៀងស្តារត៍ នៅថ្ងៃទី៣១ ខែកក្កដា ឆ្នាំ១៩៩១។

| | |
|---|---|
| **១២៤- រដ្ឋ**<br>អ. State<br>បារ. Etat (m.) | សហគមន៍នយោបាយមួយ ដែលមានការចាត់តាំងនៅក្រោមប្រព័ន្ធរដ្ឋាភិបាលមួយ(នីតិបញ្ញត្តិ នីតិប្រតិបត្តិ និងតុលាការ)។ រដ្ឋមានលក្ខណៈសម្គាល់៤ យ៉ាងគឺ ទឹកដី ប្រជាជន រដ្ឋាភិបាល និងសមត្ថភាពគតិយុត្ត ក្នុងទំនាក់ទំនងជាមួយរដ្ឋផ្សេងទៀត។ ក៏ប៉ុន្តែ នៅក្នុងប្រទេស ដូចជា សហរដ្ឋអាម៉េរិក អូស្ត្រាលី និងប្រេស៊ីល ជាដើម ពាក្យថា*រដ្ឋ* ក៏សំដៅទៅលើអង្គភាពនយោបាយដែរ ប៉ុន្តែ មិនមានអធិបតេយ្យភាព និងស្ថិតនៅក្រោមអំណាចកណ្តាលមួយ ហៅថា*រដ្ឋសហព័ន្ធ*។ រដ្ឋមួយអាចមានប្រជាជាតិច្រើនដូចជា ចក្រភពអង់គ្លេស ឥណ្ឌា ជាដើម។ |
| **១២៥- ប្រជាជាតិ**<br>អ. Nation<br>បារ. Nation (f.) | សហគមន៍មនុស្សដែលត្រូវបានបង្កើតឡើងតាមដំណើរប្រវត្តិសាស្ត្រមានលក្ខណៈសម្គាល់រួមគ្នា ដូចជា ភាសា ទំនៀមទម្លាប់ ប្រពៃណី និងពូជសាសន៍ ពោលគឺ សហគមន៍វប្បធម៌-នយោបាយ ដែលមានមនសិការចំពោះស្វ័យភាព ឯកភាព និងផលប្រយោជន៍ដោយឡែក។ ប្រជាជាតិខ្លះពុំមានរដ្ឋទេ។ គេមានទឹកដី និងប្រជាជន ប៉ុន្តែ ពុំមានអង្គការនយោបាយសម្រាប់ធានាអធិបតេយ្យភាពពេញលេញនោះឡើយ ដូចជា ប្រជាជាតិកួឌីស្ថាន(Kurdistan)។ |
| **១២៦- ប្រទេស**<br>អ. Country<br>បារ. Pays (m.) | ទឹកដីនៃប្រជាជាតិមួយ ដែលកំណត់ដោយព្រំដែន នៅក្នុងទីតាំងភូមិសាស្ត្រមួយ(geographical area)។ ប្រទេសមួយអាចជារដ្ឋដែលមានឯករាជ្យភាពនិងអធិបតេយ្យភាព ឬអាចជារដ្ឋគ្មានឯករាជ្យភាពនិងគ្មានអធិបតេយ្យភាព។ ឧទាហរណ៍ ប្រទេសកម្ពុជានៅក្រោមអាណាព្យាបាលបារាំងពីថ្ងៃទី១១ ខែសីហា ឆ្នាំ១៨៦៣ដល់១៩៥៣ ជារដ្ឋគ្មានអធិប-តេយ្យភាព។ ចាប់ពីថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ១៩៥៣ ប្រទេសកម្ពុជាបានក្លាយជារដ្ឋឯករាជ្យនិងអធិបតេយ្យ។ |
| **១២៧- រដ្ឋ-ប្រជាជាតិ**<br>អ. Nation-State<br>បារ. Etat-Nation (m.) | ទម្រង់មួយនៃអង្គការនយោបាយ ដែលនៅក្នុងនោះ សហគមន៍មនុស្សដែលមានប្រវត្តិសាស្ត្រ ប្រពៃណី ភាសា និងពូជសាសន៍ដូចគ្នា រស់នៅក្រោមរដ្ឋា-ភិបាលមួយ ពោលគឺការត្រួតគ្នារវាង*រដ្ឋ* ដែលជាអង្គការនយោបាយនិង *ប្រជា-ជាតិ* ដែលផ្តោតលើអត្តសញ្ញាណនៃសហគមន៍មនុស្ស។<br>ឧ. ប្រទេសជប៉ុន បើមិនមានការត្រួតគ្នាបែបនេះទេ គេហៅថា*រដ្ឋពហុជាតិ*។ |
| **១២៨- រដ្ឋពហុជាតិ**<br>អ. Multinational State<br>បារ. Etat multinational (m.) | រដ្ឋអធិបតេយ្យមួយ ដែលមានប្រជាជាតិពីរឬច្រើននៅក្នុងនោះ ខុសពីរដ្ឋ-ប្រជាជាតិ ដែលមានតែប្រជាជាតិមួយ។ រដ្ឋពហុជាតិក៏អាចជារដ្ឋដែលមានពហុវប្បធម៌ ពហុភាសា និង/ឬពហុពូជសាសន៍ ដូចជា សហរដ្ឋអាម៉េរិក រុស្ស៊ី ឥណ្ឌា ចិន ជាដើម។ |

| | |
|---|---|
| **១២៩- ឯកត្តរដ្ឋ**<br>អ. Unitary State<br>បារ. Etat unitaire ( m. ) | រដ្ឋគ្រប់គ្រងដោយអំណាចកណ្តាលមួយដែលមានរបបនយោបាយនិងគតិយុត្តតែមួយ។ |
| **១២៨- រដ្ឋសហព័ន្ធ**<br>អ. Federal State<br>បារ. Etat Fédéral ( m. ) | ដែនដីនៃសហគមប្រជាជាតិណាមួយ ដែលប្រព័ន្ធគ្រប់គ្រងមានពីរកម្រិតគឺមានការបែងចែកអំណាចរវាងរដ្ឋាភិបាលសហព័ន្ធ និងរដ្ឋាភិបាលនៃរដ្ឋជាសមាជិក។ រដ្ឋាភិបាលទាំងពីរកម្រិតមានការបែងចែកសមត្ថកិច្ចខុសគ្នាដែលក្នុងនោះ រដ្ឋាភិបាលសហព័ន្ធមានសមត្ថកិច្ចផ្តាច់មុខសំខាន់ៗយ៉ាងតិចបួនគឺវិស័យការពារជាតិ វិស័យការបរទេស វិស័យបោះពុម្ព ក្រដាសប្រាក់ និងវិស័យពាណិជ្ជកម្មអន្តរជាតិ។<br>ឧ. ប្រទេសកាណាដា សហរដ្ឋអាម៉េរិក ឥណ្ឌា ។ល។ ជារដ្ឋសហព័ន្ធ។ |
| **១២៩- រដ្ឋអធិបតេយ្យ**<br>អ.  Sovereign State<br>បារ. Etat souverain ( m. ) | រដ្ឋដែលមានប្រជាជនរស់នៅជាអចិន្ត្រៃយ៍ មានទឹកដីមួយជាកំណត់មានរដ្ឋា-ភិបាលដែលមិនស្ថិតនៅក្រោមអំណាចនៃរដ្ឋផ្សេងទៀត និងមានសមត្ថភាពគតិយុត្តទាក់ ទងជាមួយរដ្ឋដទៃទៀត។ |
| **១៣០- រដ្ឋចំណុះ**<br>អ.  Dependent State<br>បារ. Etat dépendant<br>( m. ) | រដ្ឋដែលមិនអាចប្រើប្រាស់អំណាចពេញលេញទៅលើកិច្ចការបរទេសនិងយោធាបាន តែអាចទទួលបានពីរដ្ឋត្រួតត្រាមហាអំណាចអាណានិគម ឬមហា-អំណាច អាណាព្យាបាលនូវស្វ័យភាពផ្ទៃក្នុងមួយចំនួន។<br>សម្គាល់៖<br>បច្ចេកសព្ទមួយចំនួន ដែលប្រើសម្រាប់សម្គាល់រដ្ឋចំណុះនោះ មានដូចជារដ្ឋក្រោមអាណត្តិ(នៃសង្គមប្រជាជាតិ) រដ្ឋក្រោមអាណាព្យាបាល ជាដើម។ ចាប់ពីឆ្នាំ១៩៤៥ មានសម្ពាធអន្តរជាតិយ៉ាងខ្លាំង ដើម្បីឱ្យលុបបំបាត់ភាពជាចំណុះ ដែល ជាប់ទាក់ទងនឹងលទ្ធិអាណានិគមនិយម។ |

## II.២.៣- បច្ចេកសព្ទស្នើដោយគណៈកម្មការភូមិវិទ្យា

| | |
|---|---|
| **១- ភូមិវិទ្យា**<br>អ.geography<br>បារ.géographie | វិទ្យាសាស្ត្រដែលសិក្សាអំពីផែនដី រួមបញ្ចូលទាំងរបាយមនុស្ស សត្វ រុក្ខជាតិ និងបម្រែបម្រួលទាំងឡាយដោយសារធម្មជាតិឬដោយសារសកម្មភាពមនុស្ស (បាតុភូតរូបនិងបាតុភូតសង្គម)។ ភូមិវិទ្យាចែកជាពីរផ្នែក គឺ ភូមិវិទ្យារូបនិងភូមិវិទ្យាមនុស្ស។ |
| **២- ផែនដីវិទ្យា**<br>អ.earth science/geo-science<br>បារ.science de la terre | វិទ្យាសាស្ត្រដែលសិក្សាអំពីធរណីវិទ្យា/ភូគព្ភវិទ្យា ឧតុភូតវិទ្យា សាគរវិទ្យា និងតារាវិទ្យា។<br>ឧ. ការសិក្សាអំពីផែនដីក្នុងប្រព័ន្ធព្រះអាទិត្យ ជាផ្នែកមួយនៃផែនដីវិទ្យា។ |

| | |
|---|---|
| **៣- ភូមិវិទ្យារូប**<br>អ.physical geography<br>បារ.géographie physique | ផ្នែកមួយនៃភូមិវិទ្យាដែលសិក្សាអំពីផ្នែកខាងក្រៅរបស់ផែនដី មានសណ្ឋានដី ជលធារ អាកាសធាតុ របាយរុក្ខជាតិនិងសត្វ និងបម្រែបម្រួលទាំងឡាយ ដោយសារធម្មជាតិឬដោយសារសកម្មភាពមនុស្ស។<br>ឧ. ការសិក្សាអំពីអាកាសធាតុនិងគម្របព្រៃឈើ ជាផ្នែកមួយនៃភូមិវិទ្យារូប។ |
| **៤- ធរណីវិទ្យា/ភូគព្ភវិទ្យា**<br>អ.geology<br>បារ.géologie | វិទ្យាសាស្ត្រដែលសិក្សាអំពីរចនាសម្ព័ន្ធរូបវន្តនៃផែនដី រួមបញ្ចូលទាំងកំណកំណើត សមាសភាគ ទម្រង់ និងប្រវត្តិរបស់វា តាមរយៈការសិក្សាសិលាផ្សេងៗ។<br>ឧ. ការសិក្សាអំពីកំណកំណើតជួរភ្នំធំៗជាផ្នែកមួយនៃធរណីវិទ្យា។ |
| **៥- ភូមិសណ្ឋានវិទ្យា**<br>អ.geomorphology<br>បារ.géomorphologie | វិទ្យាសាស្ត្រដែលសិក្សាអំពីទម្រង់ផ្ទៃផែនដី រួមមានកំណកំណើត ទ្រង់ទ្រាយ និងការវិវត្តរបស់វា។<br>ឧ. ជួរភ្នំក្រវាញ តំបន់ទំនាបកណ្ដាល និងតំបន់ខ្ពង់រាបឦសាន ជាផ្នែកសំខាន់ៗនៃភូមិសណ្ឋានវិទ្យាប្រទេសកម្ពុជា។ |
| **៦- រូបសាស្ត្រផែនដី**<br>អ.geophysics<br>បារ.géophysique(f.) | ការសិក្សាអំពីផែនដីតាមរយៈបច្ចេកទេសរូបវិទ្យា ដូចជា ទម្រង់រួមនិងចលនាផ្សេងៗ ទៅលើបាតុភូត ឧតុភូត ជលធារ សាគរ ការរញ្ជួយដី បន្ទុះភ្នំភ្លើង ម៉ាញេទិក ជាដើម។ |
| **៧- ផ្លូវទឹក**<br>អ. waterway<br>បារ. cours d'eau (f.) | សមាសភាគនៃបណ្ដាញជលធារ ដូចជាមហាសមុទ្រ សមុទ្រ ទន្លេ ស្ទឹង ព្រែក ព្រែកជីក ប្រឡាយ ជ្រោះ បឹង ជាដើម។ |
| **៨- មហាសមុទ្រ**<br>អ. ocean<br>បារ. océan (m.) | វិសាលភាពទឹកប្រៃដ៏ធំល្វឹងល្វើយគ្របដណ្ដប់ប្រមាណ៧០% នៃផ្ទៃផែនដីទាំងមូល។ មហាសមុទ្រ មានមហាសមុទ្រប៉ាស៊ីហ្វិក មហាសមុទ្រអាត្លង់ទិក មហាសមុទ្រឥណ្ឌា មហាសមុទ្រអាកទិក មហាសមុទ្រអង់តាកទិក ឬមហាសមុទ្រខាងត្បូង។ |
| **៩- សមុទ្រ**<br>អ. sea<br>បារ. mer (f.) | វិសាលភាពទឹកប្រៃដែលគ្របដណ្ដប់លើផ្នែកណាមួយនៃផ្ទៃផែនដី(សមុទ្រក្នុង) ឬជាចំណែកណាមួយនៃមហាសមុទ្រ។ |
| **១០- សមុទ្រក្នុង**<br>អ. inland sea<br>បារ. mer intérieure | វិសាលភាពទឹកប្រៃដែលគ្របដណ្ដប់លើផ្នែកណាមួយនៃផ្ទៃផែនដី ហើយ ព័ទ្ធជុំវិញដោយផ្ទៃដីឬមានច្រកចង្អៀតណាមួយភ្ជាប់ទៅសមុទ្រឬមហាសមុទ្រ។<br>ឧ. សមុទ្រកាសព្យែន (តំបន់អាស៊ីកណ្ដាល) សមុទ្រមេឌីទែរ៉ានេ (ចន្លោះទ្វីបអឺរ៉ុប អាហ្វ្រិក និង អាស៊ី)។ |
| **១១- ទន្លេ**<br>អ. river<br>បារ. fleuve (m.) | ផ្លូវទឹកធម្មជាតិដែលទទួលទឹកពីស្ទឹង ព្រែក ជ្រោះ អូរ ទឹកក្រោមដីនិងពីតំបន់ផ្ទៃរងទឹកភ្លៀងនៅផ្នែកខាងលើ ហើយហូរចាក់ទៅសមុទ្រ។<br>ឧ. ទន្លេមេគង្គ ទន្លេបាសាក់ ទន្លេសាប ទន្លេតូច។ |
| **១២- ទន្លេអន្តរជាតិ**<br>អ. international river | ទន្លេដែលហូរកាត់ភូមិសាស្ត្រប្រទេសចាប់ពី២ឡើងទៅ។<br>ឧ.ទន្លេមេគង្គ។ |

| | |
|---|---|
| **១៣- អាងទន្លេ**<br>អ. catchment area<br>បារ. bassin fluvial | តំបន់ភូមិសាស្ត្រដែលកំណត់ដោយព្រំប្រទល់ផ្ទៃជម្រាលទទួលទឹកភ្លៀងបង្កើតជាប្រព័ន្ធទឹកហូរ ដោយរាប់បញ្ចូលទាំងទឹកលើដីនិងទឹកក្រោមដី។ អាងទន្លេដែលធំ មានអាងទន្លេរង។<br>ឧ. អាងទន្លេមេគង្គលើនៃប្រទេសកម្ពុជា(ផ្ទៃ ១០ ៣៧៣ គ.ម$^{២}$)។ |
| **១៤- អាងទន្លេរង**<br>អ. sub-catchment area<br>បារ. bassin fluvial | ផ្នែកណាមួយនៃអាងទន្លេដែលធំ។<br>ឧ. អាងទន្លេសេសាន(ផ្ទៃ ៧ ៦២១ គ.ម$^{២}$) ជាអាងទន្លេរងនៃអាងទន្លេមេគង្គលើក្នុងប្រទេសកម្ពុជា។ |
| **១៥- អាងទឹក**<br>អ. reservoir<br>បារ. réservoir (m.) | ទីតម្កល់ទឹកដែលកើតឡើងដោយធម្មជាតិឬដោយមនុស្ស សម្រាប់ប្រើប្រាស់។<br>ឧ. អាងទឹកកំពីងពួយ(ខេត្តបាត់ដំបង)។ |
| **១៦- ព្រែក**<br>អ. small river<br>បារ. rivière (f.) | ផ្លូវទឹកធម្មជាតិដែលនាំទឹកចេញឬចូលពីទន្លេ ស្ទឹង ឬ សមុទ្រ និង ពីតំបន់ផ្ទៃរងទឹកភ្លៀងនៅផ្នែកខាងលើ។<br>ឧ. ព្រែកព្នៅ(រាជធានីភ្នំពេញ) ព្រែកឆ្លូង(ខេត្តក្រចេះ) ព្រែកកំពត (ខេត្តកំពត)។ |
| **១៧- ព្រែកជីក**<br>អ. canal<br>បារ. canal (m.) | ផ្លូវទឹកដែលគេជីកសម្រាប់នាំទឹក និង/ឬ នាវាចរណ៍។<br>ឧ. ព្រែកជីកភ្នំដា(ខេត្តតាកែវ) ព្រែកជីកស៊ុយអេ(ប្រទេសអេហ្ស៊ីប) ព្រែកជីកប៉ាណាម៉ា(ប្រទេសប៉ាណាម៉ា)។ |
| **១៨- ប្រឡាយ**<br>អ. creek<br>បារ. ruisseau (m.) | ផ្លូវទឹកតូចដែលគេជីកសម្រាប់នាំទឹក។ |
| **១៩- ស្ទឹង**<br>អ. river<br>បារ. rivière (f.) | ផ្លូវទឹកសាបធម្មជាតិដែលទទួលប្រភពទឹកមកពី ជ្រោះ អូរ ទឹកក្រោមដី និងពីតំបន់ផ្ទៃរងទឹកភ្លៀងនៅផ្នែកខាងលើ ហើយហូរចាក់ទៅបឹង ទន្លេ ឬសមុទ្រ។<br>ឧ. ស្ទឹងសង្កែក្នុងខេត្តបាត់ដំបងហូរចូលបឹងទន្លេសាប ស្ទឹងជាយអារ៉ែងក្នុងខេត្តកោះកុងហូរចូលសមុទ្រ។ |
| **២០- អូរ**<br>អ. stream<br>បារ. ruisseau (m.) | ផ្លូវទឹកធម្មជាតិតូចដែលទទួលប្រភពទឹកមកពីជ្រោះ និង ពីតំបន់ផ្ទៃរងទឹកភ្លៀងនៅផ្នែកខាងលើ ហើយដែលអាចហូរចូលក្នុងផ្លូវទឹកណាមួយ ដូចជា ព្រែក ស្ទឹង ទន្លេ បឹង សមុទ្រ...។ អូរតូចជាងស្ទឹងឬព្រែក ហើយពេលខ្លះគ្មានទឹក។<br>ឧ. អូរបើជាន់និងអូរជ្រៅ(ខេត្តបន្ទាយមានជ័យ) អូរពងមាន់ក្នុងខេត្តស្ទឹងត្រែងហូរចូលទន្លេមេគង្គ អូរគ្រេះនិងអូរឈើទាលក្នុងខេត្តព្រះសីហនុ ហូរចូលសមុទ្រ។ |
| **២១- ជ្រោះ**<br>អ. torrent<br>បារ. torrent (m.) | ផ្លូវទឹកឬល្បាក់ទឹកធម្មជាតិនៅតំបន់ភ្នំឬខ្ពង់រាប មានចំណោតខ្លាំង ហើយ មានទឹកមិនទៀងទាត់។ |

| | |
|---|---|
| | ឧ. ជ្រោះភ្នំគូលែន(ខេត្តសៀមរាប) ជ្រោះពេជ្រនិល(ខេត្តកំពង់ស្ពឺ) ជ្រោះប៊ូស្រា(ខេត្តមណ្ឌលគិរី) ជ្រោះសុភមិត្រ(ខេត្តស្ទឹងត្រែង)។ |
| **២២- បឹង**<br>អ. lake<br>បារ. lac (m.) | សមាសភាគនៃបណ្ដាញជលធារ ដូចជាមហាសមុទ្រ សមុទ្រ ទន្លេ ស្ទឹង ព្រែក ព្រែកជីក ប្រឡាយ ជ្រោះ បឹង ជាដើម។ |
| **២៣- បឹងទឹកប្រៃ**<br>អ. salt water lake | ហោលទឹកប្រៃដែលដាច់ចេញពីសមុទ្រ ហើយមានជាតិកម្រិតជាតិប្រៃខ្ពស់។<br>ឧ. បឹងគ្រីតសលឡេក (Great salt Lake) នៅសហរដ្ឋអាម៉េរិក។ |
| **២៤- ជ្រលង**<br>អ.valley<br>បារ. vallée (f.) | កំហូងវែងនៅចន្លោះភ្នំឬចន្លោះទីខ្ពស់ មានមាត់លើធំឬតូច មានទឹកឬគ្មានទឹក។ |
| **២៥- ជលវិទ្យា**<br>អ. hydrology<br>បារ. hydrologie (f.) | វិទ្យាសាស្ត្រដែលសិក្សាអំពីទឹករបស់ផែនដី(ទឹកសាបនិងទឹកប្រៃ) រួមបញ្ចូលទាំងវដ្តទឹក លក្ខណៈរូបនិងលក្ខណៈគីមីរបស់ទឹក ទំនាក់ទំនងជាមួយនឹងធនធានទឹក បរិយាកាស រំហួត កំណកអាកាស លំហូរទឹក និងទឹកក្រោមដី។ |
| **២៦- ជលភូគព្ភវិទ្យា**<br>អ. hydrogeology<br>បារ. hydrogéologie | ផ្នែកនៃភូគព្ភសាស្ត្រដែលសិក្សាអំពីទំនាក់ទំនងរវាងទឹកនិងរចនាសម្ព័ន្ធរូបវន្តទាំង នៅលើផ្ទៃខាងលើនិងនៅខាងក្នុងរបស់ផែនដី។ |
| **២៧- កម្ពស់ទឹកភ្លៀង/ភ្លៀងមាត្រ**<br>អ. rainfall measurement<br>បា. pluviométrie (f.) | បរិមាណនៃកំណកអាកាសដែលធ្លាក់នៅទីកន្លែងណាមួយនិងក្នុងពេលវេលាជាក់លាក់ណាមួយ។ គេគណនាបរិមាណនៃកំណកអាកាសនេះដោយភ្លៀងម៉ែត្រ (ឧបករណ៍វាស់ទឹកភ្លៀង)។ |
| **២៨- វដ្តទឹក**<br>អ. water cycle<br>បារ. cycle de l´eau | ដំណើរវិលជុំបន្តគ្នាមិនដាច់នៃបាតុភូត រំហួត កំណក ចំហាយ លំហូរ... របស់ទឹក។<br>ឧ.វដ្តទឹកពីសមុទ្រទៅបរិយាកាសធ្លាក់មកលើផែនដីហើយត្រឡប់ទៅសមុទ្រវិញ។ |
| **២៩- ជលធារសាស្ត្រ**<br>អ. hydrography<br>បារ. hydrographie(f.) | ផ្នែកមួយនៃភូមិវិទ្យាដែលសិក្សាអំពីប្រព័ន្ធឬបាយផ្លូវទឹក(មហាសមុទ្រ សមុទ្រ បឹង ទន្លេ ស្ទឹង...) នៃតំបន់មួយ រួមមាន វិសាលភាព ប្រភព បណ្ដោយ ភ្នែន និងសណ្ឋានផ្លូវទឹកនោះ។ |
| **៣០- ភ្លៀងម៉ែត្រ**<br>អ. rain gauge/ pluviometer<br>បា. pluviomètre (m.) | ឧបករណ៍សម្រាប់វាស់បរិមាណនៃកំណកអាកាសនៅទីកន្លែងណាមួយ។ |
| **៣១- លំហូរទឹក**<br>អ. run-off<br>បារ. écoulement d`eau | ចលនាទឹកដែលហូរលើដីឬក្រោមដីឆ្ពោះទៅកាន់ខ្សែទឹក ហើយ មានល្បឿនខុសៗគ្នា។ |

| | |
|---|---|
| **៣២- ធារ**<br>អ. water discharge<br>បារ. débit ( m. ) | បរិមាណទឹកដែលហូរនៃផ្លូវទឹកមួយ ក្នុងឯកតាមួយនៃពេលវេលា។ គេគណនាធារដោយគិតអំពីបរិមាណនៃទឹកហូរជាម៉ែត្រគូបក្នុងមួយវិនាទី។ |
| **៣៣- ម៉ូឌុល**<br>អ. module<br>បារ. module ( m. ) | ធារមធ្យមប្រចាំឆ្នាំរបស់ផ្លូវទឹកមួយ។<br>ឧ. ម៉ូឌុលរបស់ទន្លេអាម៉ាហ្សូនមានបរិមាណធំជាងគេបំផុតនៃពិភពលោក គឺ ១២០ ០០០ ម$^{៣}$/វិនាទី។ |
| **៣៤- ផ្នែកទឹកខាងលើ**<br>អ. upstream water<br>បារ. amont ( m. ) | ផ្នែករបស់ផ្លូវទឹកដែលស្ថិតនៅចន្លោះទីកន្លែងណាមួយទៅនឹងប្រភពរបស់វា។ |
| **៣៥- ផ្នែកទឹកខាងក្រោម**<br>អ. downstream water<br>បារ. aval ( m. ) | ផ្នែករបស់ផ្លូវទឹកដែលស្ថិតនៅចន្លោះទីកន្លែងណាមួយទៅនឹងទីបញ្ចប់របស់វា។ |
| **៣៦- ពាម**<br>អ. mouth<br>បារ. embouchure ( f. ) | កន្លែងដែលផ្លូវទឹកជួបគ្នា ឬ ផ្លូវទឹកធំមួយបែកជាផ្លូវទឹកច្រើន។<br>ឧ. ពាមជីកង ពាមសត្វា ពាមប្រជ្ជោះ ពាមរ។ |
| **៣៧- ទីប្រសព្វ**<br>អ. confluence<br>បារ. confluent ( m. ) | កន្លែងដែលផ្លូវទឹកពីរឬច្រើនហូរជួបគ្នាបង្កើតជាផ្លូវទឹកធំមួយ។ |
| **៣៨- ពាមសមុទ្រ**<br>អ. estuary<br>បារ. estuaire ( m. ) | កន្លែងចុងក្រោយនៃទន្លេ ស្ទឹង ព្រែក ប្រសព្វនឹងសមុទ្រ។ |
| **៣៩- ដីសណ្ត**<br>អ. delta<br>បារ. delta ( m. ) | វាលទំនាបបង្កើតឡើងដោយស្រទាប់កម្ទេចកំណដែលចាក់បង្គរបន្តិចម្តងៗ នៅតាមមាត់ទន្លេឬសមុទ្រ នៅពេលល្បឿនទឹកថយចុះ។ វាលទំនាបមួយចំនួនមានរាងជាត្រីកោណដោយសារទន្លេបែកជាដៃតូចៗ មុនហូរចូលទៅសមុទ្រ។<br>ឧ. ដីសណ្តទន្លេមេគង្គ។ |
| **៤០- រដូវទឹកឡើង/ រដូវជំនោរឡើង**<br>អ. flooding season<br>បារ. saison des hautes eaux / saison de crue | រយៈពេលដែលទឹកនៃផ្លូវទឹកណាមួយឡើងខ្ពស់។<br>ឧ. រដូវទឹកឡើងទន្លេមេគង្គ ចាប់ផ្តើមពីខែសីហា។ |
| **៤១- រដូវទឹកស្រក/ រដូវសម្រក**<br>អ. drop in the water level<br>បារ. saison des basses eaux /saison de décrue | រយៈពេលដែលទឹកនៃផ្លូវទឹកណាមួយស្រកចុះ។<br>ឧ. រដូវទឹកស្រកទន្លេមេគង្គ ចាប់ផ្តើមពីខែវិច្ឆិកា។ |

| | |
|---|---|
| **៤២- ទឹកធ្លាក់**<br>អ. waterfall<br>បារ. chute d'eau | លំហូរទឹកនៃផ្លូវទឹកណាមួយពីទីខ្ពស់ ធ្លាក់ទៅលើបំណាក់នៃចំណោតរបស់វា។<br>ឧ. - ទឹកធ្លាក់ប៊ូស្រានៅខេត្តមណ្ឌលគិរី<br>- ទឹកធ្លាក់ខ្ពស់ជាងគេរបស់ពិភពលោកឈ្មោះ សាល់តូអង់ហ្គែល(Salto Angel) នៅប្រទេសវេណេស៊ុយអេឡា មានកម្ពស់ ៩៧៩ ម៉ែត្រ ។ |
| **៤៣- ល្បាក់ទឹក**<br>អ. cataract<br>បារ. cataracte (f.) | ប្រភេទទឹកធ្លាក់ដែលមានមុខទឹកធំ។<br>ឧ. ល្បាក់ទឹកខោននៃទន្លេមេគង្គត្រង់ព្រំប្រទល់កម្ពុជា-ឡាវ។ |
| **៤៤- ទឹកជ្រោះ**<br>អ. rapid<br>បារ. rapide (m.) | កំណាត់របស់ផ្លូវទឹកដែលលំហូររបស់វាមានល្បឿនកើនឡើងដោយសារចំណោតគំហុកនៃពោះរបស់ផ្លូវទឹក ដោយសារថ្មឬអន្លង់ជ្រៅៗដែលធ្វើឱ្យលំហូរទឹកបែកខ្ញែក។<br>ឧ. ទឹកជ្រោះកាំពីខេត្តក្រចេះ ទឹកឈូខេត្តកំពត។ |
| **៤៥- ជំនោរ**<br>អ.high tide<br>បារ.marée haute | នីវ៉ូសមុទ្រខ្ពស់ដែលបណ្ដាលមកពីចលនាទឹកសមុទ្រមកលើផ្ទាំងទ្វីបដោយសារកម្លាំងផ្គុំគ្នានៃទំនាញរបស់ព្រះចន្ទ ព្រះអាទិត្យ និង ផែនដី។ ជំនោរមាន២ដងក្នុង១ថ្ងៃ។ |
| **៤៦- លំនាច**<br>អ.low tide<br>បារ.marée basse | នីវ៉ូសមុទ្រទាបដែលបណ្ដាលមកពីចលនាទឹកសមុទ្រថយពីផ្ទាំងទ្វីបដោយសារកម្លាំងផ្គុំគ្នានៃទំនាញរបស់ព្រះចន្ទ ព្រះអាទិត្យ និង ផែនដី។ លំនាចមាន២ដងក្នុង១ថ្ងៃ។ |
| **៤៧- ដៃ**<br>អ.tributary<br>បារ.affluent(m.) | ផ្លូវទឹកតូចដែលជាប់ទៅនឹងផ្លូវទឹកធំមួយ (ដៃទន្លេ ដៃស្ទឹង ដៃសមុទ្រ...)។ |
| **៤៨- ទឹកជំនន់ / ជំនន់**<br>អ. flood<br>បារ. crue (f.) | បាតុភូតដែលកើតឡើងនៅរដូវទឹកឡើងឬរដូវជំនឡើង ដោយទឹកឡើងហួសពីកម្រិតកំណត់នៅកន្លែងនីមួយៗនៃផ្លូវទឹក។ |
| **៤៩- ពោះផ្លូវទឹក**<br>អ. riverbed<br>បារ. lit (m.) | ផ្ទៃដីដែលគ្របដណ្ដប់ដោយទឹកនៃផ្លូវទឹកណាមួយ។ |
| **៥០- ប្រធានសក្តិ**<br>អ. force majeure<br>បារ. force majeure | បាតុភូតធម្មជាតិឬព្រឹត្តិការណ៍សង្គម ដែលកើតឡើងដោយមិនបានរំពឹងទុកជាមុន មិនអាចប៉ាន់ស្មាននូវទំហំឬកម្រិត និង មិនអាចជម្នះបាន ដូចជា ខ្យល់ព្យុះ ទឹកជំនន់ រញ្ជួយដី កុបកម្ម សង្គ្រាម...។ |
| **៥១- គ្រោះមហន្តរាយ**<br>អ. disaster<br>បារ. catastrophe(f) | ការខូចខាតដ៏ធំធេង(ទ្រព្យសម្បត្តិ ជីវិតមនុស្ស សត្វ...) ដែលបង្កឡើងដោយធម្មជាតិឬដោយមនុស្ស។ |

| | |
|---|---|
| **៥២- គ្រោះមហន្តរាយធម្មជាតិ**<br>អ. natural disaster<br>បារ. catastrophe naturelle | ការខូចខាតដ៏ធំធេង(ទ្រព្យសម្បត្តិ ជីវិតមនុស្ស សត្វ...) ដែលបង្កឡើងដោយធម្មជាតិ ដូចជា ការរញ្ជួយដី បន្ទុះភ្នំភ្លើង ទឹកជំនន់ ការរអិលដី រលកស៊ូណាមី ។ល។ |
| **៥៣- គ្រោះទឹកជំនន់**<br>អ. flooding/inundation disaster<br>បារ. inondation (f.) | ការខូចខាតដោយសារកម្ពស់ទឹកឡើងលើសពីកម្រិតប្រកាសអាសន្ន បណ្ដាលមកពីកត្តាធម្មជាតិឬកត្តាមនុស្ស នៅតាមតំបន់ឬនៅតាមបណ្ដាញផ្លូវទឹកណាមួយ ដែលបណ្ដាលឱ្យមានមហន្តរាយ ដូចជា ជន់លិចផ្ទះសម្បែង ផលដំណាំ ហេដ្ឋារចនាសម្ព័ន្ធ ជីវិតមនុស្ស សត្វ ជាដើម។ |
| **៥៤- គ្រោះរាំងស្ងួត**<br>អ. drought disaster | ការខូចខាតផលដំណាំបណ្ដាលមកពីកង្វះកំណកអាកាស កង្វះសំណើមក្នុងដីជាពិសេស កង្វះទឹកភ្លៀងរយៈពេលយូរនៃតំបន់ណាមួយ។ |
| **៥៥- ស៊ូណាមី**<br>អ.tsunami (កម្ចីពីជប៉ុន)<br>បារ. tsunami (f.) | មហារលកសមុទ្រនៅតំបន់ឆ្នេរ ដែលកើតឡើងដោយសារការរញ្ជួយដីបំណាក់ស្រុត បន្ទុះភ្នំភ្លើងនៅក្រោមបាតសមុទ្រ ឬ ដោយសារការបាក់រអិលដីតំបន់ឆ្នេរ បណ្ដាលឱ្យមានមហន្តរាយយ៉ាងធ្ងន់ធ្ងរនៅតំបន់ឆ្នេរ។ |
| **៥៦- បន្ទុះភ្នំភ្លើង**<br>អ. volcanic eruption<br>បារ.éruption volcanique | ការផ្ទុះចេញឧស្ម័ន ផេះ ផ្សែង និង កម្អែភ្នំភ្លើង ទៅក្នុងអាកាស ទៅលើដីបាតសមុទ្រ ដោយសារកម្លាំងក្នុងជម្រៅផែនដីដែលទម្លុះស្រទាប់ដី បាតសមុទ្រ...។ ឧ. ឆ្នាំ១៩០២ បន្ទុះភ្នំភ្លើងប៉េឡេបានបំផ្លាញក្រុងសាំងព្យែ(Saint-Pierre) ទាំងមូលនៃកោះម៉ាទីនិកដែលស្ថិតនៅប្រជុំកោះអង់ទី(មហាសមុទ្រអាត្លង់ទិក) ដោយសារផេះនិងផ្សែង។ |
| **៥៧- ខ្យល់កន្ត្រាក់**<br>អ. gust<br>បារ. rafale (f.) | សម្ទុះខ្យល់ដែលមានកម្លាំងខ្លាំងនិងមានល្បឿនលឿន បក់កញ្ឆក់ភ្លាមៗតែក្នុងរយៈពេលខ្លី។ |
| **៥៨- ខ្យល់ព្យុះ/ព្យុះ**<br>អ. storm<br>បារ. orage (m.) | ខ្យល់បក់ដែលមានកម្លាំងខ្លាំងនិងល្បឿនលឿន ជាធម្មតា មានភ្លៀង ផ្គរ បន្ទោរ ផ្គរ និង រន្ទះជាមួយផង។ |
| **៥៩- ខ្យល់កួច**<br>អ. whirlwind<br>បារ. tourbillon (m.) | ខ្យល់បក់វិលខ្លាំងនៅមួយកន្លែងឬចល័ត មានរាងដូចសសរឈរឬសាជីផ្ងារ ដែលកើតមាននៅលើផ្ទៃដីឬក្នុងសមុទ្រ។ |
| **៦០- ព្យុះត្រូពិក/ព្យុះស៊ីក្លូន/ព្យុះកំបុតត្បូង**<br>អ. cyclone<br>បារ. cyclone (f.) | ព្យុះតាមរដូវនៅតំបន់ត្រូពិក បណ្ដាលមកពីមណ្ឌលសម្ពាធខ្សោយ។ នៅតំបន់អាស៊ី គេហៅថាព្យុះនេះថា ព្យុះទីហ្វុង ហើយ នៅទ្វីបអាម៉េរិក គេហៅថា ព្យុះហ៊ើរីខេន(hurricane)។ |
| **៦១- ព្យុះព្រិល**<br>អ. snowstorm<br>បារ. tempête (f.) de neige | ខ្យល់បក់បោកខ្លាំងក្នុងពេលធ្លាក់ព្រិលច្រើន។ |

| | |
|---|---|
| **៦២- ភ្លៀងទឹកកក**<br>អ. hail<br>បារ. grêle ( f. ) | ប្រភេទភ្លៀងជាដុំទឹកកក ដែលមានអង្កត់ផ្ចិតលើសពី៥មិល្លីម៉ែត្រ។ |
| **៦៣- រន្ទះ**<br>អ. lightning<br>បារ. foudre ( f. ) | បាតុភូតធម្មជាតិដែលមានពន្លឺនិងសំឡេងខ្លាំងព្រមគ្នា ភាគច្រើនកើតឡើងនៅពេលមានភ្លៀង។ |
| **៦៤- រលកយក្ស**<br>អ. giant waves/<br>rogue waves | រលកធំៗដែលកើតលើផ្ទៃមហាសមុទ្រ បណ្ដាលមកពីព្យុះ ហើយ អាចបង្កឱ្យមានគ្រោះមហន្តរាយនៅលើផ្ទៃសមុទ្រនិងតំបន់ឆ្នេរ។ |
| **៦៥- រំកិលដី**<br>អ. landslide<br>បារ. glissement de<br>terrain | ចលនាបាក់ធ្លាក់ឬរអិលចុះក្រោមនៃផ្ទាំងដីឬសិលាជាទ្រង់ទ្រាយធំ កើតឡើងនៅទីកន្លែងដែលស្រទាប់ដីឬសិលាខាងលើលែងខាំជាប់ជាមួយផ្នែករឹងនៅខាងក្រោម ដោយសារមានបន្ទុះភ្នំភ្លើង រញ្ជួយដី ឬ ភ្លៀងខ្លាំង ជាដើម។ |
| **៦៦- ការរញ្ជួយដី**<br>អ. earthquake<br>បារ. séisme ( m. )/<br>tremblement de terre | លំញ័រនៃសំបកផែនដីរយៈពេលខ្លីជួនកាលច្រើនដងបណ្ដាលមកពីកម្លាំងខាងក្នុងនៃជម្រៅផែនដីឬបន្ទុះភ្នំភ្លើង។ |
| **៦៧- ជនជាតិ/ជាតិពន្ធុ**<br>អ. ethnic group<br>បារ. ethnie( f. ) | សង្គមមនុស្សមួយក្រុមដែលមានលក្ខណៈសម្គាល់សំខាន់ៗរួមគ្នា ដូចជា ជាតិសាសន៍ វប្បធម៌ ភាសា ប្រពៃណី ទំនៀមទម្លាប់ ជំនឿ ...។ |
| **៦៨- ជនជាតិដើម**<br>អ. indigenous people<br>បារ. indigène, autochtone | ជាតិពន្ធុដែលរស់នៅដំបូងគេនៅលើទឹកដីណាមួយ( ប្រទេស តំបន់ ទ្វីប )។ |
| **៦៩- ជនជាតិភាគតិច**<br>អ. ethnic minority<br>បារ. minorité ethnique | ជនជាតិដែលមានចំនួនតិចក្នុងចំណោមប្រជាជនទាំងអស់លើទឹកដីណាមួយ។ |
| **៧០- កុលសម្ព័ន្ធ**<br>អ. tribe<br>បារ. tribu ( f. ) | ក្រុមមនុស្សដែលមានចំណងសម្ព័ន្ធវង្សត្រកូលជាមួយគ្នា រស់នៅរួមគ្នាក្នុងតំបន់ភូមិសាស្ត្រណាមួយ មានជំនឿសាសនា ភាសានិងប្រវត្តិរួមគ្នា និង ដឹកនាំដោយមនុស្សម្នាក់ហៅថាមេកុលសម្ព័ន្ធ( មេកន្ទ្រាញ )។<br>ជាទូទៅពួកគេរស់នៅក្នុងតំបន់ក្រៅពីទីប្រជុំជនឬទីក្រុង។ |
| **៧១- ពូជ**<br>អ. race<br>បារ. race ( f. ) | តំណជាតិកំណើតឬវង្សត្រកូលរបស់ពួកមនុស្ស ដោយសំអាងទៅលើលក្ខណៈរួមមួយចំនួន ដូចជាលក្ខណៈរូប (សម្បុរស្បែក ទម្រង់លលាដ៍ក្បាល...) លក្ខណៈសរីរសាស្ត្រ ជាដើម។<br>ឧ.នៅលើលោក គេបានចែកពូជមនុស្សជា៣ក្រុមធំៗគឺ ពូជស្បែកស ពូជស្បែកខ្មៅ និង ពូជស្បែកលឿង។ |

| | |
|---|---|
| **៧២- ប្រជាជន**<br>អ. population<br>បារ. population (f.) | មនុស្សទាំងអស់ដែលរស់នៅក្នុងប្រទេសមួយឬក្នុងកន្លែងណាមួយនៃប្រទេសនោះ។ ក្នុងន័យទូលាយ គេអាចប្រើពាក្យប្រជាជនសម្គាល់មនុស្សម្នាក់ៗក្នុងប្រទេស ឬក្រុមមនុស្សក្នុងតំបន់ណាមួយ ឬក៏ក្រុមមនុស្សនៃពិភពលោកទាំងមូល។<br>ឧ. តាមជំរឿនឆ្នាំ២០០៨ ព្រះរាជាណាចក្រកម្ពុជាមានប្រជាជន ១៣ ៣៩៥ ៦៨២ នាក់។ |
| **៧៣- ពលរដ្ឋ**<br>អ. citizen<br>បារ. citoyen, -ne | ជនទាំងឡាយណាដែលមានសញ្ជាតិរបស់រដ្ឋដែលខ្លួនកំពុងរស់នៅ។<br>ឧ.ពលរដ្ឋខ្មែរដែលមានអាយុចាប់ពី១៥ឆ្នាំឡើង ត្រូវមានអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ។ ប្រជាពលរដ្ឋខ្មែរទាំងពីរភេទដែលមានអាយុយ៉ាងតិច១៨ឆ្នាំមានសិទ្ធិបោះឆ្នោត។ ជនណាមានសញ្ជាតិខ្មែរ ជាពលរដ្ឋខ្មែរ។ |
| **៧៤- អ្នករស់នៅ**<br>អ. inhabitant<br>បារ. habitant, e | ជនដែលរស់នៅកន្លែងណាមួយ ដូចជានៅក្នុងភូមិ ឃុំ ស្រុក ជាដើម។ |
| **៧៥- សង្គមស៊ីវិល**<br>អ. civil society<br>បារ. société civile | ក្រុមមនុស្សដែលធ្វើសកម្មភាពការពារផលប្រយោជន៍លើវិស័យសេដ្ឋកិច្ចនយោបាយ វិទ្យាសាស្រ្ត វប្បធម៌ សាសនា មានជាអាទិ៍ សមាគម សហគមន៍ អង្គការមិនមែនរដ្ឋាភិបាល គណបក្សនយោបាយ។ |
| **៧៦- សមាគម**<br>អ. association<br>បារ. association (f.) | សង្គមស៊ីវិលមួយប្រភេទដែលជាអង្គការសមាជិកភាព ត្រូវបានបង្កើតឡើងក្នុងគោលបំណងអភិវឌ្ឍនិងការពារផលប្រយោជន៍របស់សមាជិកឬ/និងផលប្រយោជន៍រួម និង មិនស្វែងរកប្រាក់ចំណេញ។<br>ឧ. សមាគមសិល្បករ សមាគមជនពិការ...។ |
| **៧៧- សមាគមក្នុងស្រុក**<br>អ. local association<br>បារ. association locale | សមាគមមួយប្រភេទដែលបង្កើតឡើងដោយក្រុមប្រជាពលរដ្ឋនៅក្នុងប្រទេសមួយ ក្នុងគោលបំណងអភិវឌ្ឍនិងការពារផលប្រយោជន៍របស់សមាជិកឬ/និងផលប្រយោជន៍រួម និង មិនស្វែងរកប្រាក់ចំណេញ។ |
| **៧៨- សមាគមបរទេស**<br>អ. foreign association<br>បារ. association étrangère | សមាគមមួយប្រភេទដែលបង្កើតឡើងនៅក្រៅប្រទេស ហើយ ចូលមកធ្វើសកម្មភាពដោយស្របច្បាប់នៅក្នុងប្រទេសផ្សេង ដើម្បីរួមចំណែកអភិវឌ្ឍនិងការពារផលប្រយោជន៍តាមគោលបំណងរបស់សមាគមខ្លួន និង មិនស្វែងរកប្រាក់ចំណេញ។ |
| **៧៩- អង្គការមិនមែនរដ្ឋាភិបាល**<br>អ. non-governmental organization (NGO)<br>បារ. organisation non-gouvernementale (ONG) | សង្គមស៊ីវិលមួយប្រភេទដែលជាអង្គការមិនមែនសមាជិកភាព បង្កើតឡើងដើម្បីធ្វើសកម្មភាពដោយស្មគ្រចិត្ត ក្នុងគោលបំណងរួមចំណែកអភិវឌ្ឍផ្នែកសេដ្ឋកិច្ច-សង្គម។ អង្គការមិនមែនរដ្ឋាភិបាលមានអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកនិងអង្គការមិនមែនរដ្ឋាភិបាលបរទេស។ |

| | |
|---|---|
| **៨០- សហគមន៍**<br>អ. community<br>បារ. communauté (f.) | ក្រុមមនុស្សដែលរស់នៅកន្លែងណាមួយក្នុងប្រទេស ហើយ មានផលប្រយោជន៍រួមគ្នាលើផ្នែកសេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌... ដូចជា សហគមន៍ព្រៃឈើ សហគមន៍នេសាទ សហគមន៍កសិកម្ម ជាដើម។ ពាក្យ សហគមន៍ក៏អាចប្រើក្នុងន័យទូលាយដើម្បីសម្គាល់ក្រុមប្រទេសក្នុងតំបន់ណាមួយនៃពិភពលោក មានសហគមន៍អាស៊ាន សហគមន៍អឺរ៉ុប ...។ |
| **៨១- សហជីព**<br>អ. union, syndicate<br>បារ. syndicat (m.) | អង្គការវិជ្ជាជីវៈរបស់កម្មករឬនិយោជិត ដើម្បីការពារសិទ្ធិនិងអត្ថប្រយោជន៍សមាជិកខ្លួន។ |
| **៨២- សមូហភាព**<br>អ. collectivity<br>បារ. collectivité (f.) | ក្រុមឬសម្ព័ន្ធមនុស្សដែលមានទំនាក់ទំនងរវាងគ្នានឹងគ្នាជារចនាសម្ព័ន្ធ។ |
| **៨៣- សហករណ៍**<br>អ. cooperative<br>បារ. coopérative(f.) | ក្រុមមនុស្សដែលបង្កើតឡើងដើម្បីអភិវឌ្ឍនិងការពារផលប្រយោជន៍របស់ខ្លួន ដូចជា ផលប្រយោជន៍ក្នុងផ្នែកផលិតកម្ម កសិកម្ម ការប្រើប្រាស់គ្រឿងឧបភោគបរិភោគ ជាដើម។<br>ឧ. សហករណ៍កសិកម្ម សហករណ៍សិប្បកម្ម ...។ |
| **៨៤- ក្លឹប**<br>អ. club<br>បារ. club (m.) | ក្រុមមនុស្សដែលមានចំណូលចិត្តឬផលប្រយោជន៍ដូចគ្នា ចូលរួមធ្វើសកម្មភាពជាមួយគ្នានៅកន្លែងណាមួយ។<br>ឧ. ក្លឹបកីឡា ក្លឹបសិក្សា ក្លឹបយុវជន ក្លឹបអ្នកកាសែត ជាដើម។ |
| **៨៥- គណបក្សនយោបាយ**<br>អ. political party<br>បារ. partie politique | ក្រុមមនុស្សដែលមានទស្សនៈនយោបាយដូចគ្នា ហើយ ប្រតិបត្តិសកម្មភាពរួមមួយ ដើម្បីឈានទៅគ្រប់គ្រងអំណាចនិងអនុវត្តគោលនយោបាយរបស់ខ្លួន។ |
| **៨៦- ភាពនៅលីវ**<br>អ. celibacy<br>បារ. célibat (m.) | ស្ថានភាពនៃជនដែលមានវ័យគ្រប់ការ តែមិនទាន់មានប្តីឬប្រពន្ធ។ |
| **៨៧-អាយុមានកូន**<br>អ. childbearing ages<br>(reproductive ages)<br>បារ. âges de procréation | ចន្លោះអាយុស្ត្រីដែលអាចផ្តល់កំណើតកូនបាន ជាទូទៅ ចាប់គិតពីអាយុ១៥ឆ្នាំដល់៤៩ឆ្នាំ (ប្រទេសខ្លះគិតត្រឹម៤៤ឆ្នាំ)។<br>ឧ. យោងតាមជំរឿនទូទៅនូវប្រជារាស្ត្ររបស់ប្រទេសកម្ពុជាឆ្នាំ២០០៨ ស្ត្រីដែលស្ថិតក្នុងអាយុមានកូន មានចំនួន ៣ ៦៥៥ ០៥១នាក់ (៥៣,១%នៃចំនួនស្ត្រីសរុប)។ |
| **៨៨- ភាពបង្កកំណើត / លទ្ធភាពមានកូន**<br>អ. fertility<br>បារ. fécondité (f.) | សម្បទាដែលស្ត្រីម្នាក់អាចផ្តល់កំណើតកូនបានក្នុងមួយជីវិតរបស់គាត់។ |

| | |
|---|---|
| **៨៩- អត្រាភាពបង្កកំណើតទូទៅ / អត្រាលទ្ធភាពមានកូនទូទៅ**<br>អ. general fertility rate (GFR)<br>បារ. taux de fécondité générale | ចំនួនកំណើតរស់ក្នុងមួយឆ្នាំចែកនឹងចំនួនស្ត្រីសរុបដែលស្ថិតក្នុងអាយុមានកូនក្នុងឆ្នាំនោះ។ ជាទូទៅ អត្រានេះគិតជាភាគពាន់។ |
| **៩០- អត្រាកើតដុល**<br>អ. crude birth rate (CBR)<br>បារ.taux brut de natalité | ចំនួនកំណើតរស់សរុបក្នុងឆ្នាំណាមួយ ធៀបនឹងចំនួនប្រជាជនសរុបប្រចាំឆ្នាំនោះ។ ជាទូទៅ អត្រានេះគិតជាភាគពាន់។<br>ឧ. ក្នុងឆ្នាំ២០១១ មានទារកកើតរស់ ៣ ៣៥៦នាក់ ក្នុងទីក្រុងមួយ ដែលមានប្រជាជនសរុប ២៣៣ ០០០នាក់។ ដូច្នេះ អត្រាកើតដុលមាន ១៤,៤‰។ |
| **៩១- អត្រាស្លាប់ដុល**<br>អ. crude death rate (CDR)<br>បារ. taux brut de mortalité | ចំនួនអ្នកស្លាប់សរុបក្នុងឆ្នាំណាមួយ ធៀបនឹងចំនួនប្រជាជនសរុបប្រចាំឆ្នាំនោះ។ ជាទូទៅ អត្រានេះគិតជាភាគពាន់។<br>ឧ. ក្រុង ក មានអ្នកស្លាប់សរុបចំនួន ១ ៣៩០នាក់ ក្នុងឆ្នាំ២០១១ ក្នុងចំណោមប្រជាជនសរុប ៣២៣ ០០០នាក់។ ដូច្នេះ អត្រាស្លាប់ដុលមាន ៤,៣‰។ |
| **៩២- ផលធៀបភេទ**<br>អ. sex ratio<br>បារ. masculinité | ចំនួនបុរសធៀបនឹងចំនួនស្ត្រីនៅកន្លែងណាមួយ។ គេប្រើផលធៀបភេទដើម្បីវាយតម្លៃអំពីអតុល្យភាពភេទទូទៅឬតាមក្រុមអាយុ។ ជាទូទៅ ផលធៀបនេះ គិតធៀបនឹងចំនួនស្ត្រី១០០នាក់។<br>ឧ. ភូមិ **ក** មានបុរស២១០នាក់និងស្ត្រី២៣០នាក់។ ផលធៀបភេទគឺ៩១ [(២១០ : ២៣០) X ១០០]។ នេះមានន័យថា បុរសចំនួន៩១នាក់ ទល់នឹងស្ត្រី១០០នាក់។ |
| **៩៣- ផលធៀបអ្នកក្នុងបន្ទុកតាមអាយុ**<br>អ. age dependency ratio / dependency ratio by age | ចំនួនក្មេងអាយុ ០–១៤ឆ្នាំបូកចំនួនមនុស្សចាស់អាយុ៦៥ឆ្នាំឡើង ធៀបនឹងប្រជាជនក្នុងក្រុមអាយុ ១៥–៦៤ឆ្នាំ។ ផលធៀបនេះ គេគិតជាភាគរយ។ គេអាចហៅផលធៀបនេះថា អត្រាអ្នកក្នុងបន្ទុក(dependency ratio) ក៏បាន។ |
| **៩៤- មរណប្រមាណ**<br>អ. mortality<br>បារ.mortalité | ចំនួនមនុស្សស្លាប់ក្នុងចំណោមប្រជាជនសរុប នៅកន្លែងណាមួយនិងពេលវេលាកំណត់ណាមួយ។ |
| **៩៥-ជាតិប្រមាណ**<br>អ. natality<br>បារ. natalité | ចំនួនកំណើតរស់ក្នុងចំណោមប្រជាជនសរុប នៅកន្លែងណាមួយ និង ពេលវេលាកំណត់ណាមួយ។ |

| | |
|---|---|
| **៩៦- កំណើនធម្មជាតិ**<br>អ. natural increase<br>បារ. accroissement naturel | ចំនួនអ្នកកើតលើសចំនួនអ្នកស្លាប់។ |
| **៩៧- តំហយធម្មជាតិ**<br>អ. natural decrease | ចំនួនអ្នកស្លាប់លើសចំនួនអ្នកកើត។ |
| **៩៨- ប្រជាសាស្ត្រ**<br>អ. demography<br>បារ. démographie | ការសិក្សាអំពីប្រជាជនតាមបែបស្ថិតិវិទ្យា។ |
| **៩៩- ជំនាន់កំណើត**<br>អ. birth cohort | ក្រុមមនុស្សដែលកើតក្នុងឆ្នាំឬក្នុងព្រឹត្តិការណ៍ណាមួយជាមួយគ្នា។ |
| **១០០- អាយុមធ្យម**<br>អ. mean age<br>បារ. âge moyen | មធ្យមភាគនៃអាយុរបស់សមាជិកទាំងអស់នៃប្រជាជនមួយក្រុម។<br>ឧ. សិស្សមួយក្រុមមានគ្នា៨នាក់ ដែលមានលំដាប់អាយុ ៩, ១១, ១២, ១២, ១៣, ១៤, ១៥ និង ១៨ឆ្នាំ។ ដូច្នេះ អាយុមធ្យមរបស់សិស្សក្រុមនេះ គឺ ១៣ ឆ្នាំ(១០៤ចែកនឹង៨)។ |
| **១០១- អាយុគំរូ**<br>អ. mode age<br>បារ. mode d'âge | អាយុរបស់អ្នកដែលមានចំនួនច្រើនជាងគេក្នុងចំណោមប្រជាជនមួយក្រុម។<br>ឧ. សិស្សមួយក្រុមមានគ្នា៨នាក់ ដែលមានលំដាប់អាយុ ៩, ១១, ១២,១២, ១៣, ១៤, ១៥ និង ១៨ឆ្នាំ។ សមាជិកដែលមានអាយុ១២ឆ្នាំមានចំនួន២នាក់ ដែលជាចំនួនច្រើនជាងគេ ដូច្នេះ អាយុគំរូរបស់សិស្សក្រុមនោះគឺ ១២ឆ្នាំ។ |
| **១០២- អាយុមេដ្យា**<br>អ. median age<br>បារ. âge médiane | អាយុដែលចែករបាយអាយុប្រជាជនជាពីរក្រុមស្មើគ្នា។ |
| **១០៣- ពីរ៉ាមីតអាយុ**<br>អ. age pyramid<br>បារ. pyramide des âges | គំនូសតាងដែលបង្ហាញពីចំនួនឬសមាមាត្រប្រជាជនតាមក្រុមអាយុនិងតាមភេទ។ |
| **១០៤- អាយុសង្ឃឹមរស់ /សង្ឃឹមរស់**<br>អ. life expectancy<br>បារ. espérance de vie | រយៈពេលមធ្យម (គិតជាឆ្នាំ) នៃជីវិតរបស់មនុស្សនៅក្នុងតំបន់ ប្រទេស ឬក្រុមប្រជាជនណាមួយ។ ជាទូទៅ ស្ត្រីមានអាយុសង្ឃឹមរស់ខ្ពស់ជាងបុរស។ |
| **១០៥-ម៉ាល់ទុសនិយម**<br>អ. malthusianism<br>បារ. malthusianisme (m.) | ទ្រឹស្តីរបស់លោក ម៉ាល់ទុស (Thomas R. Malthus គ.ស. ១៧៦៦-១៨៣៤) សេដ្ឋវិទូនិងប្រជាវិទូអង់គ្លេស ដែលបានលើកឡើងថា ចំនួនប្រជាជនមានទំនោរកើនឡើងតាមកំណើនធរណីមាត្រ ដែលបណ្តាលឱ្យការផ្គត់ផ្គង់គ្រឿងឧបភោគបរិភោគមិនគ្រប់គ្រាន់សម្រាប់ទ្រទ្រង់ជីវិត លើកលែងតែមានមហន្តរាយណាមួយកើតឡើង(សង្គ្រាម គ្រោះទុរភិក្ស ជំងឺ ...) ដែលធ្វើឱ្យចំនួនប្រជាជនថយចុះ ឬ ដោយការរឹតត្បិតការរួមភេទដើម្បីទប់ស្កាត់កំណើនប្រជាជន។ |

| | |
|---|---|
| **១០៦- ប្រជាជនចាស់**<br>អ. old population<br>បារ. population vieille | ប្រជាជននៃតំបន់ឬប្រទេសណាមួយដែលមនុស្សពេញវ័យនិងវ័យចាស់មានសមាមាត្រខ្ពស់ក្នុងចំណោមប្រជាជនសរុប។<br>ឧ. ឆ្នាំ២០១០ ប្រទេសជប៉ុនមានទម្រង់ពីរ៉ាមីតជាប្រជាជនចាស់ ហើយ មានអាយុមេដ្យាន ៤៤,៦ឆ្នាំ។ |
| **១០៧- ប្រជាជនក្មេង**<br>អ. young population<br>បារ. population jeune | ប្រជាជននៃតំបន់ឬប្រទេសណាមួយដែលមនុស្សវ័យកុមារ វ័យជំទង់ និង ទើបពេញវ័យមានសមាមាត្រខ្ពស់ក្នុងចំណោមប្រជាជនសរុប។<br>ឧ. ជំរឿនឆ្នាំ១៩៩៨បង្ហាញថា កម្ពុជាមានទម្រង់ពីរ៉ាមីតជាប្រជាជនក្មេង ហើយមានអាយុមេដ្យាន ២២ឆ្នាំ។ |
| **១០៨- ប្រជាជនលើសបន្ទុក**<br>អ. overpopulation<br>បារ. surpopulation( f. ) | ស្ថានភាពនៃប្រជាជននៅកន្លែងណាមួយ (តំបន់ ប្រទេស) ដែលមានចំនួនច្រើនលើសពីលទ្ធភាពសេដ្ឋកិច្ច។ |
| **១០៩- គ្រួសារ**<br>អ. family<br>បារ.famille ( f. ) | ក្រុមមនុស្សដែលមានចំណងទាក់ទងនឹងគ្នា ដោយសារកំណើត អាពាហ៍-ពិពាហ៍ ការទទួលចិញ្ចឹម ហើយ រស់នៅជាមួយគ្នាដូចជា ឪពុក ម្តាយ កូន...។ |
| **១១០- គេហព័ន្ធ**<br>អ. household<br>បារ. ménage ( m. ) | មនុស្សទាំងអស់ដែលរស់នៅក្នុងឯកតាលំនៅឋានមួយ (ផ្ទះ បន្ទប់ ទូក ផ្ទះទឹក ...)។ គេហព័ន្ធមួយអាចមានមនុស្សជាសាច់ញាតិឬមនុស្សមិនមែនជាសាច់ញាតិនឹងគ្នា។ |
| **១១១- ទំហំគ្រួសារ**<br>អ. household size<br>បារ. | ចំនួនមនុស្សជាមធ្យមនៅក្នុងគ្រួសារមួយ ដែលជាលទ្ធផលនៃចំនួនមនុស្សសរុបនៅក្នុងកន្លែងណាមួយ( ភូមិ ឃុំ ស្រុក តំបន់ ...) ចែកនឹងចំនួនគ្រួសារសរុបនៅក្នុងកន្លែងនោះ។ |
| **១១២- មេគ្រួសារ**<br>អ. head of household<br>បារ. chef de famille | អ្នកដែលទទួលខុសត្រូវក្នុងគ្រួសារមួយ។ |
| **១១៣- ប្រជាសាស្ត្រគ្រួសារ**<br>អ. family demography<br>បារ. démographie familiale ( f. ) | ការសិក្សានិងការវិភាគលើគេហព័ន្ធគ្រួសារ ដូចជា កំណើតគ្រួសារ ការផ្លាស់ប្តូរស្ថានភាពគ្រួសារ( ការកើនចំនួនឬការបាត់បង់សមាជិក ...) ជាដើម។ |
| **១១៤- ស្ថានភាពអាពាហ៍ពិពាហ៍**<br>អ. marital status<br>បារ. statut matrimonial | សភាពរបស់មនុស្សម្នាក់ៗក្នុងទំនាក់ទំនងខាងអាពាហ៍ពិពាហ៍ ដូចជា មិនទាន់រៀបការ រៀបការ រស់នៅបែកគ្នាក្រោយរៀបការ លែងលះ និង មេម៉ាយឬពោះម៉ាយ( ដោយមូលហេតុផ្សេងៗ )។ |
| **១១៥- ជនបម្លាស់ទី**<br>អ. displaced person<br>បារ. personne déplacée ( f. ) | ជនដែលប្តូរទីកន្លែងរស់នៅដោយកត្តាផ្សេងៗ។ |

| | |
|---|---|
| **១១៦-ជំរឿន**<br>អ.census<br>បារ.recensement(m.) | ការប្រមូលស្ថិតិពីបុគ្គល គ្រួសារ សហគ្រាស ឬ អង្គភាពចាត់តាំងផ្សេងទៀត ដែលអង្គភាពទាំងអស់ត្រូវបានធ្វើសម្ភាសន៍។ ជំរឿនមានជំរឿនប្រជាជន ជំរឿនកសិកម្ម ជំរឿនសេដ្ឋកិច្ច ...។ |
| **១១៧- ជំរឿនប្រជាជន**<br>អ. population census<br>បារ.recensement(m.) de la population | ការប្រមូលទិន្នន័យពីប្រជាជនទាំងអស់ ដែលរួមមានទិន្នន័យផ្សេងៗដូចជា អាយុ ភេទ មុខរបរ ស្ថានភាពអាពាហ៍ពិពាហ៍ ការសិក្សា ស្ថានភាពសេដ្ឋកិច្ច សង្គម ...។ |
| **១១៨- អង្កេត**<br>អ.survey<br>បារ.enquête(f.) | ការប្រមូលទិន្នន័យតាមសំណាកគំរូពីបុគ្គល គ្រួសារ សហគ្រាស ឬ អង្គភាពចាត់តាំងផ្សេងៗ។ |
| **១១៩- គំរូតាង/សំណាកគំរូ**<br>អ.sample<br>បារ.échantillon (m.) | សំណុំបុគ្គល សហគ្រាស អង្គភាព... ដែលត្រូវបានជ្រើសរើសជាតំណាងឱ្យគោលដៅដែលយើងបានកំណត់ដើម្បីឱ្យអ្នកធ្វើអង្កេតឬអ្នកសិក្សាស្រាវជ្រាវប្រមូលទិន្នន័យ។ |
| **១២០- អង្កេតចន្លោះជំរឿន**<br>អ.inter-census survey<br>បារ. enquête de l'interrecensement | ការប្រមូលទិន្នន័យក្នុងចន្លោះពេលពីជំរឿនមួយទៅជំរឿនមួយទៀត តាមការជ្រើសរើសគំរូតាង។ |
| **១២១- លក្ខណៈសម្គាល់ប្រជាជន**<br>អ. population characteristics<br>បារ.caractéristiques de la population | ចំណុចពិសេសផ្សេងៗរបស់ប្រជាជនមានអាយុ ភេទ ពូជ ជាតិពន្ធុ ស្ថានភាពអាពាហ៍ពិពាហ៍ មុខរបរ ការអប់រំ និង ប្រាក់ចំណូល ដែលបានមកពីការវិភាគប្រជាសាស្ត្រ។ |
| **១២២- របាយប្រជាជន**<br>អ. population distribution<br>បារ. répartition de la population | ការតាំងទីលំនៅរបស់ប្រជាជនដែលមានលក្ខណៈប្រមូលផ្តុំឬរាយប៉ាយ តាមភូមិសាស្ត្រនានា។ |
| **១២៣- ដង់ស៊ីតេប្រជាជន**<br>អ. density of population<br>បារ.densité de population | ចំនួនប្រជាជនក្នុងផ្ទៃដីមួយគីឡូម៉ែត្រការ៉េ។ |
| **១២៤- ចំណោលប្រជាជន**<br>អ. population projection<br>បារ. projection démographique | ទំហំនិងលក្ខណៈសម្គាល់ប្រជាជន ដែលគណនាសម្រាប់ពេលអនាគត ដោយផ្អែកលើការវិភាគនិន្នាការបច្ចុប្បន្ន ដូចជា កត្តាកើត កត្តាមរណៈ កត្តាបម្លាស់លំនៅ ជាដើម ។ |

| | |
|---|---|
| **១២៥- កំណើនប្រជាជន**<br>អ. population increase<br>បារ. accroissement de la population | ការកើនចំនួនប្រជាជនសរុបដែលជាលទ្ធផលរវាងការកើត ការស្លាប់ និង បម្លាស់លំនៅ ក្នុងភូមិសាស្ត្រជាក់លាក់និងក្នុងរយៈពេលកំណត់ណាមួយ។ |
| **១២៦- គោលនយោបាយប្រជាជន**<br>អ. population policy<br>បារ.politique en matière de population | វិធានការរបស់រដ្ឋ ដើម្បីមានឥទ្ធិពលលើទំហំ កំណើន របាយឬសមាសភាពប្រជាជនក្នុងពេលបច្ចុប្បន្នឬអនាគត។ |
| **១២៧- ស្ថិតិ**<br>អ.statistic(s)<br>បារ.statistique | ទិន្នន័យដែលបានមកដោយការប្រមូល ការរៀបចំ ការចងក្រង ការវិភាគ ការបោះពុម្ព និង ការផ្សព្វផ្សាយលទ្ធផលនៃចម្លើយ តាមការប្រមូលព័ត៌មានឬពីប្រភពទិន្នន័យរដ្ឋបាល។ |
| **១២៨- ភូមិវិទ្យាមនុស្ស**<br>អ. human geography<br>បារ. géographie humaine | ផ្នែកមួយនៃភូមិវិទ្យាដែលសិក្សាអំពី ប្រជាជន សហគមន៍ វប្បធម៌ សេដ្ឋកិច្ច និងអន្តរកម្មរបស់មនុស្សជាមួយនឹងបរិស្ថាន ដោយផ្តោតទៅលើទំនាក់ទំនងរវាងសកម្មភាពមនុស្សក្នុងលំហលើផ្ទៃផែនដី។ |
| **១២៩- ភូមិវិទ្យាប្រជាជន**<br>អ. population geography<br>បារ. géographie de population | ផ្នែកមួយនៃភូមិវិទ្យាមនុស្សដែលសិក្សាអំពីការប្រែប្រួលនៃរបាយ ដង់ស៊ីតេ សមាសភាព លំនៅឋាន ក្រុង បម្លាស់លំនៅ និង កំណើននៃប្រជាជនទៅតាមទីកន្លែងនានា។ |
| **១៣០- ភូមិវិទ្យាក្រុង**<br>អ. urban geography<br>បា. géographie urbaine | ផ្នែកមួយនៃភូមិវិទ្យាមនុស្ស ដែលសិក្សាអំពីប្រវត្តិនិងការវិវត្តនៃទីតាំង រូបរាង មុខងារនិងសកម្មភាពសំខាន់ៗ ទំនាក់ទំនងជាមួយតំបន់ជុំវិញ និង ការចាត់ថ្នាក់របស់ក្រុងនិងទីក្រុង។ |
| **១៣១- នគរូបនីយកម្ម**<br>អ. urban planning/ town planning<br>បារ. urbanisation (f.) | សិល្បៈ វិទ្យាសាស្ត្រ និងបច្ចេកទេសនៃការធ្វើផែនការរូបវន្តទីក្រុង ការអភិវឌ្ឍ ការអភិរក្ស ការគ្រប់គ្រងអភិវឌ្ឍ ការសាងសង់ និង ការកែលម្អនៅក្នុងទីក្រុង និងតំបន់ជុំវិញ ព្រមទាំងតំបន់ទទួលឥទ្ធិពលក្នុងគោលបំណងទទួលបាននូវចីរភាព តុល្យភាព សុខុមាលភាព សោភណភាព សមធម៌ និងសមាហរណកម្ម។ |
| **១៣២-ក្រុង**<br>អ. town<br>បារ. ville(f.) | កន្លែងដែលមានប្រជាជនរស់នៅច្រើន មានផ្សារនិងហាងលក់ទំនិញ កន្លែងធ្វើការ កន្លែងកម្សាន្ត និង មានការរៀបចំហេដ្ឋារចនាសម្ព័ន្ធរូបវន្ត។ល។ ក្រុងតូចជាងទីក្រុង។<br>ឧ.ក្រុងព្រះសីហនុ។ |
| **១៣៣- ទីក្រុង**<br>អ . city<br>បារ. ville(f.) | ក្រុងធំ។<br>ឧ.ទីក្រុងភ្នំពេញ ទីក្រុងបាងកក ទីក្រុងហូជីមិញ។ |

| | |
|---|---|
| **១៣៤- បុរី**<br>អ. city<br>បារ. cité(f.) | ទីតាំងមួយដែលត្រូវបានរៀបចំជាដីឡូត៍ ជាសំណង់លំនៅឋាន ជាសំណង់ផ្សេងៗ លម្ហសាធារណៈ និង ហេដ្ឋារចនាសម្ព័ន្ធនានា នៅលើក្បាលដីតែមួយ ស្របតាមគម្រោងប្លង់សរុបរបស់បុរីដែលបានទទួលការអនុញ្ញាតជាផ្លូវការ។ ក្នុងករណីខ្លះ បុរីក៏សម្គាល់ទីក្រុងដែរ(បុរីវ៉ាទីកង់ បុរីញូវយ៉ក...)។<br>ឧ.បុរីប៉េងហួត បុរីពិភពថ្មី បុរីភ្នំពេញ...។ |
| **១៣៥- រដ្ឋធានី/រាជធានី**<br>អ. capital<br>បារ. capitale(f.) | ទីក្រុងដែលជាទីតាំងរបស់រដ្ឋាភិបាលឬរាជរដ្ឋាភិបាលនៃប្រទេសមួយ។<br>ឧ. រាជធានីភ្នំពេញ រដ្ឋធានីវ៉ាស៊ីនតោន(សហរដ្ឋអាមេរិក) រដ្ឋធានីកង់បេរ៉ា (អូស្ត្រាលី)។ |
| **១៣៦- ទីប្រជុំជន**<br>អ. urban area<br>បារ.agglomération (m.) | កន្លែងដែលមានអគារឬគេហដ្ឋានច្រើននិងមនុស្សរស់នៅច្រើន ដោយមិនគិតអំពីដែនដីរដ្ឋបាល។ |
| **១៣៧- ជនបទ**<br>អ. rural area<br>បារ. zone rurale (f.) | កន្លែងក្រៅពីទីប្រជុំជន មានមនុស្សរស់នៅតិចមានលក្ខណៈជាស្រែចម្ការឬព្រៃ។ |
| **១៣៨- អត្រានុកូលដ្ឋាន**<br>អ. civil status<br>បារ.état-civil | ចំណងរួមភ្ជាប់សញ្ជាតិទៅនឹងរដ្ឋនិងឋានៈនៅក្នុងគ្រួសារ ហើយ ដែលបង្កើតឱ្យមានសិទ្ធិនិងករណីយកិច្ច។ ទិន្នន័យសំខាន់ៗរបស់អត្រានុកូលដ្ឋានមានការកើត ការស្លាប់ ការរៀបការ ជាដើម។ |
| **១៣៩- បញ្ជីអត្រានុកូលដ្ឋាន**<br>អ. register of civil status<br>បារ.registre de l'état civil | ប្រព័ន្ធចុះបញ្ជីសម្រាប់កត់ត្រាទិន្នន័យអត្រានុកូលដ្ឋាន។ |
| **១៤០- កណ្តាលក្រុង**<br>អ. city centre/downtown<br>បារ. centre-ville (m.) | កន្លែងដែលជាទីតាំងកណ្តាលនៃក្រុង ហើយ ដែលមានជាយក្រុងនៅពីក្រៅ។ ជាទូទៅ កណ្តាលក្រុងជាអតីតទីតាំងប្រវត្តិសាស្ត្រឬជាតំបន់អភិវឌ្ឍចាស់។ |
| **១៤១- ជាយក្រុង**<br>អ. suburbs<br>បារ. banlieue(f.) | កន្លែងដែលជាផ្នែកនៃក្រុង ហើយស្ថិតក្រៅពីកណ្តាលក្រុង។ ជាទូទៅ ជាយក្រុងជាកន្លែងអភិវឌ្ឍថ្មីឬកំពុងដំណើរការអភិវឌ្ឍ។<br>ឧ. គិតត្រឹមឆ្នាំ២០១៤ ជាយក្រុងភ្នំពេញ មានខណ្ឌដង្កោ ខណ្ឌសែនសុខ ខណ្ឌពោធិ៍សែនជ័យ ...។ |
| **១៤២- ភូមិជាយក្រុង**<br>អ. suburb<br>បារ. faubourg (m.) | ភូមិឆ្ងាយៗនៃជាយក្រុង ភាគច្រើនជាកន្លែងតាំងទីលំនៅថ្មីនៃអ្នកចេញពីកណ្តាលក្រុងឬអ្នកមកពីជនបទ និង ដែលកំពុងដំណើរការអភិវឌ្ឍ។ |
| **១៤៣- របេកក្រុង**<br>អ. urbanization<br>បារ. urbanisation (f.) | ការរីកក្រុងបណ្តាលមកពីលំហូរចូលប្រជាជនច្រើនពីជនបទឬកន្លែងផ្សេងទៀត។<br>ឧ.ប្រទេសកំពុងអភិវឌ្ឍមានរបេកក្រុងលឿន ពិសេសបណ្តាលមកពីចំណោលជនបទ។ |

| | |
|---|---|
| **១៤៤- របើសក្រុង**<br>**អ.** municipal pound<br>**បារ.** fourrière municipale | ទីតាំងដោយឡែកមួយរបស់ក្រុង សម្រាប់ទុកជាបណ្ដោះអាសន្ននូវរបស់របរ ឬសត្វដែលគ្មានសណ្ដាប់ធ្នាប់នៅទីសាធារណៈ ហើយ ដែលត្រូវបានសមត្ថកិច្ច រឹបអូស ប្រមូល ឬ រើសបាន។ |
| **១៤៥- បណ្ដុំក្រុង**<br>អ. megalopolis/ megacity<br>បារ. mégalopole (f.) | ទីក្រុងដ៏ធំមួយដែលកើតឡើងដោយការផ្ដុំទីក្រុងឬក្រុងជាច្រើនជាប់ៗគ្នា។<br>ឧ. បណ្ដុំក្រុងនៃសហរដ្ឋអាម៉េរិកមានបណ្ដោយឆ្នេរមហាសមុទ្រអាត្លង់ទិកលាតសន្ធឹងពីជើងទៅត្បូងពីទីក្រុងបូស្តុនទៅទីក្រុងវ៉ាស៊ីនតោនប្រវែង៨៥០គ.ម. និង មានប្រជាជនជាង៤០លាននាក់(ឆ្នាំ២០០០)។ |
| **១៤៦- មេត្រូប៉ូល**<br>អ. metropolis<br>បារ. métropole (f.) | ១- រាជធានី/រដ្ឋធានីនយោបាយនៃប្រទេសមួយ។<br>២-ទីក្រុងធំជាងគេនៃប្រទេសមួយ។<br>៣-មជ្ឈមណ្ឌលសំខាន់ជាងគេក្នុងវិស័យអ្វីមួយនៃប្រទេសមួយ។<br>៤-ទីក្រុងធំជាងគេឬមជ្ឈមណ្ឌលសេដ្ឋកិច្ចសំខាន់ជាងគេនៃតំបន់មួយ។ |
| **១៤៧-ប្រទេសមេ**<br>អ. home country<br>បារ. métropole (f.) | ប្រទេសដែលគ្រប់គ្រងទឹកដីអាណានិគមផ្សេងៗ។<br>ឧ. ក្នុងសម័យអាណានិគម ប្រទេសបារាំងជាប្រទេសមេនៃប្រទេសកម្ពុជា វៀតណាម ឡាវ និង ប្រទេសដទៃទៀត។ |
| **១៤៨-ទីសំណាក់**<br>អ. residence<br>បារ. residence(f.) | កន្លែងដែលបុគ្គលម្នាក់ៗស្នាក់អាស្រ័យនៅជាក់ស្ដែងក្នុងរយៈពេលជាកំណត់ណាមួយដែលមិនមែនជាលំនៅឋាន។<br>ឧ.ឈ្មោះ ក មានលំនៅឋាននៅខេត្តតាកែវ បានជួលផ្ទះនៅភ្នំពេញ ដើម្បីរៀន។ ផ្ទះនៅភ្នំពេញនេះហៅថា ទីសំណាក់។ |
| **១៤៩- លំនៅឋាន**<br>អ. domicile<br>បារ. domicile(m.) | ទីកន្លែងដែលជាទីតាំងនៃជីវភាពរស់នៅជាអចិន្ត្រៃយ៍របស់បុគ្គលម្នាក់ៗ។ |
| **១៥០- ទីលំនៅ**<br>អ. habitation<br>បារ. habitation(f.) | ទីឬកន្លែងដែលមនុស្សនៅឬសម្រាប់មនុស្សនៅ ដោយមិនគិតថាជាលំនៅឋានឬជាទីសំណាក់។ ក្នុងការប្រើប្រាស់ គេប្រើពាក្យទីលំនៅឬអាសយដ្ឋានសម្រាប់បំពេញឯកសារផ្សេងៗ។ |
| **១៥១- និវេសនដ្ឋាន**<br>អ. residence<br>បារ .résidence (f.) | កន្លែងនៅជាផ្លូវការសម្រាប់ថ្នាក់ដឹកនាំប្រទេស តំណាងប្រទេស តំណាងស្ថាប័នជាតិឬអន្តរជាតិ ក្នុងរយៈពេលកំណត់នៃអាណត្តិរបស់ខ្លួន។ |
| **១៥២- អន្តេវាសិកដ្ឋាន**<br>អ.boarding school | កន្លែងដែលសិស្សឬនិស្សិតនៃគ្រឹះស្ថានសិក្សាណាមួយ ស្នាក់នៅ រៀនសូត្រ បរិភោគ ...។ |

| | |
|---|---|
| **១៥៣- ភូមិឋាន**<br>អ.settlement<br>បារ.habitat (m.) | ការតាំងទីលំនៅក្នុងកន្លែងណាមួយ ដែលមានលក្ខណៈ ទម្រង់ដោយឡែក ខាងនគរូបនីយកម្ម ប្រពៃណីជនជាតិ បរិស្ថាន សង្គមកិច្ច កម្មសិទ្ធិដីធ្លី ...។<br>ឧ. បុរី១០០ខ្នង (សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ), ភូមិអភិវឌ្ឍអន្លង់ជ្រៃសម្ដេច ហេង សំរិន (ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ) ជាភូមិឋាន។ |
| **១៥៤- អាសយដ្ឋាន**<br>អ.address<br>បារ.adresse (f.) | ការចង្អុលបង្ហាញជាក់លាក់នៃទីកន្លែងណាមួយ។ អាសយដ្ឋានអាចប្រើជាកូអរដោណេ(រយៈទទឹងនិងរយៈបណ្ដោយ) លេខជាក់លាក់នៅតាមផ្លូវ(ផ្ទះលេខ ...) ចំណុចចង្អុលណាមួយក្នុងផែនទី(ខាងកើតផ្សារ ...) ឈ្មោះហៅកន្លែងណាមួយ(ភូមិដើមអម្ពិល ភូមិចាម ...) ជាដើម។ |
| **១៥៥- ភូមិវិទ្យាសេដ្ឋកិច្ច**<br>អ.economic geography<br>បារ.géographie(f.) économique | ផ្នែកមួយនៃភូមិវិទ្យាដែលពាក់ព័ន្ធនឹងផលិតកម្ម របាយ ការដោះដូរនិងការប្រើប្រាស់ធនធាន រួមទាំងការសិក្សាពីកត្តាសេដ្ឋកិច្ចដែលមានឥទ្ធិពលលើរបាយនិងភាពខុសគ្នានៅលើផ្ទៃផែនដី។ |
| **១៥៦- ភូមិវិទ្យាកសិកម្ម**<br>អ. agricultural geography<br>បារ.géographie agricole | ផ្នែកមួយនៃភូមិវិទ្យាសេដ្ឋកិច្ចដែលសិក្សាអំពីទិដ្ឋភាពផ្សេងៗនៃការដាំដុះនិងការចិញ្ចឹមសត្វ។ |
| **១៥៧- ផ្ទះ/គេហដ្ឋាន**<br>អ. home<br>បារ.demeure/maison | អគារដែលសង់ឡើងសម្រាប់មនុស្សរស់នៅ។ |
| **១៥៨- កសិកម្មយថាផល**<br>អ.extensive agriculture<br>បារ.agriculture extensive | ការដាំដុះឬការចិញ្ចឹមសត្វ ដែលប្រើទុននិងពលកម្មតិច ហើយ ទទួលបានផលតាមលក្ខខណ្ឌធម្មជាតិ។ |
| **១៥៩- កសិកម្មអតិផល**<br>អ.intensive agriculture<br>បារ.agriculture(f.) intensive | ការដាំដុះឬការចិញ្ចឹមសត្វដែលប្រើទុននិងបច្ចេកទេសខ្ពស់ ហើយ ទទួលបានទិន្នផលខ្ពស់ក្នុងផ្ទៃដីមួយឯកតា។ |
| **១៦០- កសិកម្មប្រពៃណី**<br>អ.traditional agriculture<br>បារ.agriculture(f.) traditionnelle | កសិកម្មដែលប្រតិបត្តិការដាំដុះនិងការចិញ្ចឹមសត្វបន្តពីជំនាន់មុន ដូចជា របៀបប្រើប្រាស់ពូជ របៀបដាំដុះ ការប្រើប្រាស់កម្លាំងពលកម្ម(គោ ក្របី)... ហើយ ជាទូទៅ ទទួលផលតាមលក្ខខណ្ឌធម្មជាតិ។ |

## II.២.៤- បច្ចេកសព្ទស្នើដោយគណៈកម្មការវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា

| | |
|---|---|
| **១- ស៊ីតចំនួនពិត**<br>អ. real sequence<br>បារ. suite réelle (f.) | អនុគមន៍លេខដែលកំណត់ពីសំណុំ $\{0, 1, 2, 3, \cdots\}$ ឬ $\{1, 2, 3, 4, \cdots\}$ ទៅ $\mathbb{R}$ ។ ឧទាហរណ៍ 1, 5, 9, 13, 17, ... ជាស៊ីតចំនួនពិត។ |
| **២-ស៊េរី**<br>អ. series<br>បារ. série (f.) | ផលបូកពីជគណិតនៃតួទាំងឡាយរបស់ស៊ីតមួយ។<br>ឧទាហរណ៍៖<br>១. 1 + 2 + 3 + ... + 2010 + 2011 ជាស៊េរីកំណត់។<br>២. 2 + 4 + 6 + ... + 2n + 2(n + 1) + ... ជាស៊េរីអនន្ត។ |
| **៣- លីមីត**<br>អ. limit<br>បារ. limite(f.) | តម្លៃដែលអថេរឬអនុគមន៍ ខិតទៅជិតតម្លៃនោះ។ |
| **៤- លីមីតនៃអនុគមន៍**<br>អ. limit of function<br>បារ. limite de fonction (f.) | តម្លៃ $L$ ដែលអនុគមន៍ $f(x)$ ខិតជិត កាលណា $x$ ខិតជិត $c$ មានន័យថា ចំពោះគ្រប់ចំនួន $\varepsilon > 0$ គេមានចំនួន $\alpha > 0$ ដែល $0 < \|x - c\| < \alpha$ គេបាន $\|f(x) - L\| < \varepsilon$ ។ គេសរសេរ $\lim f(x) = L$ កាលណា $x$ ខិតជិត $c$ ឬ $\lim_{x \to c} f(x) = L$ ។ |
| **៥- ដេរីវេ**<br>អ. derivative<br>បារ. dérivée (f.) | លីមីតនៃផលធៀបរវាងផលដកអនុគមន៍និងផលដកអថេរ កាលណាផលដកអថេរនោះខិតជិតសូន្យ។ |
| **៦- អាំងតេក្រាល**<br>អ. integral<br>បារ. intégrale (f.) | ផលបូកផ្ទៃក្រឡាចតុកោណកែងតូចៗ ដែលខណ្ឌដោយអនុគមន៍មួយអថេរ $f(x)$ និងអក្សអាប់ស៊ីស ហើយមានតម្លៃវិជ្ជមានឬអវិជ្ជមានស្របតាមតម្លៃអ័រដោណេដែលមានរាង $\int f(x)dx$ ។ |
| **៧- អាំងតេក្រាលកំណត់**<br>អ. definite integral<br>បារ. intégrale définie | អាំងតេក្រាលដែលអថេរ $x$ ប្រែប្រួលក្នុងចន្លោះកំណត់មួយពី $a$ ទៅ $b$ ដែលមានរាង $\int_a^b f(x)dx$ ។ |
| **៨- អាំងតេក្រាលមិនកំណត់**<br>អ. indefinite integral<br>បារ. intégrale indéfinie | អាំងតេក្រាលដែលអថេរប្រែប្រួលមិនកំណត់។<br>ឧទាហរណ៍៖ $\int x^2 dx$ ជាអាំងតេក្រាលមិនកំណត់។ |
| **៩- អាំងតេក្រាលពីរជាន់ (អាំងតេក្រាលឌុប)**<br>អ. double integral/ double iterated integral<br>បារ. intégrale double | អាំងតេក្រាលនៃអនុគមន៍ពីរអថេរ $f(x, y)$ ដែលមានរាង $\iint f(x, y)dx\,dy$ ។ |

| | |
|---|---|
| **១០- អាំងតេក្រាល** n ជាន់<br>អ.$n^{th}$ iterated integral / $n^{th}$-order integral | អាំងតេក្រាលនៃអនុគមន៍ n អថេរ ដែលមានរាង $\underbrace{\iint\cdots\iint}_{n} f(x_1, x_2, ..., x_{n-1}, x_n)\underbrace{dx_1 dx_2 ... dx_{n-1} dx_n}_{n}$ ហើយ n ជាចំនួនគត់ធម្មជាតិ។ |
| **១១- លីនេអ៊ែ**<br>អ. linear<br>បារ. linéaire | ១- ដែលមានលក្ខណៈជាបន្ទាត់ត្រង់ឬដែលទាក់ទងនឹងដឺក្រេទីមួយ។<br>ឧទាហរណ៍ : សមីការលីនេអ៊ែ $y = ax + b$ ។<br>២- ដែលមានវិមាត្រមួយ។<br>៣- នៃលំដាប់ទីមួយ។ |
| **១២- សមីការលីនេអ៊ែ**<br>អ. linear equation<br>បារ. équation linéaire | - សមីការពហុធាដឺក្រេទីមួយ។<br>ឧទាហរណ៍៖ $y = 4x + 3$ និង $x + y = 7$ ជាសមីការលីនេអ៊ែ។<br>- សមីការមួយដែលអាចសរសេរជាទម្រង់ $a_1 x_1 + a_2 x_2 + ... + a_n x_n = b$ ដែល $x_1, x_2, ...., x_n$ ជាអថេរ ហើយ b និង $a_1, a_2, ..., a_n$ ជាចំនួនពិត ឬកុំផ្លិច។ |
| **១៣- ពីជគណិតលីនេអ៊ែ**<br>អ. linear algebra<br>បារ. algèbre linéaire | មែកធាងនៃគណិតវិទ្យាដែលទាក់ទងនឹងការសិក្សាអំពីវ៉ិចទ័រ លំហវ៉ិចទ័រ បម្លែងលីនេអ៊ែ និង ប្រព័ន្ធសមីការលីនេអ៊ែ។ |
| **១៤- សមីការពីជគណិត**<br>អ. algebraic equation<br>បារ. équation algébrique | សមីការដែលមានរាង $f(x) = 0$ ដែល $f(x)$ ជាពហុធាណាមួយ។<br>ឧទាហរណ៍៖ សមីការ $x^3 - 5x + 4 = 0$ ជាសមីការពីជគណិត។ |
| **១៥- វិភាគវ៉ិចទ័រ**<br>អ. vector analysis<br>បារ.analyse vectorielle | ផ្នែកមួយនៃគណិតវិទ្យាដែលសិក្សាអំពីវ៉ិចទ័រ អនុគមន៍វ៉ិចទ័រ ទំនាក់ទំនង (គណនាឌីផេរ៉ង់ស្យែលនិងអាំងតេក្រាល) និង ការអនុវត្តរបស់វា។ |
| **១៦- វិមាត្រ**<br>អ. dimension<br>បារ. dimension (f.) | (ពីជគណិតលីនេអ៊ែ) - ចំនួននៃវ៉ិចទ័រនៅក្នុងគោលមួយនៃលំហវ៉ិចទ័រ V ដោយសរសេរជា dim V ។<br>ឧទាហរណ៍៖ $\dim\mathbb{R} = 1$, $\dim\mathbb{R}^2 = 2$ និង $\dim\mathbb{R}^3 = 3$ ។<br>- វិមាត្រនៃម៉ាទ្រីសមួយ គឺជាចំនួននៃជួរដេកនិងជួរឈររបស់វា។<br>(ធរណីមាត្រ) - ទំហំនៃរូបប្លង់មួយឬសូលីត។<br>ឧទាហរណ៍៖ ១- វិមាត្រនៃរង្វង់មួយ គឺជាកាំ។<br>២- វិមាត្រនៃចតុកោណកែងមួយ គឺជាបណ្តោយនិងទទឹង។<br>៣- វិមាត្រនៃប្រលេពីប៉ែតកែង គឺជាបណ្តោយ ទទឹង និងកម្ពស់។ |
| **១៧- គណិតវិទ្យា**<br>អ. mathematics<br>បារ. mathématiques (f.) | វិទ្យាសាស្ត្រដែលសិក្សាអំពី នព្វន្ត ធរណីមាត្រ ពីជគណិត គណិតវិទ្យាវិភាគ គណិតវិទ្យាគណនា ជាដើម ហើយសិក្សាអំពី បរិមាណ ទំហំ លំដាប់ ទម្រង់ ទំនាក់ទំនង និង លក្ខណៈរបស់វា ដោយប្រើប្រាស់ចំនួននិងមិត្តសញ្ញា។<br>គណិតវិទ្យាចែកជាពីរផ្នែកធំៗ គឺ គណិតវិទ្យាសុទ្ធ និង គណិតវិទ្យាអនុវត្ត។ |

| | |
|---|---|
| **១៨- គណិតវិទ្យាអនុវត្ត**<br>អ. applied mathematics<br>បារ. mathématiques appliquées (f.) | ផ្នែកមួយនៃគណិតវិទ្យាសម្រាប់ប្រើក្នុងការអនុវត្តលើផ្នែកវិទ្យាសាស្ត្រនិង/ឬ ផ្នែកវិទ្យាសាស្ត្រសង្គម។ |
| **១៩- គណិតវិទ្យាសុទ្ធ**<br>អ. pure mathematics<br>បារ. mathématiques pures(f.) | ផ្នែកមួយនៃគណិតវិទ្យាដែលទាក់ទងនឹងតក្កវិទ្យា រូបមន្ត គំនិតអរូបី ទម្រង់ គោលការណ៍ សោភ័ណ...។ |
| **២០- ដ្យាក្រាម**<br>អ. diagram<br>បារ. diagramme (m.) | - គំនូសតាងបកាសន៍មួយជាលក្ខណៈរូបភាព។<br>- ការតាង/គំនូសតាងរូបភាពឬក្រាហ្វនៃជាតុមួយចំនួនដែលទាក់ទងគ្នា។<br>ឧទាហរណ៍៖ ដ្យាក្រាមព្រួញ ដ្យាក្រាមវិន។ |
| **២១- អាប់ស៊ីស**<br>អ. abscissa<br>បារ. abscisse (f.) | - កូអ័រដោណេ x នៃចំណុចមួយនៅក្នុងប្រព័ន្ធ ឬ តម្រុយកូអ័រដោណេ វិមាត្រពីរ។<br>- ចម្ងាយនៃចំណុចមួយពីអ័ក្សអ័រដោណេ (អក្ស (y’oy) ) ដែលត្រូវបានវាស់ ស្របទៅនឹងអ័ក្សអាប់ស៊ីស( អ័ក្ស (x’ox) ) ។<br>ឧទាហរណ៍៖ អាប់ស៊ីសនៃចំណុច P(5, 3) គឺ 5 ។<br> |
| **២២-តម្លៃដាច់ខាត**<br>អ. absolute value<br>បារ. valeur absolue (f.) | - តម្លៃវិជ្ជមានចំពោះចំនួនពិតមួយដែលមិនគិតទៅលើសញ្ញារបស់វា តាងដោយ $\|x\|$ ។<br>ឧទាហរណ៍៖ $\|6\| = 6, \|-7\| = 7$ និង $\|0\| = 0$ ។<br>- ម៉ូឌុល ឬ ចម្ងាយដែលគិតចេញពីគល់អ័ក្ស ឬ តម្រុយទៅចំណុចមួយ។<br>ឧទាហរណ៍៖ គេឱ្យចំណុច $P(x_0 , y_0)$ តាងចំនួនកុំផ្លិច $z = x_0 + i\,y_0$ នៅក្នុងប្លង់កុំផ្លិច (x0y)។ ចម្ងាយរវាងគល់តម្រុយ 0 និងចំណុច $P(x_0, y_0)$ គឺ<br>$\|z\| = \|OP\| = OP = \\|\overrightarrow{OP}\\| = \sqrt{x_0^2 + y_0^2}$ ។ |

| | |
|---|---|
| |  |
| **២៣- បំលែង**<br>អ. transformation<br>បារ. transformation (f.) | -(ពីជគណិត) ការផ្លាស់ប្តូរពីកន្សោមពីជគណិត ឬសមីការមួយទៅជាទម្រង់ផ្សេងមួយទៀតដែលសមមូលនឹងវា។<br>-(ធរណីមាត្រ)ការផ្លាស់ប្តូររូបសណ្ឋានមួយទៅរូបសណ្ឋានមួយទៀតដោយប្តូរចំណុចនីមួយៗទៅទីតាំងផ្សេងមួយទៀតតាមលំនាំជាក់លាក់។ |
| **២៤-ភាពឆ្លុះ / ស៊ីមេទ្រី**<br>អ. symmetry<br>បារ. symétrie (f.) | លក្ខណៈនៃរូបសណ្ឋានធរណីមាត្រដែលឆ្លុះគ្នាធៀបនឹងអ័ក្សឆ្លុះ ផ្ចិតឆ្លុះ ឬប្លង់ឆ្លុះ។ |
| **២៥- បំលែងប៉ុន / អ៊ីសូមេទ្រី**<br>អ. isometry<br>បារ. isométrie (f.) | បំលែងដែលនៅក្នុងនោះមានចម្ងាយរវាងចំណុចពីរមិនផ្លាស់ប្តូរ។ |
| **២៦- ម៉ាទ្រីស**<br>អ. matrix<br>បារ. matrice (f.) | តម្រៀបជាតុ(aij) ដែលត្រូវបានរៀបក្នុងទម្រង់ជាជួរដេកនិងជួររឈរ។<br>ឧទាហរណ៍ : $\begin{bmatrix} a_{11} & a_{12} \\ a_{21} & a_{22} \\ a_{31} & a_{32} \end{bmatrix}$ គឺជាម៉ាទ្រីសមួយដែលមានលំដាប់(វិមាត្រ)$3 \times 2$។<br>គេអាចតាងម៉ាទ្រីសខាងលើបែបនេះក៏បាន : $\begin{pmatrix} a_{11} & a_{12} \\ a_{21} & a_{22} \\ a_{31} & a_{32} \end{pmatrix}$ ។ |
| **២៧- ម៉ាទ្រីសការ៉េ**<br>អ. square matrix<br>បារ. matrice carrée (f.) | ម៉ាទ្រីសដែលមានចំនួនជួរដេកស្មើនឹងចំនួនជួរឈរ។<br>ឧទាហរណ៍ : $\begin{pmatrix} a_{11} & a_{12} & a_{13} \\ a_{21} & a_{22} & a_{23} \\ a_{31} & a_{32} & a_{33} \end{pmatrix}$ ជាម៉ាទ្រីសការ៉េមួយដែលមានលំដាប់ (វិមាត្រ) $3 \times 3$ ។ |
| **២៨- ម៉ាទ្រីសសូន្យ**<br>អ. zero matrix<br>បារ. matrice zéro (f.) | ម៉ាទ្រីសដែលមានធាតុទាំងអស់ស្មើនឹងសូន្យ។ ម៉ាទ្រីសសូន្យតាងដោយ O ឬ $O_{m \times n}$ ។ |

| | |
|---|---|
| | ឧទាហរណ៍ : $O=O_{2\times 3}=\begin{bmatrix}0&0&0\\0&0&0\end{bmatrix}$ ជាម៉ាទ្រីសសូន្យមានលំដាប់(វិមាត្រ) 2 $\times$ 3។ |
| **២៩- ម៉ាទ្រីសឯកតា**<br>អ. unit matrix<br>បារ. matrice unité (f.) | ម៉ាទ្រីសការ៉េដែលធាតុនៅលើអង្កត់ទ្រូងគោលស្មើនឹង 1 ហើយធាតុផ្សេងទៀតស្មើនឹងសូន្យ។ ម៉ាទ្រីសឯកតាតាងដោយ $I$ ឬ $I_n$ ។<br>ឧទាហរណ៍ : $I=I_3=\begin{bmatrix}1&0&0\\0&1&0\\0&0&1\end{bmatrix}$ ជាម៉ាទ្រីសឯកតាមានលំដាប់ $3\times 3$ ។ |
| **៣០- ម៉ាទ្រីសច្រាស**<br>អ. inverse matrix<br>បារ. matrice inverse (f.) | ម៉ាទ្រីស B មួយនៃម៉ាទ្រីសការ៉េ A ដែលផ្ទៀងផ្ទាត់ $BA=I=AB$ ក្នុងនោះ B មាន លំដាប់ដូចគ្នានឹង A ហើយ I ជាម៉ាទ្រីសឯកតាដែលមានលំដាប់ដូចគ្នា នឹង A ។ គេអាចសរសេរ B ស្មើនឹង $A^{-1}$។<br>ឧទាហរណ៍ : គេមានម៉ាទ្រីស $A=\begin{bmatrix}1&0\\1&1\end{bmatrix}$ និង $B=\begin{bmatrix}1&0\\-1&1\end{bmatrix}$ នោះ $BA=I_2=AB$ មានន័យថា B ជាម៉ាទ្រីសច្រាសនៃម៉ាទ្រីស A ដែលសរសេរជា<br>$A^{-1}=B=\begin{bmatrix}1&0\\-1&1\end{bmatrix}$ ។ |
| **៣១- វ៉ិចទ័រ**<br>អ. vector<br>បារ. vecteur (m.) | - បរិមាណដែលមានទំហំ (ប្រវែង) និងទិសដៅដែលតាងដោយអង្កត់ត្រង់មានទិសដៅ។<br>ឧទាហរណ៍ : វ៉ិចទ័របម្លាស់ទី វ៉ិចទ័រល្បឿន វ៉ិចទ័រសំទុះ វ៉ិចទ័រកម្លាំង។ល។<br>វ៉ិចទ័រត្រូវបានគេសរសេរដោយដាក់សញ្ញាព្រួញនៅពីលើអក្សរ ដូចជា $\vec{a}$ ឬ $\overrightarrow{A}$ ។ វាក៏អាចតាងដោយអក្សរដិត **a** ឬ **A** ។ |
| **៣២- នព្វន្ត**<br>អ. arithmetic<br>បារ.arithmétique (f.) | ផ្នែកមួយនៃគណិតវិទ្យាដែលសិក្សាអំពីប្រមាណវិធី ដូចជា វិធីបូក វិធីដក វិធីគុណ និងវិធីចែក។ |
| **៣៣-ដ្យាក្រាមព្រួញ**<br>អ. diagram of arrow / arrow diagram<br>បារ. graphe? schéma de la flèche / diagramme de la flèche (m.) | ដ្យាក្រាមដែលបានចុះធាតុនៃសំណុំ A និងធាតុនៃសំណុំ B ក្នុងថាសពីរដាច់ពីគ្នា ដោយមានភ្ជាប់សញ្ញាព្រួញពីធាតុ $x\in A$ ទៅធាតុ $y\in B$ ដែលទាក់ទងគ្នាតាមទំនាក់ទំនងទ្វេធាតុ $\mathcal{R}$ ។<br>ដ្យាក្រាមខាងក្រោមនេះជាដ្យាក្រាមព្រួញមួយ។<br> |

| | |
|---|---|
| **៣៤- ដ្យាក្រាមវិន**<br>អ. Venn diagram<br>បារ. diagramme de Venn (m.) | ដ្យាក្រាមតាងដោយសំណុំចំណុចនៅក្នុងប្លង់។ គេតាងសំណុំសាកល U ដោយផ្ទៃក្នុងនៃចតុកោណកែង ហើយសំណុំរងរបស់វាដោយថាសដែលនៅខាងក្នុងចតុកោណកែងនេះ។ រូបខាងក្រោមនេះ ជាដ្យាក្រាមវិនមួយ។<br><br> |
| **៣៥- អឺរ៉េ**<br>អ. array<br>បារ. tableau (m.) ?/ rangée(f.) ? | -តម្រៀបតាមលំដាប់(មានលំដាប់)នៃចំនួនឬធាតុមួយចំនួនផ្សេងទៀត ដែលបានប្រើប្រាស់នៅក្នុងដេទែរមីណង់និងម៉ាទ្រីស។<br>- តម្រៀបតាមលំដាប់នៃវត្ថុតាមជួរឈរនិងជួរដេក។<br>ឧទាហរណ៍ : ម៉ាទ្រីស វ៉ិចទ័រជួរឈរ ដេទែរមីណង់ សុទ្ធតែជាអឺរ៉េ។ |
| **៣៦- ផ្ចិតពហុកោណនិយ័ត**<br>អ. center of a regular polygon<br>បារ. Centre de polygone régulier | ចំណុចមួយខាងក្នុងពហុកោណនិយ័តដែលស្ថិតនៅចម្ងាយស្មើគ្នាពីកំពូលទាំងអស់របស់វា។<br> |
| **៣៧- រូប**<br>អ. figure<br>បារ. figure (f.) | ទ្រង់ទ្រាយឬរាងរៅដែលកំណត់ដោយខ្សែគំនូសឬផ្ទៃ ដូចជា រាងមូល រាង ការ៉េ រាងគូប ជាដើម។ |
| **៣៨- រូបធរណីមាត្រ**<br>អ. geometric figure<br>បារ. figure éométrique | សំណុំចំណុចនៅលើប្លង់ឬក្នុងលំហ។ |
| **៣៩-រូបប្លង់**<br>អ. plane figure<br>បារ. figure plane | រូបធរណីមាត្រដែលស្ថិតនៅលើប្លង់។ |
| **៤០- រាងធរណីមាត្រ**<br>អ. geometric shape<br>បារ. forme géométrique (f.) | រូបធរណីមាត្រដែលអាចពណ៌នាតាមវិធីគណិតវិទ្យា។ |
| **៤១- ពហុកោណផត**<br>អ. concave polygon<br>បារ. polygone concave | ពហុកោណដែលមានរង្វាស់មុំក្នុងណាមួយធំជាង$180^0$ ។ |

| | |
|---|---|
| **៤២- ពហុកោណប៉ោង**<br>អ. convex polygon<br>បារ. polygone convexe | ពហុកោណដែលមិនមានរង្វាស់មុំក្នុងណាមួយធំជាង$180^0$។ |
| **៤៣- ត្រីកោណកែង**<br>អ. right triangle / right- angled triangle<br>បារ. triangle rectangle ( m. ) | ត្រីកោណដែលមានមុំកែងមួយ។<br>ឧទាហរណ៍ : ត្រីកោណ ABC ជាត្រីកោណកែងត្រង់ C ។<br> |
| **៤៤- ត្រីកោណសមបាត**<br>អ. isosceles triangle<br>បារ. triangle isocèle( m. ) | ត្រីកោណដែលមានជ្រុងពីរប្រវែងស្មើគ្នា។<br>ឧទាហរណ៍ : ត្រីកោណ ABC ជាត្រីកោណសមបាត។<br> |
| **៤៥- ត្រីកោណវិសមបាត**<br>អ. scalene triangle<br>បារ. triangle scalène ( m. ) | ត្រីកោណដែលមានជ្រុងបីប្រវែងមិនស្មើគ្នា។<br>ឧទាហរណ៍ : ត្រីកោណ ABC ជាត្រីកោណញ្ញយ។<br> |
| **៤៦- ត្រីកោណទ្រេត**<br>អ. oblique triangle<br>បារ. triangle oblique | ត្រីកោណដែលមិនមានមុំក្នុងណាមួយនៃកំពូល ជាមុំកែង។<br>ឧទាហរណ៍ : ត្រីកោណសម័ង្ស ត្រីកោណសមបាត ... ជាត្រីកោណទ្រេត។ |
| **៤៧- ត្រីកោណស្រួច**<br>អ. acute triangle<br>បារ. triangle aigu | ត្រីកោណដែលមានមុំក្នុងទាំងបីនៃកំពូលជាមុំស្រួច( តូចជាង៩០$^0$ )។ |

| | |
|---|---|
| **៤៨- ត្រីកោណទាល**<br>អ. obtuse triangle<br>បារ. triangle obtus<br>(m.) | ត្រីកោណដែលមានមុំក្នុងណាមួយនៃកំពូលជាមុំទាល(ធំជាង៩០$^0$ តូចជាង១៨០$^0$)។<br> |
| **៤៩- ជ្រុង**<br>អ. side<br>បារ. côté (m.) | - បន្ទាត់ដែលខណ្ឌរូបប្លង់មួយ។<br>- ផ្ទៃ/មុខដែលខណ្ឌរូបសូលីដមួយ។<br> |
| **៥០- ទ្រនុង**<br>អ. edge<br>បារ. arête (f.) | អង្កត់ដែលជាប្រសព្វរវាងមុខពីរនៃសូលីដ។ |
| **៥១- មុខ**<br>អ. face<br>បារ. face (f.) | ផ្ទៃដែលខណ្ឌរូបសូលីដមួយ។<br> |
| **៥២- សូលីដ**<br>អ. solid<br>បារ. solide (m.) | រូបធរណីមាត្រក្នុងប្រព័ន្ធវិមាត្របី។ |
| **៥៣- ប្លង់**<br>អ. plane<br>បារ. plan (m.) | ផ្ទៃរាបស្មើគ្មានព្រំដែនកំណត់ដែលមានវិមាត្រពីរ។ |
| **៥៤- ចំណុច**<br>អ. point<br>បារ. point (m.) | រូបដែលមានទីតាំងជាក់លាក់ ហើយដែលមានវិមាត្រស្មើសូន្យ។ |
| **៥៥- វិមាត្រពីរ**<br>អ. two-dimensional or 2D/<br>បារ. bidimensionnel | ដែលមានតែបណ្ដោយនិងទទឹង។<br>- (រូបភាពក្នុងប្លង់) ដែលកំណត់ឡើងដោយវិមាត្រចំនួនពីរ ដូចជាបណ្ដោយនិងទទឹង ឬបាតនិងកម្ពស់ ឬ...។ |

| | |
|---|---|
| **៥៦- វិមាត្របី**<br>អ. three-dimensional or 3D<br>បារ. tridimensionnel | ដែលមានបណ្ដោយ ទទឹង និងកម្រាស់(កម្ពស់)។<br>-(រូបភាពក្នុងលំហ) ដែលកំណត់ឡើងដោយវិមាត្រចំនួនបី ដូចជាបណ្ដោយ ទទឹង និងកម្ពស់ឬកម្រាស់។ |
| **៥៧- ធរណីមាត្រប្លង់**<br>អ. plane geometry<br>បារ. géométrie plane | ផ្នែកមួយនៃធរណីមាត្រដែលសិក្សាអំពីរូបក្នុងប្លង់ ដូចជា ចំណុច បន្ទាត់ រង្វង់ ត្រីកោណ ជាដើម។ |
| **៥៨- លំហ**<br>អ. space<br>បារ. espace (m.) | វិសាលភាពវិមាត្របីឬច្រើនជាងបី គ្មានព្រំដែនកំណត់ដែលក្នុងនោះវត្ថុ និងព្រឹត្តិការណ៍មានទិសដៅនិងមានទីតាំងធៀប។ |
| **៥៩- ផ្នែកប្លង់**<br>អ. plane section<br>បារ. section du plan | ផ្នែកប្រសព្វនៃរូបនិងប្លង់ បង្កើតបានជាមុខកាត់ឬផ្នែកនានានៃប្លង់។ |
| **៦០- ធរណីមាត្រ**<br>អ. geometry<br>បារ. géométrie(f.) | ផ្នែកមួយនៃគណិតវិទ្យាដែលសិក្សាពីលក្ខណៈ ទំនាក់ទំនង និងរង្វាស់-ចំណុច បន្ទាត់ ខ្សែកោង មុំ ផ្ទៃ និងសូលីដ។ |
| **៦១- ធរណីមាត្រក្នុងលំហ**<br>អ. space/solid geometry<br>បារ. géométrie dans l'espace(f.) | ផ្នែកមួយនៃធរណីមាត្រដែលសិក្សាពីរូបធរណីមាត្រវិមាត្របីឬច្រើនជាងបី។ |
| **៦២- ធរណីមាត្រអឺគ្លីដ**<br>អ. Euclidean geometry<br>បារ. géométrie euclidienne(f.) | ធរណីមាត្រដែលសិក្សាពីឧបធារណ៍របស់អឺគ្លីដ។ |
| **៦៣- ធរណីមាត្រវិភាគ/ ធរណីមាត្រកូអ័រដោណេ/ ធរណីមាត្រកាតេស្យ៊ាង**<br>អ. analytic geometry/ analytical geometry / coordinate geometry/ cartesian geometry<br>បារ. géométrie analytique/ géométrie de oordonnées/ géométrie de cartésienne | ផ្នែកមួយនៃគណិតវិទ្យាដែលប្រើប្រាស់ពីជគណិតដើម្បីសិក្សាពីលក្ខណៈ ធរណីមាត្រ និងគណនាលើនិមិត្តសញ្ញាដែលកំណត់ក្នុងប្រព័ន្ធកូអ័រដោណេ។ |

| | |
|---|---|
| **៦៤- កំពូល**<br>អ. vertex<br>បារ. sommet(m.) | - ចំណុចប្រសព្វរវាងជ្រុងពីរនៃពហុកោណមួយដែលបង្កើតបានជាមុំខុសពីសូន្យ។<br>- ចំណុចប្រសព្វរវាងបន្ទាត់ពីរឬប្លង់ពីរដែលបង្កើតបានជាមុំខុសពីសូន្យ។<br>- ចំណុចប្រសព្វរវាងទ្រនុងពីរឬច្រើននៃពហុមុខដែលបង្កើតបានជាមុំខុសពីសូន្យ។ |
| **៦៥- មាឌ**<br>**អ.** volume<br>**បារ.** volume(m.) | បរិមាណនៃវត្ថុមួយ(រាវ រឹង ឬឧស្ម័ន)ឬរបស់ណ្ឌានដែលផ្ទុកវត្ថុនោះ នៅក្នុងលំហវិមាត្របី។ |
| **៦៦- បទគន្លឹះ**<br>**អ.** lemma<br>**បារ.** lemme(m.) | បកាសន៍ជាជំនួយសម្រាប់ប្រើសម្រួលដល់ការស្រាយបញ្ជាក់ទ្រឹស្តីបទ។ |
| **៦៧- វិចារ**<br>**អ.** argument<br>**បារ.** argument(m.) | (តក្កវិទ្យា)ភាពបន្តបន្ទាប់នៃបកាសន៍ទាំងឡាយដែលមានសេចក្តីសន្និដ្ឋានមួយត្រឹមត្រូវ។ |
| **៦៨- វិបាក**<br>**អ.** consequence<br>**បារ.**conséquence(f.) | ការសន្និដ្ឋានដែលបានមកពីវិចារ។ |
| **៦៩- ក្សូរ៉ូលែ /អនុសាធ្យ**<br>**អ.** corollary<br>**បារ.** corollaire(m.) | បកាសន៍ជាវិបាកនៃទ្រឹស្តីបទដែលបានស្រាយបញ្ជាក់រួច។ |
| **៧០- តក្កវិទ្យា**<br>អ. logic<br>បារ. logique(f.) | វិទ្យាសាស្ត្រដែលសិក្សាពីភាពសមហេតុផលនៃបកាសន៍ឬវិចារ។ |
| **៧១- ផ្នែកកោន**<br>**អ.** conic section<br>**បារ.** section conique(f.) | ខ្សែកោងមានរាងជារង្វង់ អេលីប ប៉ារ៉ាបូល អ៊ីពែបូល ដែលកំណត់បានពីការប្រសព្វរវាងកោននិងប្លង់។ |
| **៧២- ប្រព័ន្ធកូអ័រដោណេ**<br>អ. coordinate system<br>បារ. système de coordonnées | ប្រព័ន្ធដែលប្រើប្រាស់កូអ័រដោណេសម្រាប់កំណត់ទីតាំងចំណុច បន្ទាត់ ... ក្នុងប្លង់ឬលំហ។ |
| **៧៣- ពីជគណិត**<br>អ. algebra<br>បារ. algèbre(f.) | ផ្នែកមួយនៃគណិតវិទ្យាដែលសិក្សាពីប្រមាណវិធីនព្វន្តនិងទំនាក់ទំនងរវាងធាតុដោយប្រើប្រាស់អក្សរនិងនិមិត្តសញ្ញា សម្រាប់តាងចំនួន បរិមាណក្នុងរូបមន្តនិងសមីការ។ |

<table>
<tr><td>

**៧៤- ពីជគណិតអរូបី / ពីជគណិតទំនើប**

អ. abstract algebra / modern algebra

បារ. algèbre abstraite(f.)

</td><td>

ផ្នែកមួយនៃពីជគណិតដែលសិក្សាពីសំណុំនៃធាតុ ប្រមាណវិធី ស្វ័យសត្យ ទំនាក់ទំនង និងទម្រង់ពីជគណិតដូចជា ក្រុម កង កាយ។ល។

</td></tr>
<tr><td>

**៧៥- អេលីប**

អ. ellipse

បារ. ellipse (f.)

</td><td>

ខ្សែកោងបិទនៅក្នុងប្លង់ដែលផលបូកចម្ងាយពីគ្រប់ចំណុចរបស់វាទៅចំណុចនឹងពីរហៅថាកំណុំ មានតម្លៃថេរ។




</td></tr>
<tr><td>

**៧៦- ប៉ារ៉ាបូល**

អ. parabola

បារ. parabole(f.)

</td><td>

១-ផ្នែកកោនដែលជាប្រសព្វរវាងកោនជាមួយនឹងប្លង់ ដែលស្របតាមជនេត្រនៃកោននោះ។




២- សំណុំចំណុចដែលស្ថិតនៅស្មើចម្ងាយពីបន្ទាត់នឹងមួយ(បន្ទាត់ប្រាប់ ទិស) និងពីចំណុចនឹងមួយ(កំណុំ)ដែលស្ថិតនៅលើអ័ក្សឆ្លុះ។




</td></tr>
<tr><td>

**៧៧- អ៊ីពែបូល**

អ. hyperbola

បារ. hyperbole(f.)

</td><td>

១-ផ្នែកកោននៃទ្វេកោន ដែលបង្កើតដោយប្លង់មួយកាត់បាតទាំងពីរនៃទ្វេកោននោះ។

</td></tr>
</table>

| | |
|---|---|
| | <br>២- សំណុំចំណុចដែលមានផលដករវាងចម្ងាយពីគ្រប់ចំណុចនៃសំណុំចំណុចនោះទៅចំណុចនឹងពីរ( កំណុំ ) មានតម្លៃថេរ។<br><br>អ៊ីពែបូល |
| **៧៨- ស្វ័យសត្យ/ ឧបធារណ៍**<br>**អ.** axiom/postulate<br>**បារ.** axiome/postulat ( m. ) | បកាសន៍ដែលព្រមទទួលថាពិតជាសាកល ដោយមិនចាំបាច់ស្រាយបញ្ជាក់។ |
| **៧៩- ទ្វេកោន**<br>**អ.** double cone<br>**បារ.** double cône ( m. ) | រូបធរណីមាត្រដែលបង្កើតដោយកោនពីរទល់កំពូលគ្នា។<br><br>ទ្វេកោន |
| **៨០- ទ្រឹស្តីសំណុំ**<br>**អ.** set theory<br>**បារ.** théorie des ensembles ( f. ) | ផ្នែកមួយនៃគណិតវិទ្យាដែលសិក្សាពីលក្ខណៈនៃសំណុំ។ |

| | |
|---|---|
| ៨១- ទ្រឹស្ដីក្រុម<br>អ. group theory<br>បារ. théorie des groupes | ផ្នែកមួយនៃគណិតវិទ្យាដែលសិក្សាពីលក្ខណៈនៃក្រុម។ |
| ៨២- ទំនាក់ទំនង<br>អ. relation<br>បារ. relation(f.) | សំណុំនៃតម្លៃធាតុចូលនិងធាតុចេញ ដែលតាងជាគូមានលំដាប់ ឬជាសំណុំរងនៃផលគុណដេកាត។<br>ឧ. សំណុំនៃគូមានលំដាប់ $\{(1, 2), (3, 6), (5, 10)\}$ ជាទំនាក់ទំនង។<br><br> |
| ៨៣- ផលគុណដេកាត/ ផលគុណកាតេស្យ៉ាង<br>អ. Cartesian product<br>បារ. produit cartesien (m.) | សំណុំមួយដែលបង្កើតឡើងដោយសំណុំពីរដែលបានឱ្យ ហើយមានគ្រប់ធាតុជាគូមានលំដាប់ដែលធាតុទី១នៃគូនីមួយៗយកពីសំណុំទី១និងធាតុទី២យកពីសំណុំទី២។<br>ឧទាហរណ៍ : បើសំណុំ $A = \{1, 2\}$ និង $B = \{2, 3, 5\}$ នោះផលគុណដេកាតនៃ A និង B គឺ<br>$A \times B = \{(1, 2), (1, 3), (1, 5), (2, 2), (2, 3), (2, 5)\}$។ |
| ៨៤- កង<br>អ. ring<br>បារ. anneau(m.) | (ពីជគណិតអរូបី) សំណុំនៃធាតុគណិតវិទ្យាដែលមានលក្ខណៈស៊ប់នឹងប្រមាណវិធីទ្វេធាតុពីរ ក្នុងនោះសំណុំនេះប្រដាប់ដោយប្រមាណវិធីទី១បង្កើតបានជាក្រុម មានលក្ខណៈត្រឡប់(ក្រុមអាបែល) ហើយប្រមាណវិធីទីពីរ មានលក្ខណៈផ្តុំលើសំណុំនេះ និងមានលក្ខណៈបំបែកធៀបនឹងប្រមាណវិធីទី១។ |
| ៨៥- ទ្រឹស្ដីកង<br>អ. ring theory<br>បារ. théorie d'anneau / théorie de l'anneau ? | ផ្នែកមួយនៃគណិតវិទ្យាដែលសិក្សាពីលក្ខណៈនៃកង។ |
| ៨៦- កាយ<br>អ. field<br>បារ. corps(m.) | សំណុំនៃធាតុគណិតវិទ្យាដែលមានលក្ខណៈស៊ប់នឹងប្រមាណវិធីទ្វេធាតុពីរ ដែលសំណុំនេះប្រដាប់ដោយប្រមាណវិធីទី១បង្កើតបានជាក្រុមមានលក្ខណៈត្រឡប់(ក្រុមអាបែល) និងប្រមាណវិធីទី២ ដែលបង្កើតបានជាក្រុមមានលក្ខណៈត្រឡប់(ក្រុមអាបែល) ដោយធាតុណឺតវាខុសពីធាតុសូន្យ ហើយប្រមាណវិធីទី២ មានលក្ខណៈបំបែកថែមទៀតផងបើធៀបនឹងប្រមាណវិធីទី១។ |
| ៨៧- ទ្រឹស្ដីកាយ<br>អ. field theory<br>បារ. théorie de corps | ផ្នែកមួយនៃគណិតវិទ្យាដែលសិក្សាពីលក្ខណៈនៃកាយ។ |

# V- លិខិតទាក់ទងនឹងការជូនព្រឹត្តិបត្រលេខ៧ របស់ក្រុមប្រឹក្សាជាតិភាសាខ្មែរ

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**

ក្រុមប្រឹក្សាជាតិភាសាខ្មែរ
ចូល
មកដល់ថ្ងៃ អង្គារ ទី ០២/០២/២០១៦
ម៉ោង ១១:០០នាទី ព្រឹក
លេខ ០២៣/១៦ ក.ជ.ភ.ខ

## ផ្ញើជូន

## ឯកឧត្តមបណ្ឌិតសភាចារ្យ ហ៊ុំ ម៉ល់ ប្រធានក្រុមប្រឹក្សាជាតិភាសាខ្មែរ

*ឯកឧត្តមបណ្ឌិតសភាចារ្យ ជាទីស្រឡាញ់រាប់អាន !*

ខ្ញុំបានទទួលរួចហើយនូវសៀវភៅរបស់ឯកឧត្តម ដែលបានផ្ញើមកជូនខ្ញុំ មានចំណងជើងថា សទ្ទានុក្រមវេជ្ជសាស្ត្រ និងកសិកម្ម, សទ្ទានុក្រមវប្បធម៌ និងវិចិត្រសិល្បៈ និងព្រឹត្តិបត្រក្រុមប្រឹក្សាជាតិភាសាខ្មែរ ចំនួន ៣០ ច្បាប់ ដើម្បីខ្ញុំបានស្វែងយល់។

ឆ្លៀតឱកាសនេះ ខ្ញុំសូមថ្លែងនូវការកោតសរសើរដោយស្មោះចំពោះឯកឧត្តមបណ្ឌិត ដែលបានខិតខំស្រាវជ្រាវចងក្រងសៀវភៅដ៏មានសារៈសំខាន់នេះឡើង ទុកជាឯកសារសម្រាប់កូនចៅជំនាន់ក្រោយបានសិក្សាស្រាវជ្រាវ។

ជាថ្មីម្តងទៀត ក្នុងនាមភរិយាខ្ញុំ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ និងសូមប្រសិទ្ធពរជ័យបវរមហាប្រសើរជូនចំពោះឯកឧត្តមបណ្ឌិត និងសហការី សូមបានប្រកបដោយពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូមឯកឧត្តមបណ្ឌិតសភាចារ្យ ទទួលនូវការស្រឡាញ់រាប់អានដ៏ជ្រាលជ្រៅពីខ្ញុំ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ មករា ឆ្នាំ២០១៦

**ហ៊ុន សែន**

ព្រឹទ្ធសភា
អគ្គលេខាធិការដ្ឋាន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាជាតិភាសាខ្មែរ
ចូល
មកដល់ថ្ងៃ ៣ 15/02/16
ម៉ោង 11h ៣០
លេខ 032/16

## លិខិតថ្លែងអំណរគុណ

អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា មានកិត្តិយសសូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅជូនចំពោះ **ឯកឧត្តម បណ្ឌិតសភាចារ្យ ហ៊ុំ ម៉ល់ ប្រធានក្រុមប្រឹក្សាជាតិភាសាខ្មែរ** ព្រមទាំងសហការី ដែលបានផ្តល់ព្រឹត្តិបត្រលេខ៧ របស់ក្រុមប្រឹក្សាជាតិភាសាខ្មែរ ចំនួន ០៤ក្បាល ដើម្បីតម្កល់នៅ បណ្ណាល័យព្រឹទ្ធសភា សម្រាប់សមាជិក សមាជិកា ព្រឹទ្ធសភា មន្ត្រីរាជការ និស្សិត សិស្ស និងសាធារណជនទូទៅសិក្សាស្រាវជ្រាវ។

ខ្ញុំសង្ឃឹម និងជឿជាក់ថា ឯកឧត្តមបណ្ឌិតសភាចារ្យ ព្រមទាំងសហការី នឹងបន្តជួយផ្តល់សៀវភៅ ព្រឹត្តិបត្រ និងឯកសារថ្មីៗ ដើម្បីជាប្រយោជន៍ក្នុងការអភិវឌ្ឍធនធានមនុស្សក្នុងព្រះរាជាណាចក្រកម្ពុជា ។

សូម ឯកឧត្តមបណ្ឌិតសភាចារ្យ ទទួលនូវការរាប់អានដ៏ស្មោះស្ម័គ្រ អំពីខ្ញុំ ។ល។

រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែកុម្ភៈ ឆ្នាំ២០១៦
**អគ្គលេខាធិការ**

អ៊ុំ សារិទ្ធ

វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (855 23) 211 441, 211 442, 211 443 ទូរសារ: (855 23) 211 446. E-mail: oum_sarith@camnet.com.kh

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងបរិស្ថាន
លេខ : ០៧៩ សរ.សណ.ប.ស្ក

ក្រុមប្រឹក្សាជាតិភាសាខ្មែរ
ចូល មកដល់ថ្ងៃ ០៧/11/02/16
ម៉ោង ១៤:០០
លេខ ០៣០/16

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែកុម្ភៈ ឆ្នាំ២០១៦

**គោរពជូន**
**ឯកឧត្តមបណ្ឌិតសភាចារ្យ ហ៊ាំ ម៉ល់**
**ប្រធានក្រុមប្រឹក្សាជាតិភាសាខ្មែរ**

ខ្ញុំមានសេចក្តីសោមនស្សរីករាយ និងសូមថ្លែងអំណរគុណយ៉ាងស្មោះចំពោះ ឯកឧត្តមបណ្ឌិតសភាចារ្យ ដែលបានផ្ញើព្រឹត្តិបត្រលេខ៧របស់ក្រុមប្រឹក្សាជាតិភាសាខ្មែរ(ក.ជ.ភ.ខ.)ចំនួន៤ច្បាប់ដល់ខ្ញុំ ដើម្បីជួយផ្សព្វផ្សាយដល់មន្ត្រីរាជការក្រសួងបរិស្ថាន។

ខ្ញុំសូមកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះស្នាដៃរបស់ក្រុមប្រឹក្សាជាតិភាសាខ្មែរ ដែលបានខិតខំប្រឹងប្រែងរៀបចំចងក្រងព្រឹត្តិបត្រ សម្រាប់ជាមូលដ្ឋាននៃចំណេះដឹង និងគុណប្រយោជន៍ដល់មន្ត្រីរាជការគ្រប់ស្ថាប័ន និងសាធារណជនទទួលបាននូវបច្ចេកសព្ទ ដែលទាក់ទងនឹងវេជ្ជសាស្ត្រ កសិកម្ម វិចិត្រសិល្បៈ វប្បធម៌ និងសេដ្ឋកិច្ច និងជាការលើកកម្ពស់ការយល់ដឹងភាសាខ្មែរ ដើម្បីប្រើប្រាស់ភាសាខ្មែរឱ្យមានការឯកភាពគ្នា និងបានត្រឹមត្រូវ។

ជាទីបញ្ចប់ ខ្ញុំសូមប្រសិទ្ធពរជ័យជូនចំពោះ ឯកឧត្តម ថ្នាក់ដឹកនាំ និងមន្ត្រីរាជការទាំងអស់នៃក.ជ.ភ.ខ. សូមប្រកបដោយសុខភាពល្អ និងប្រកបដោយពុទ្ធពរទាំងបួនប្រការគឺអាយុ វណ្ណៈ សុខៈនិងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូមឯកឧត្តមបណ្ឌិតសភាចារ្យ មេត្តាទទួលនូវការរាប់អានដ៏ស្មោះពីខ្ញុំ។

រដ្ឋមន្ត្រី

សាយ សំអាល់

អគារមរតកតេជោ ដីឡូលេខ503 ផ្លូវកៅស៊ូអមមាត់ទន្លេបាសាក់ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ភ្នំពេញ ទូរស័ព្ទ: ០២៣ ២១៣ ៩០៨, ០២៣ ២២០ ៣៦៩ ទូរសារ: ០២៣ ២១២ ៥៤០

**Manulife**

លេខ:០៦១........២០១៥/LC

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាជាតិភាសាខ្មែរ
ចូល មកដល់ថ្ងៃ ១៨.៥.២០១៥
ម៉ោង ១៤:០០
លេខ ១១៥/១៥ ក.ជ.ភ.ខ

**ក្រុមហ៊ុន មេនូឡាយហ្វ៍ (ខេមបូឌា) ភីអិលស៊ី**
**សូមគោរពជូន**
**ឯកឧត្តម បណ្ឌិតសភាចារ្យ ព្រំ ម៉ល់**
**ប្រធានក្រុមប្រឹក្សាជាតិភាសាខ្មែរ**

**កម្មវត្ថុ ៖** សេចក្ដីថ្លែងអំណរគុណចំពោះការផ្ដល់ជូននូវព្រឹត្តិបត្ររបស់ក្រុមប្រឹក្សាជាតិភាសាខ្មែរ(ក.ជ.ភ.ខ) លេខមុនៗចំនួនពីរ(០២)ច្បាប់ គ្រប់លេខ។

សេចក្ដីដូចមានចែងក្នុងកម្មវត្ថុខាងលើ យើងខ្ញុំមានកិត្តិយស សូមគោរពជូន **ឯកឧត្តម បណ្ឌិតសភាចារ្យ** មេត្តាជ្រាបថា ក្រុមហ៊ុន មេនូឡាយហ្វ៍(ខេមបូឌា)ភីអិលស៊ី បានទទួលរួចហើយនូវព្រឹត្តិបត្ររបស់ក្រុមប្រឹក្សាជាតិភាសាខ្មែរ ដែលបានផ្ញើមកក្រុមហ៊ុន ដើម្បីជាឯកសារ និងផ្សព្វផ្សាយបន្តដល់បុគ្គលិកនៃក្រុមហ៊ុន មេនូឡាយហ្វ៍។

ក្រុមហ៊ុនមេនូឡាយហ្វ៍ (ខេមបូឌា) ភីអិលស៊ី សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ **ឯកឧត្តម បណ្ឌិត សភាចារ្យ** ដែលបានផ្ដល់នូវព្រឹត្តិបត្រនេះ និងសូមសម្ដែងនូវការកោតសរសើរដ៏ស្មោះចំពោះក្រុមប្រឹក្សាជាតិភាសាខ្មែរដែលខិតខំចងក្រងនូវស្នាដៃដ៏មានសារសំខាន់នេះ ដើម្បីជាប្រយោជន៍ដល់ក្រុមហ៊ុនអាចមានលទ្ធភាពផ្សព្វផ្សាយបន្តដល់បុគ្គលិកគ្រប់នាយកដ្ឋាននៃក្រុមហ៊ុន មេនូឡាយហ្វ៍។

សូម **ឯកឧត្តម បណ្ឌិត សភាចារ្យ** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីយើងខ្ញុំ។

រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែ ឧសភា ឆ្នាំ២០១៥
**ជ.ក្រុមហ៊ុន មេនូឡាយហ្វ៍ (ខេមបូឌា) ភីអិលស៊ី**
**នាយកនាយកដ្ឋានច្បាប់ និង**
**ការប្រតិបត្តិតាមច្បាប់**

ព្រះរាជាណាចក្រកម្ពុជា ក្រុមហ៊ុន មេនូឡាយហ្វ៍ (ខេមបូឌា) ភីអិលស៊ី MANULIFE (CAMBODIA) PLC KINGDOM OF CAMBODIA

**លោក ព្រូ ស៊ីថន**

ក្រុមហ៊ុនមេនូឡាយហ្វ៍ (ខេមបូឌា) ភីអិលស៊ី
លេខ ១០៤ អគារសេរី ជាន់ទី ៨ មហាវិថីសហព័ន្ធរុស្ស៊ី
សង្កាត់ទឹកល្អក់ ១ ខណ្ឌទួលគោក ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទផ្នែកសេវាបម្រើអតិថិជន៖ (៨៥៥) ២៣ ៩៦៥ ៩៩៩
ទូរសារ៖ (៨៥៥) ២៣ ៩៦៥ ៩៦៦ www.manulife.com.kh